ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ សកម្មភាពប្រយុទ្ធ នឹងជំងឺអេដស៍/កាមរោគ

# ប្រចាំត្រីមាសទី ១ ឆ្នាំ ២០០៤

ក្រសួងសុខាភិបាល

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

# សេចក្តីសង្ខេប

## ១. សកម្មភាពនៅថ្នាក់ខេត្ត

នៅក្នុងត្រីមាសទី១ ឆ្នាំ ២០០៤ នេះ ខេត្ត-ក្រុង ចំនួន១៩ នៅក្រោមគំរោង DFID បានប្រើប្រាស់ថវិកាដែលបានអនុម័តហើយអស់ ៦៤%, ខេត្តចំនួន៤ ដែលប្រើប្រាស់ថវិកាអស់ ៨៤% ក្រោមគំរោង ADB និងខេត្តបន្ទាយមានជ័យ ដែលប្រើប្រាស់ថវិការបស់អង្គការ CDC ដើម្បីអនុវត្តសកម្មភាព បង្ការនិងទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ដូចជាការអប់រំផ្សព្វផ្សាយតាមរយៈវិទ្យុ ទូរទស្សន៍ និងការរៀបចំយុទ្ធនាការ ឃោសនាផ្សព្វផ្សាយ ក្នុងឱកាស បុណ្យជាតិសំខាន់ៗ កម្មវិធីមិត្តអប់រំមិត្ត កម្មវិធីអប់រំផ្ទាល់ កម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០% ការងារគ្រប់គ្រង និងព្យាបាលជំងឺកាមរោគ សំរាប់ប្រជាជនទូទៅ នៅតាមមណ្ឌលសុខភាព ការងារគ្រប់គ្រង និងព្យាបាលជំងឺកាមរោគ សំរាប់នារីរកស៊ីផ្លូវភេទ នៅគ្លីនិកកាមរោគ ទាំង ២៩, កម្មវិធីថែទាំបន្ត ដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ។

## ២. សកម្មភាពនៅថ្នាក់ជាតិ

យោងទៅតាមគំរោងផែនការសកម្មភាពប្រចាំ ត្រីមាសទី១ ឆ្នាំ ២០០៤ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានពង្រឹងនិងពង្រីកនូវសកម្មភាពមួយចំនួនដូចជា:

### ១. ការអប់រំផ្សព្វផ្សាយ និងកម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០%:

ដើម្បីឆ្លើយតបទៅនឹងតំរូវការសំភារៈអប់រំស្តីពីជំងឺអេដស៍/កាមរោគ សំរាប់ប្រើប្រាស់ក្នុងសកម្មភាព ប្រយុទ្ធនឹងជំងឺអេដស៍ មជ្ឈមណ្ឌលជាតិ បានរៀបចំ សិក្ខាសាលាស្តីពីការផលិត និងរបៀបប្រើប្រាស់សំភារៈ ព្រមទាំងបានពង្រាង ឯកសារសំរាប់ផលិតសំភារៈមួយចំនួន ដូចជា: ខិត្តបណ្ណ ផ្ទាំងរូបភាព កូនសៀវភៅ អប់រំពីជំងឺអេដស៍ កាមរោគ មួក អាវយឺត និងបានដាក់តាំងនូវផ្ទាំងបដាធំៗបីប្រភេទផ្សេងៗគ្នា ចំនួន១២ នៅជ្រោយចង្វា (រាជធានីភ្នំពេញ) , ខេត្តតាកែវ កំពង់ស្ពឺ កំពង់ចាម និងនៅ ខេត្តកណ្តាល ។

មន្ត្រីផ្នែកនេះ បានចុះអភិបាលការងារលើកម្មវិធីមិត្តអប់រំមិត្ត កម្មវិធីអប់រំផ្ទាល់ និងកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០% នៅតាមបណ្តាខេត្តមួយចំនួនដូចជា: ខេត្តកំពង់ស្ពឺ កំពង់ចាម ប៉ៃលិន បាត់ដំបង និងបន្ទាយមានជ័យ ដើម្បីឱ្យការអនុវត្តកម្មវិធីនេះមានដំណើរការកាន់តែល្អប្រសើរឡើង ។

### ២. កម្មវិធីជំងឺកាមរោគ

ដើម្បីឱ្យការអនុវត្តកម្មវិធីនេះកាន់តែមានភាពប្រសើរ មន្ត្រីផ្នែកជំងឺកាមរោគ បានរៀបចំកិច្ចប្រជុំ ជាមួយក្រុមការងារបច្ចេកទេស ដើម្បីរៀបចំកែលំអនូវគោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រង និងថែទាំជំងឺ កាមរោគ សំរាប់ប្រជាជនទូទៅ និងរៀបចំធ្វើការបង្កើតប្រព័ន្ធពិនិត្យគុណភាពសំរាប់មន្ទីរពិសោធន៍ដែលនឹងសាកល្បងធ្វើ នៅគ្លីនិកកាមរោគ ខេត្តបាត់ដំបង បន្ទាយមានជ័យ និងកោះកុង ។

មន្ត្រីផ្នែកនេះ បានចូលរួមជាគ្រូសំរបសំរួលក្នុងវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងថែទាំជំងឺ កាមរោគ និង ការអភិបាល សំរាប់មន្ត្រីស្រុកប្រតិបត្តិ នៅខេត្តបន្ទាយមានជ័យ និងខេត្តកំពង់ចាម និងវគ្គ បណ្តុះបណ្តាលបំប៉ន ស្តីពី ការគ្រប់គ្រង និងថែទាំជំងឺកាមរោគ ដល់មន្ត្រីគ្លីនិកកាមរោគ នៅខេត្តសៀមរាប កណ្តាល និងក្រុងប៉ៃលិន ដែលឧបត្ថម ដោយអង្គការសុខភាពគ្រួសារអន្តរជាតិ ព្រមទាំងបានចុះអភិបាល ការងារនៅតាមគ្លីនិកកាមរោគ និងមណ្ឌលសុខភាព ដែលមានសេវាថែទាំជំងឺកាមរោគ នៅតាមបណ្តាខេត្ត មួយចំនួនដូចជាៈ ខេត្តកំពង់ស្ពឺ កំពង់ចាម កំពង់ធំ សៀមរាប កណ្តាល ប៉ៃលិន បាត់ដំបង ព្រះវិហារ ឧត្តរមានជ័យ និងបន្ទាយមានជ័យ។

## ៣. កម្មវិធីថែទាំអ្នកជំងឺអេដស៍បន្ត

មជ្ឈមណ្ឌលជាតិបានរៀបចំវគ្គសិក្ខាសាលាស្តីពីការពិនិត្យឡើងវិញ នូវគំរោងផែនការយុទ្ធសាស្ត្រឆនាំ ២០០៤-២០០៧ និងការផ្លាស់ប្តូរបទពិសោធន៍ ស្តីពីការថែទាំបន្តរបស់ស្រុកប្រតិបត្តិមោងឫស្សី ដែលមានការ ចូលរួម ពីខេត្ត-ក្រុង ចំនួន៥ ដែលនឹងត្រូវពង្រីកនូវកម្មវិធីថែទាំបន្តគឺ ខេត្តស្វាយរៀង ព្រៃវែង កំពង់ចាម សៀមរាប និងខេត្តតាកែវ ។

ផ្តល់ការគាំទ្រ និងជំនួយបច្ចេកទេសនៅក្នុងវគ្គសិក្ខាសាលា និងការអនុវត្តសកម្មភាពថែទាំអ្នកជំងឺ អេដស៍ តាមផ្ទះ និងតាមសហគមន៍ ការថែទាំអ្នកជំងឺអេដស៍ក្នុងមន្ទីរពេទ្យ ការប្រើថ្នាំប្រឆាំងមេរោគអេដស៍ ការថែទាំបន្ត និងផ្នែកធ្វើ តេស្តឈាម និងផ្តល់ប្រឹក្សា នៅតាមបណ្តាខេត្តក្រុងមួយចំនួន ដូចជានៅខេត្ត កោះកុង តាកែវ ស្វាយរៀង ពោធិសាត់ បាត់ដំបង ក្រុងព្រះសីហនុ ព្រៃវែង ។

## ៤. ការងារគ្រប់គ្រង សំរបសំរួល និង ផែនការ

ដើម្បីសំរួលដល់ការអនុវត្តការងារ មជ្ឈមណ្ឌលជាតិបានផ្គត់ផ្គង់កុំព្យូទ័រចំនួន ១៦ និងម៉ាស៊ីនព្រីន ចំនួន ១២ ដល់ថ្នាក់ជាតិ និងថ្នាក់ខេត្ត ក្រោមគំរោង DFID ។

បានចងក្រងនូវគំរោងផែនការសកម្មភាពគ្រប់ជ្រុងជ្រោយ ប្រចាំឆ្នាំ២០០៤, ត្រីមាសទី១ និងរបាយការណ៍ ប្រចាំ ត្រីមាស ជាភាសាខ្មែរ និងអងគ្លេស និងធ្វើការបែងចែកដល់ ម្ចាស់ជំនួយ មន្ទីរសុខាភិបាលខេត្ត និងស្ថាប័ន អង្គការផ្សេងៗ ដែលពាក់ព័ន្ធ។

ដើម្បីពង្រឹងនូវប្រព័ន្ធតាមដាន របាយការណ៍ និងវាយតំលៃ មជ្ឈមណ្ឌលជាតិបានរៀបចំបង្កើតឱ្យ មាន គោលការណ៍ណែនាំ និងប្រព័ន្ធរបាយការណ៍គ្រប់គ្រងលទ្ធផលការបញ្ចូលទិន្ន័យ វិភាគទិន្ន័យ និងវគ្គសិក្ខាសាលាចំនួន២វគ្គ ដល់ប្រធានកម្មវិធីអេដស៍ ទាំង២៤ខេត្ត-ក្រុង និងមន្ត្រីតាមផ្នែកនិមួយៗនៃ មជ្ឈមណ្ឌល ជាតិ។

ភ្នំពេញ, ១៧ ឧសភា ឆ្នាំ ២០០៤

**ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹង ជំងឺអេដស៍ សើស្បែក និងកាមរោគ**

ប្រធានផ្នែកតាមដានត្រួតពិនិត្យ របាយការណ៍ និងវាយតំលៃ

**វេជ្ជ, លឹម យី**

# មាតិកា

ទំព័រ

សេចក្តីសង្ខេប

១ សកម្មភាពការងារនៅថ្នាក់ជាតិ

១,១,ការិយាល័យបច្ចេកទេស,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ០១

១,១,១, ផ្នែកផែនការ និងសំរបសំរួល,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ០១

១,១,២, ផ្នែកតាមដានត្រួតពិនិត្យ របាយការណ៍ និងវាយតំលៃ,,,,, ០២

១,២, ផ្នែកបច្ចេកទេសជំនាញ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ០២

១,២,១, ផ្នែកពពីមានអប់រំ និងទំនាក់ទំនងមហាជន,,,,,,,,,,,,,,,,, ០២

១,២,២, ផ្នែកជំងឺកាមរោគ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ០៤

១,២,៣, ផ្នែកថែទាំជំងឺអេដស៍,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ០៦

១,២,៤, ផ្នែកស្រាវជ្រាវ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ០៧

១,២,៥, ផ្នែកអង្កេតតាមដាន,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ០៩

១,២,៦, គ្លីនិកជាតិ សើស្បែក និង កាមរោគ,,,,,,,,,,,,,,,,,, ១១

២ សកម្មភាពការងារនៅថ្នាក់ខេត្ត

១, ខេត្តបន្ទាយមានជ័យ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ១៤

២, ខេត្តបាត់ដំបង,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ១៩

៣, ខេត្តព្រៃវែង,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ២១

៤, ខេត្តស្វាយរៀង,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ២៤

៥, ខេត្តកោះកុង,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ២៧

៦, ខេត្តកំពង់ចាម,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៣០

៧, ខេត្តកំពង់ឆ្នាំង,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៣៣

៨, ខេត្តកំពង់ស្ពឺ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៣៦

៩, ខេត្តកំពង់ធំ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៣៧

១០, ខេត្តកំពត,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៣៩

១១, ខេត្តកណ្តាល,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៤១

១២, ក្រុងកែប,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៤៤

១៣, ក្រុងប៉ៃលិន,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៤៥

១៤, ក្រុងភ្នំពេញ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៤៧

១៥, ខេត្តពោធិសាត់,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៤៨

១៦, ខេត្តរត្តនៈគិរី,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៥០

១៧, ខេត្តសៀមរាប,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៥១

១៨, ក្រុងព្រះសីហនុ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៥៥

១៩, ខេត្តស្ទឹងត្រែង,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៥៧

២០, ខេត្តតាកែវ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៥៩

២១, ខេត្តព្រះវិហារ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៦០

២២, ខេត្តឧត្តរមានជ័យ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៦១

២៣, ខេត្តមណ្ឌលគិរី,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៦២

២៤, ខេត្តក្រចេះ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៦៣

# របាយការណ៍សកម្មភាពប្រយុទ្ធនឹងជម្ងឺអេដស៍_កាមរោគ
# របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
# ប្រចាំត្រីមាសទី១ ឆ្នាំ ២០០៤

## ១.សកម្មភាពការងារនៅថ្នាក់ជាតិ

### ១.១. ការិយាល័យបច្ចេកទេស

#### ១.១.១. ផ្នែកផែនការ សំរបសំរួល និងគ្រប់គ្រងកម្មវិធី

**ក. កិច្ចប្រជុំ :**

នៅដើមឆ្នាំ២០០៤នេះ មជ្ឈមណ្ឌលជាតិ បានអនុវត្តន៏ការងារសំខាន់ៗមួយចំនួន ដូចជា :

- ចូលរួមកិច្ចប្រជុំកំណត់ទិសដៅសកម្មភាព
  សំរាប់អនុវត្តន៏កម្មវិធីអេដស៏ឆ្នាំ២០០៤របស់ផ្នែកនិមួយៗនៃ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹង ជំងឺអេដស៏ សើស្បែក និងកាមរោគ និងខេត្ត-ក្រុងទាំង ២៤ ដោយរួមបញ្ចូលផែន ការគ្រប់គ្រងសំរាប់ សកម្មភាព ខែមករានិងរួមបញ្ចូលផែនការលទ្ធកម្មគ្រប់ជ្រុងជ្រោយ សំរាប់ឆ្នាំ២០០៤ របស់ គំរោងថវិកា DFID ។
- ចូលរួមប្រជុំពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្រ សំរាប់បង្ការនិងថែទាំជម្ងឺអេដស៏/កាមរោគ របស់ មជ្ឈ មណ្ឌលជាតិ ឆ្នាំ ២០០១-២០០៥ ។
- ចូលរួមក្នុងកិច្ចប្រជុំបច្ចេកទេស និងរៀបចំបញ្ចូលសេចក្តីព្រាងគំរោងផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០០៤ - ២០០៧
- ចូលរួមសំរបសំរួលក្នុងកិច្ចប្រជុំស្ដីពីការដាក់បញ្ចូល ផែនការសកម្មភាពមួយចំនួន ដែលឧបត្ថម្ភដោយអង្គការ URC ទៅក្នុងផែនការសកម្មភាពគ្រប់ជ្រុងជ្រោយរបស់កម្មវិធីអេដស៏ខេត្ត-ក្រុង ចំនួន ៧។

**ខ. ការងារអភិបាល :**

- មន្ត្រីផ្នែកផែនការសំរបសំរួលគំរោង
  បានចុះអភិបាលការងារអនុវត្តន៏លើគំរោងផែនការសកម្មភាព នៃកម្មវិធី អេដស៏ ត្រីមាសទី១

ឆ្នាំ ២០០៤ និងពិនិត្យមើលពីឱសថបរិក្ខារ ដែលបានប្រើប្រាស់នៅ តាមស្រុកប្រតិបត្តិ នៅខេត្ត ព្រៃវែង ខេត្តស្វាយរៀង និងបាត់ដំបង និងខេត្តបន្ទាយមានជ័យ ។

**ឍ. សកម្មភាពផ្សេងៗ :**

- រៀបចំបញ្ចូលផែនការសកម្មភាព ប្រចាំត្រីមាសទី១ ឆ្នាំ ២០០៤ របស់មជ្ឈមណ្ឌលជាតិ និង ខេត្ត-ក្រុង ។
- រៀបចំបញ្ចប់ផែនការសកម្មភាពគ្រប់ជ្រុងជ្រោយ ប្រចាំឆ្នាំ២០០៤ របស់ខេត្ត-ក្រុង ចំនួន១៩ និងផ្នែកនានា របស់មជ្ឈមណ្ឌលជាតិ លើកលែងតែខេត្តរបស់គំរោង ADB និង CDC
- រៀបចំគំរោងផែនការសកម្មភាពប្រចាំខែមករា និងខែកុម្ភៈ ឆ្នាំ២០០៤ របស់ ផ្នែកផែនការ សំរបសំរួល និង គ្រប់គ្រងកម្មវិធី និងរៀបចំកិច្ចព្រមព្រៀងលើផែនការសកម្មភាពប្រចាំ ឆ្នាំ ២០០៤ របស់ ខេត្ត-ក្រុង ចំនួន១៩ ដែលឧបត្ថម្ភដោយ DFID.

## ១.៧. ផ្នែកតាមដានត្រួតពិនិត្យ របាយការណ៍ និងវាយតំលៃ

**ក. កិច្ចប្រជុំ :**

- ចូលរួមប្រជុំការងារបច្ចេកទេសរបស់មជ្ឈមណ្ឌលជាតិ ចំនួនពីរលើកក្នុង១ខែ និងធ្វើការប្រជុំក្នុង ផ្នែក ចំនួន ២ លើក ក្នុង១ខែ ដើម្បីពិនិត្យលើសកម្មភាពការងារកន្លងមក និងលើកទិសដៅ សំរាប់ការងារបន្ត ។

**ខ. វគ្គបណ្តុះបណ្តាល/សិក្ខាសាលា :**

- រៀបចំវគ្គសិក្ខាសាលា ចំនួន ២វគ្គ ស្តីពី ការពង្រឹងការតាមដាននិងរបាយការណ៍ របស់កម្មវិធី អេដស៍/កាមរោគ ខេត្ត-ក្រុង ដោយ មានសិក្ខាកាមចូលរួមជា ប្រធានកម្មវិធីអេដស៍ /កាមរោគ ទាំង ២៤ខេត្ត-ក្រុង និងមន្ត្រីតាម ផ្នែកនិមួយៗរបស់មជ្ឈមណ្ឌលជាតិ ។

**គ. ការងារអភិបាល :**

- មន្ត្រីផ្នែកតាមដានត្រួតពិនិត្យ វាយតំលៃ និងរបាយការណ៍ នៃការិយាល័យបច្ចេកទេស រួមជា មួយមន្ត្រីផ្នែក ផែនការ សំរបសំរួល គ្រប់គ្រងកម្មវិធី និងមន្ត្រីផ្នែកគណនេយ្យ បានចុះអភិបាល លើសកម្មភាពការងាររបស់ កម្មវិធីអេដស៍ ខេត្តព្រៃវែង, ស្វាយរៀង, បន្ទាយមានជ័យ, បាត់ដំបង, កោះកុង, កំពង់ធំ និងខេត្តព្រះវិហារ ។

**ឃ. សកម្មភាពផ្សេងៗ :**

- រៀបចំបង្កើតឱ្យមានគោលការណ៍ណែនាំ និងតារាងត្រួតពិនិត្យសំរាប់ផ្នែកតាមដានត្រួតពិនិត្យ របាយការណ៍ និងវាយតំលៃ ។
- រៀបចំរបាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០០៤ ជាភាសាខ្មែរនិងភាសាអង់គ្លេស ស្តីពី សកម្មភាពបង្ការ និង ថែទាំជំងឺអេដស៍ របស់មជ្ឈមណ្ឌលជាតិ និងខេត្ត-ក្រុងទាំង២៤ និងបាន ធ្វើការបែងចែកទៅដល់មន្ទីរ និង អង្គការនានាដែលពាក់ពន្ធ័ ។
- រៀបចំឱ្យមានប្រពន្ធ័របាយការណ៍គ្រប់គ្រងលទ្ធផលការបញ្ចូលទិន្នន័យ និងការវិភាគ ទិន្នន័យ ។

## ១.២. ផ្នែកបច្ចេកទេសជំនាញ

### ១.២.១. ផ្នែកអប់រំពត៌មាន និងទំនាក់ទំនងមហាជន

**ក. ការផលិត និងចែកចាយសំភារៈអប់រំផ្សព្វផ្សាយ :**

ដើម្បីឆ្លើយតបទៅនឹងតំរូវការសំភារៈអប់រំស្តីពីជំងឺអេដស៍/កាមរោគសំរាប់ប្រើប្រាស់ក្នុង សកម្មភាពប្រយុទ្ធ នឹង ជំងឺអេដស៍ មជ្ឈមណ្ឌលជាតិ បានរៀបចំពង្រាង ឯកសារសំរាប់ផលិត សំភារៈមួយ ចំនួនដូចជា :ខិត្តប័ណ្ណ ផ្ទាំងរូបភាពធំ កូនសៀវភៅ អប់រំអំពីជំងឺអេដស៍ /កាមរោគ មួកអារយឺត និងសំភារៈមួយចំនួនទៀតផ្ទាំងបដាធំ៧ចំនួន ១២ នឹងដាក់តាំងនៅក្នុង រាជធានី ភ្នំពេញ ខេត្តតាកែវ កំពង់ស្ពឺ ខេត្ត កណ្តាល ខេត្តកំពង់ចាម ។

**ខ. កិច្ចប្រជុំ :**

- ចូលរួមក្នុងកិច្ចប្រជុំប្រចាំផ្នែក ទៅតាមកាលវិភាគប្រចាំខែក្នុង ឆ្នាំ២០០៤
- ចូលរួមក្នុងកិច្ចប្រជុំស្តីពីការជ្រៀតបញ្ចូលចំណេះដឹងអំពីជំងឺអេដស៍និងកាមរោគ ទៅក្នុងសាលា រៀនបើកបរ ដែលស្ថិតនៅក្រោមក្រសួងសាធារណៈការ និងដឹកជញ្ជូន ។
- ចូលរួមក្នុងកិច្ចប្រជុំស្តីពីកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកាណាដា និងអាជ្ញាធរជាតិប្រយុទ្ធ នឹង ជម្ងឺអេដស៍ ក្នុងការទប់ស្កាត់ការរាល ដាលជម្ងឺអេដស៍ ចំពោះប្រជាជនចល័ត
- ចូលរួមក្នុងការប្រកាសផ្សព្វផ្សាយអំពីលទ្ធផល BSS ឆ្នាំ២០០៣ នៅសណ្ឋាគារ សាន់វ៉េ
- ចូលរួមក្នុងវគ្គសិក្ខាសាលាចែករំលែកបទពិសោធន៍ស្តីពីចំណេះដឹងអំពីជម្ងឺអេដស៍នៅការិយាល័យ នៃជនពិការ ក្មែកកម្ពុជា
- ចូលរួមប្រជុំស្តីពីការបង្កើតសារ និងកំណត់ក្រុមគោលដៅ សំរាប់អប់រំអំពីម្ងឺអេដស៍ របស់គំរោង BCC WSF នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍

**គ. វគ្គបណ្តុះបណ្តាល/សិក្ខាសាលា**

- មន្ត្រីផ្នែកពត៌មានអប់រំ និងទំនាក់ទំនង បានរៀបចំសិក្ខាសាលាស្តីពីការបណ្តុះបណ្តាលការផលិតសំភារៈ IEC.
- ចូលរួមក្នុងសិក្ខាសាលាស្តីពីរៀបចំធ្វើសារអប់រំ ចំពោះប្រិយមិត្ត សំរាប់យុទ្ធនាការផ្សព្វផ្សាយផ្នែក BCC ឆ្នាំ២០០៤-២០០៦ នៅ អង្គការ BBC World Service Trust.
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការអប់រំអំពីជម្ងឺកាមរោគ នៅតាមសហគមន៍ (Meeting on Speaker Training on HIV/AIDS for the Community )

**ឃ. ការងារអភិបាល :**

- មន្ត្រីផ្នែកពត៌មានអប់រំ និងទំនាក់ទំនង បានចុះអភិបាលការងារលើកម្មវិធី មិត្តអប់រំមិត្ត កម្មវិធីអប់រំផ្ទាល់ កម្មវិធីស្រោមអនាម័យ ១០០% ការបែងចែក និងការប្រើប្រាស់សំភារៈអប់រំ នៅក្រុងប៉ៃលិន កំពង់ចាម ខេត្តកណ្តាល រាជធានីភ្នំពេញ កំពង់ស្ពឺ ក្រចេះ ក្រុងព្រះសីហនុ ខេត្តតាកែវ កំពត ក្រុងកែប កំពង់ធំ ព្រះវិហារ ស្ទឹងត្រែង រតនគីរី សៀមរាប និងខេត្តបន្ទាយមានជ័យ ។
- ចូលរួមក្នុងការប្រជុំជាមួយម្ចាស់សេវា និងក្រុមមិត្តអប់រំមិត្ត នៅខេត្តខេត្តបាត់ដំបង ខេត្តបន្ទាយ មានជ័យ និងខេត្តកំពង់ស្ពឺ ។

**ង. សកម្មភាពការងារផ្សេងៗ :**

- រៀបចំធ្វើគំរោងផែនការសំរាប់ត្រីមាសទី១ ឆ្នាំ ២០០៤
- ចុះធ្វើតេស្តសាកល្បង លើសំភារៈអប់រំអំពីជម្ងឺ អេដស៍ ដែលរួមមាន រូបភាពផ្ទាំងធំ ចំនួន៣ កូនសៀវភៅចំនួន ២ និង ខិត្តបណ្ណ័ ចំនួន៣ នៅគ្លីនិកជាតិ សើស្បែក និងកាមរោគ នៅមន្ទីរពេទ្យបង្អែក និងនៅតាមសហគមន៍ ក្នុងខេត្តកំពង់ស្ពឺ និងនៅមណ្ឌលសុខភាពក្បាលកោះ ខេត្ត កណ្តាល
- ធ្វើការកែសំរួល លើសំភារៈអប់រំជម្ងឺអេដស៍ បន្ទាប់ពីបានធ្វើតេស្តសាកល្បងរួច
- រៀបចំធ្វើគំរោងសំរាប់ចុះអភិបាលការងារក្នុងត្រីមាសទី១ និងត្រីមាសទី២ ឆ្នាំ ២០០៤
- ចូលរួមក្នុងការតាំងពិពណ៌ស្តីពីសមិទ្ធិផលសុខាភិបាល របស់ អង្គភាពកម្មវិធីជាតិដែលបានអនុវត្តន៍ កន្លងមក នៅក្រសួងសុខាភិបាល

### ១.២.២. ផ្នែកប្រយុទ្ធនឹងជំងឺកាមរោគ

**ក. ការរៀបរៀងឯកសារ និងគោលការណ៍ណែនាំ :**

- រៀបចំកែលំអ គោលការណ៍ណែនាំ និងឯកសារស្តីពីការគ្រប់គ្រង ថែទាំជំងឺកាមរោគ សំរាប់ប្រជាជនទូទៅ ។
- មន្ត្រីផ្នែកប្រយុទ្ធនឹងជម្ងឺកាមរោគ បានរៀបចំកែសំរួលបោះពុម្ភ និងបែងចែកប្រវត្តិជំងឺ និងបណ្ណ័ សំរាប់ស្ត្រី រកស៊ីផ្លូវភេទ

**ខ. កិច្ចប្រជុំ :**

- រៀបចំការប្រជុំប្រចាំខែ របស់ផ្នែកប្រយុទ្ធនឹងជម្ងឺអេដស៍ និងចូលរួមប្រជុំការងារ បច្ចេកទេស តាមកាលវិភាគ ដែលបានកំណត់ ។

**គ. វគ្គបណ្តុះបណ្តាល/សិក្ខាសាលា :**

- ចូលរួមជាគ្រូសំរបសំរួលវគ្គបណ្តុះបណ្តាលបំប៉ន ស្តីពីការគ្រប់គ្រងនិងថែទាំជំងឺកាមរោគ សំរាប់ស្ត្រីរកស៊ីផ្លូវភេទ ដល់ បុគ្គលិកគ្លីនិកកាមរោគ នៅក្រុងប៉ៃលិន ខេត្តសៀមរាប ខេត្តកណ្តាល (មណ្ឌលសុខភាពក្បាលកោះ) ក្រោមការឧបត្ថម្ភរបស់អង្គការ FHI.
- ចូលរួមសំរបសំរួលក្នុងវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងថែទាំជំងឺកាមរោគ ដោយពឹងផ្អែកលើចង្កោម រោគសញ្ញា និងការអភិបាលសេវាថែទាំជំងឺកាមរោគ សំរាប់មន្ត្រីស្រុក ប្រតិបត្តិ ដែលមានសិក្ខាកាមចូលរួម ចំនួន២១រូប មកពីស្រុកប្រតិបត្តិចំនួន៦ របស់ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងក្រុងប៉ៃលិន ក្រោមការឧបត្ថមរបស់ CDC និងនៅខេត្តកំពង់ចាម មានសិក្ខាកាមចូលរួមចំនួន២១រូប មកពីស្រុកប្រតិបត្តិ ចំនួន១០ ។

**ឃ. ការងារអភិបាល :**

- មន្ត្រីផ្នែកប្រយុទ្ធនឹងជំងឺកាមរោគ បានចុះអភិបាលការងារនៅតាមគ្លីនិក និងសេវាថែទាំជំងឺកាមរោគ តាម បណ្តាខេត្ត-ក្រុងមួយចំនួនដូចជា នៅគ្លីនិកកាមរោគទួលគោក ក្នុងរាជធានីភ្នំពេញ និងគ្លីនិកកាមរោគ ដែល ស្ថិតនៅក្នុងមណ្ឌលសុខភាពក្បាលកោះ ខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តតាកែវ ខេត្តកំពត ក្រុងកែប ក្រុងព្រះសីហនុ ខេត្ត កំពង់ស្ពឺ ខេត្តកំពង់ធំ ព្រះវិហារ ស្ទឹងត្រែង រតនះគិរី សៀមរាប និងខេត្ត ឧត្តរមានជ័យ ។

**ង. សកម្មភាពផ្សេងៗ :**

- មន្ត្រីផ្នែកប្រយុទ្ធនឹងជំងឺកាមរោគ បានរៀបចំគំរោងផែនការសកម្មភាព ប្រចាំត្រីមាសទី១ ឆ្នាំ ២០០៤
- រៀបចំគំរោងផែនការសំរាប់ចុះអភិបាលប្រចាំត្រីមាសទី១ និងប្រចាំឆ្នាំ២០០៤
- រៀបចំតួនាទី និងភារៈកិច្ចរបស់ក្រុមការងារបច្ចេកទេសផ្នែកប្រយុទ្ធនឹងជម្ងឺកាមរោគ

- សហការជាមួយការិយាល័យបច្ចេកទេស ក្នុងការប៉ាន់ប្រមាណតំរូវការឱសថ និងការប្រើប្រាស់ សំភារៈ បរិក្ខារ សំរាប់ការពិនិត្យជម្ងឺកាមរោគ សំរាប់គ្លីនិកកាមរោគចំនួន ២៨ ដែលនៅ ក្នុង ខេត្ត-ក្រុង ចំនួន ២២ ។
- រៀបចំបញ្ជីរសំភារៈបរិក្ខារ សំរាប់ការពិនិត្យជម្ងឺកាមរោគ ដើម្បីផ្គត់ផ្គង់ ឱ្យគ្លីនីក ៩ នៅខេត្ត តាកែវ រាជធានី ភ្នំពេញ ប៉ៃលិន ពោធិសាត់ កំពង់ចាម និងបន្ទាយមានជ័យ ។
- សហការជាមួយផ្នែកលទ្ធកម្ម ដើម្បីរៀបចំបញ្ជីរតំរូវការសំភារៈការិយាល័យ សំរាប់គ្លីនិក កាមរោគ ចំនួន៤ ក្នុង រាជធានីភ្នំពេញ និង៤ ទៀត សំរាប់ខេត្តតាកែវ ពោធិសាត់ កំពង់ចាម ប៉ៃលិន ។
- សហការជាមួយការិយាល័យបច្ចេកទេសធ្វើការប៉ាន់ប្រមាណប្រតិករមន្ទីរពិសោធន៍សំរាប់គ្លីនិក កាមរោគ ចំនួន ១៩ នៅក្នុងខេត្តចំនួន១៤ ។
- បង្កើតប្រពន្ធ័ត្រួតពិនិត្យគុណភាព នៅក្នុងផ្នែកមន្ទីរពិសោធន៍ នៃគ្លីនិកកាមរោគ និងធ្វើការ សាកល្បង ក្នុងគ្លីនិកចំនួន៣ ក្នុងខេត្ត បាត់ដំបង កោះកុង និងបន្ទាយមានជ័យ ។
- រៀបចំបញ្ជីរសំភារៈចំនួន ១០សំរាប់ដើម្បីផ្គត់ផ្គង់ឱ្យគ្លីនិក ចំនួន១០ ក្នុងខេត្ត-ក្រុង ចំនួន ៦ គឺរាជធានីភ្នំពេញ ខេត្តតាកែវ ក្រុងប៉ៃលិន ខេត្តពោធិសាត់ ខេត្តកំពង់ចាមខេត្តបន្ទាយមានជ័យ

### ១.២.៣.ផ្នែកថែទាំនិងជំងឺអេដស៍

✰ **ការថែទាំអ្នកជំងឺក្នុងមន្ទីរពេទ្យ (Institutional Care) :**

**ក. វគ្គបណ្តុះបណ្តាល/សិក្ខាសាលា :**

- មន្ត្រីផ្នែកថែទាំជំងឺអេដស៍ក្នុងមន្ទីរពេទ្យ ចូលរួមក្នុងសិក្ខាសាលាតំរង់ទិស សំរាប់គណកម្មាធិការ (Faciliay Health Based Care) នៅមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ។
- ចូមរួមជាគ្រូសំរបសំរួលក្នុងសិក្ខាសាលាស្តីពីការផ្តល់ប្រឹក្សាស្តីពីជំងឺអេដស៍
- ចូលរួមក្នុងវគ្គសិក្ខាសាលា ដើម្បីពិនិត្យមើលអំពីផែនការយុទ្ធសាស្ត្រ របស់ខេត្តចំនួន៧ក្នុង ឆ្នាំ ២០០៤ ជាមួយ អង្គការ URC នៅសាលប្រជុំរបស់មជ្ឈមណ្ឌលជាតិ
- ចូលរួមវគ្គសិក្ខាសាលាស្តីពីការពិនិត្យឡើងវិញ គំរោងផែនការយុទ្ធសាស្ត្រ ឆ្នាំ២០០៤-២០០៧ និងការផ្លាស់ ប្តូរបទពិសោធន៍ ស្តីពីការថែទាំបន្ត ដែលប្រារព្ធនៅមជ្ឈណ្ឌលជាតិស្រាវជ្រាវ សុខភាពសាធារណៈ ក្រោមការ ឧបត្ថម្ភរបស់អង្គការ GFATM, US-CDC GAP, and FHI.
- ចូលរួមជាគ្រូសំរបសំរួល ក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការបង្ការជាសកល នៅខេត្តកោះកុង

**ខ. ការងារអភិបាល :**

- ចូលរួមផ្តល់ជំនួយបច្ចេកទេសក្នុងការប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ នៅខេត្តបាត់ដំបង
- ចុះអភិបាលការងារថែទាំបន្តអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជម្ងឺអេដស៍ នៅខេត្តពោធិសាត់ ក្រុងព្រះសីហនុ និងខេត្តព្រៃវែង

☆ **ការថែទាំនៅតាមផ្ទះ (Home Base Care) :**

**ក. កិច្ចប្រជុំ :**

- ចូលរួមប្រជុំពិនិត្យឡើងវិញនូវគំរោងផែនការយុទ្ធសាស្ត្រសំរាប់ឆ្នាំ ២០០៤-២០០៧

**ខ. វគ្គបណ្តុះបណ្តាល/សិក្ខាសាលា :**

- ចូលរួមជាគ្រូសំរបសំរួលក្នុងវគ្គបណ្តុះបណ្តាលបំប៉នស្តីពីកាថែទាំជំងឺអេដស៍តាមផ្ទះដែលរៀបចំដោយ អង្គការ WVC នៅការិយាល័យរបស់អង្គការ WVC.
- ចូលរួមក្នុសិក្ខាសាលាស្តីពីគោលការណ៏ណែនាំសំរាប់ថែទាំអ្នកជំងឺអេដស៍តាមផ្ទះ និងសហគមន៏សំរាប់ក្រុមថែទាំអ្នកជំងឺអេដស៍ តាមផ្ទះនិងសហគម៏ នៅខេត្តបាត់ដំបង ដែលឧបត្ថម្ភដោយអង្គការ FHI.
- ចូលរួមសំរបសំរួលក្នុងវគ្គសិក្ខាសាលាស្តីពី ការបង្កើតបណ្តាញទំនាក់ទំនងនៃការថែទាំជំងឺអេដស៍តាមផ្ទះដែលរៀបចំដោយអង្គការ KHANA នៅខេត្តតាកែវ និងខេត្តសៀមរាប ។
- ចូលរួមជាគ្រូសំរបសំរួល ក្នុងវគ្គបណ្តុះបណ្តាល ស្តីពីគោលការណ៏ណែនាំក្នុងការថែទាំអ្នកជំងឺអេដស៍តាមផ្ទះ ដែលមានសិក្ខាកាមចំនួន ១៣រូប មកពីក្រុមថែទាំជម្ងឺ អេដស៍តាមផ្ទះ នៅខេត្តកណ្តាល ។

☆ **ការថែទាំបន្ត ( Continuum of Care ) :**

- រូបចូលរួមក្នុងងសិក្ខាសាលាស្តីពីការបង្កើតបណ្តាញទំនាក់ទំនងរវាងអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជម្ងឺអេដស៍ នៅខេត្តបាត់ដំបង ដែលឧបត្ថម ដោយអង្គការ KHANA
- ចូលរួមក្នុងសិក្ខាសាលា ស្តីពីការបង្ហាញកម្មវិធី ថែទាំបន្ត នៅក្នុងស្រុកប្រតិបត្តិសំពៅលូន ខេត្តបាត់ដំបង

☆ **ការផ្តល់ប្រឹក្សា ធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ ( VCCT ) :**

**ក.ការងារអភិបាល :**

- មន្ត្រីអនុផ្នែកផ្តល់ប្រឹក្សា ធ្វើតេស្តឈាមដោយស្មគ្រ័ចិត្ត និងរក្សាការសំងាត់ បានចុះអភិបាលការងារលើសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាម នៅខេត្ត ពោធិសាត់ បាត់ដំបង ក្រចេះ ស្ទឹងត្រែង ក្រុងព្រះសីហនុ និងខេត្ត បន្ទាយមានជ័យ ។

**៩.សកម្មភាពផ្សេងៗ :**

- ធ្វើការបែងចែកសំភារៈ Reagent ដល់គ្រប់សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដោយស្មគ្រ័ចិត្ត និងរក្សាការ សំងាត់
- ចូលរួមក្នុងពិធីសម្ភោធអាគារផ្តល់ប្រឹក្សា ធ្វើតេស្តឈាមដោយស្មគ្រ័ចិត្ត និងរក្សាការសំងាត់ នៅស្រុកមោង ឬស្សី ខេត្តបាត់ដំបង ។

**១.២.៤.ផ្នែកស្រាវជ្រាវ**

**ក. កិច្ចប្រជុំ/សិក្ខាសាលា :**

- ចូលរួមធ្វើ Presentation of NCHADS HIV Prevention Study នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការ សំរបសំរួលជំងឺអេដស៍ (HACC) ។
- ប្រជុំពិភាក្សា ជាមួយក្រុមការងារ Formative Research សំរាប់ NCHADS HIV Prevention Study.
- រៀងរាល់សប្តាហ៍ ធ្វើការប្រជុំពិភាក្សា ជាមួយលោកស្រី Margery Lazarus លើគំរោង ផែនការ និង យុទ្ធសាស្រ្តសំរាប់ធ្វើ Formative Research សំរាប់ NCHADS HIV Prevention Study.
- រៀបចំធ្វើការប្រជុំលើកដំបូង Community advisory Group លើគំរោងផែនការ និងយុទ្ធសាស្រ្ត ដើម្បី ផ្តល់យោបល់ដល់ការបង្កើត Informaed consent.
- ចូលរួមផ្សព្វផ្សាយ ស្តីពីការប្រើប្រាស់ឱសថ Tenoforvier ទៅលើក្រុមនារីរកស៊ីផ្លូវភេទ ដោយផ្ទាល់ នៅមជ្ឈមណ្ឌលជាតិ
- រៀងរាល់ថ្ងៃចន្ទ័ និងថ្ងៃអង្គារមន្ត្រីផ្នែកស្រាវជ្រាវធ្វើការប្រជុំពិភាក្សាជាមួយក្រុមការងាររបស់ NCHADS HIV Prevention ដែលឈរជើងនៅកម្ពុជា
- រៀងរាល់ថ្ងៃពុធមន្ត្រីផ្នែកស្រាវជ្រាវធ្វើការប្រជុំពិភាក្សាតាមរយៈទូរសព្ទ័ជាមួយក្រុមស្រាវជ្រវ មកពី សហរដ្ឋអាមេរិក និងអូស្រ្តាលី អំពី NCHADS HIV Prevention Study.
- រៀងរាល់ថ្ងៃព្រហស្បត្តិ៍មន្ត្រីផ្នែកស្រាវជ្រាវធ្វើការប្រជុំពិភាក្សាជាមួយក្រុមកាងារ NCHADS HIV Prevention Study នៅមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

- រៀងរាល់ថ្ងៃសុក្រ ធ្វើការប្រជុំពិភាក្សាជាមួយក្រុមការងារ ទាក់ទងនឹងការរៀបចំមន្ទីរពិសោធន៍របស់ NCHADS HIV Prevention Study ប្រជុំពិភាក្សាជាមួយលោកស្រី Kimberly Page Shafer នៅមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ។

**៩. សកម្មភាពផ្សេងៗ :**

- មន្ត្រីផ្នែកស្រាវជ្រាវ បានរៀបចំការងារ ជាមួយមណ្ឌលសុខភាពទួលស្វាយព្រៃ និងក្រុមវិស្វករសំណង់ ដើម្បីធ្វើការកែប្រែ លើការជួសជុលគ្លីនិកសំរាប់ព្យាបាលជំងឺអេដស៍។
- រៀបចំផែនការសំរាប់ធ្វើ Meeting Forum, IEC material for Stakeholders , Training staff for Formative Research NCHADS HIV Prevention Study.
- រៀបចំធ្វើលិខិតអញ្ជើញអង្គការ និងស្ថាបន័នានា មកចូលរួមក្នុងវេទិកាសហគមន៍ របស់ NCHDS HIV Prevention Study.
- រៀបចំបកប្រែសេចក្តីផ្សាយជ្រើសរើសបុគ្គលិករួចធ្វើការផ្សព្វផ្សាយតាមរយៈកាសែតរស្មីកម្ពុជា
- បានទទួលពាក្យសុំការងារធ្វើរបស់បេក្ខជន និងបេក្ខនារីទាំងឡាយ និង រៀបចំតារាងរបស់បេក្ខជន បេក្ខនារី ដែលបានដាក់ពាក្យសុំធ្វើការទៅតាម Position និមួយៗ។
- រៀបចំទទួលគណប្រតិភូមកពី University of New Sought Wales and University of Califonia Sanfrancisco.
- រៀបចំផែនការបង្កើត Research Steering Committee. Sub Research Steering Committee.
- រៀបចំវេទិកាសហគមន៍ ដើម្បីផ្តល់យោបល់ដល់ NCHADS HIV Prevention Study និងដើម្បីបង្កើត Community advisory Group.
- មន្ត្រីផ្នែកស្រាវជ្រាវ ចូលរួមក្នុងការប្រកាសផ្សព្វផ្សាយលទ្ធផលនៃ Dissamination work shop of BSS 2003 ដែលរៀបចំឡើងដោយផ្នែកអង្កេតតាមដាន នៅសណ្ឋាគារសាន់វ៉េ
- ចូលរួមធ្វើការជាមួយផ្នែកអង្កេតតាមដាន និងផ្នែកពតិមានអប់រំ និង ទំនាក់ទំនង ដើម្បីបង្កើត Protocol សំរាប់ធ្វើ KAP Baseline survey.
- ធ្វើទំនាក់ទំនង ជាមួយបេក្ខជន បេក្ខនារីដែលមានឈ្មោះក្នុង Shot List ដើម្បីអញ្ជើញមកធ្វើការសំភាសន៍
- មន្ត្រីផ្នែកស្រាវជ្រាវ រួមជាមួយ Foreign Technical Advisors ផ្សេងទៀត បានសំភាសន៍បេក្ខជន និងបេក្ខនារី ទាំងឡាយ ដែលមានក្នុង Short List

- មន្ត្រីផ្នែកស្រាវជ្រាវ រៀបចំ Coordinate Training សំរាប់ CTAP Project and HIV Prevention study.

### ១.២.៥. ផ្នែកអង្កេតតាមដាន

**ក. កិច្ចប្រជុំ :**

ចូលរួមប្រជុំធ្វើគំរោងផែនការជាយុទ្ធសាស្ត្រ សំរាប់ឆ្នាំ ២០០៥-២០០៧ និងចូលរួមប្រជុំការងារ ច្ចេកទេសប្រចាំខែ

ចូលរួមប្រជុំក្នុងការរៀបចំបង្កើត Website សំរាប់មជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ ។

- ចូលរួមប្រជុំស្តីពី ការងារអង្កេតតានដានអត្រាប្រេវ៉ាឡង់របស់ជំងឺកាមរោគ ជាមួយអង្គការ FHI, CDC, NCHADS.
- ចូលរួមប្រជុំជាមួយផ្នែកបច្ចេកទេស ដើម្បីរៀបចំធ្វើគំរោងផែនការសកម្មភាព ប្រចាំឆ្នាំ ២០០៥
- ចូលរួមប្រជុំពិភាក្សាជាមួយលោក Guy Morineau តំណាងមកពី FHI និងលោកស្រី Joyle Neal តំណាងមកពី US-CDC ដើម្បីរៀបចំធ្វើពិធីសារនៃការ អង្កេតតាមដានរកអត្រាផ្ទុកជំងឺ កាមរោគ នៅឆ្នាំ២០០៤.
- ចូលរួមប្រជុំធ្វើផែនការ អង្កេតតាមដានរកអត្រាផ្ទុកជំងឺកាមរោគ ជាមួយតំណាងមកពីUS-CDC, FHI និងតំណាងមកពី ADB នៅសាលប្រជុំរបស់មជ្ឈមណ្ឌលជាតិ ។
- ចូលរួមប្រជុំស្តីពីការប្រើប្រាស់ថ្នាំ Tenofovir លើក្រុមនារីរកស៊ីផ្លូវភេទដោយផ្ទាល់
- ចូលរួមប្រជុំផ្សព្វផ្សាយលទ្ធផល ស្តីពីការអង្កេតស្រាវជ្រាវតាមមណ្ឌលសុខភាព នៅក្រសួងសុខាភិបាល និងវិទ្យាស្ថានជាតិសុខភាពសាធារណៈ ។
- ជួបប្រជុំពិភាក្សា ជាមួយលោក Guy Morineau តំណាងមកពី FHI អំពីរបាយការណ៍ស្តីពី ការអង្កេតតាមដានពីជំងឺអេដស៍ និងការប្រព្រឹត្តផ្លូវភេទលើកទី៥ និងលើកទី៦ ។
- មន្ត្រីចំនួន១រូប ចូលរួមប្រជុំដើម្បីរៀបចំធ្វើពិធីសារ នៃការអង្កេតតាមដានរកអត្រាផ្ទុកជម្ងឺកាមរោគ នៅឆ្នាំ ២០០៤

**ខ. វគ្គបណ្តុះបណ្តាល/សិក្ខាសាលា :**

- មន្ត្រីផ្នែកអង្កេតតាមដានចំនួន២រូប ចូលរួមជាគ្រូសំរបសំរួលវគ្គសិក្ខាសាលា សំរាប់អ្នកចុះធ្វើសំភាសន៍ ស្តីពី ការអង្កេតជាមូលដ្ឋាន នៃការកាត់បន្ថយជំងឺអេដស៍ នៅក្នុងតំបន់អភិវឌ្ឍន៍

ក្នុងនាមជាអ្នកអភិបាលការងារ ដែលរៀបចំឡើងដោយ World Vision Cambodia ដែលជាគំរោង HAHP / MAAP.

- ចូលរួមក្នុងវគ្គសិក្ខាសាលា ស្តីពីការរៀបចំផលិតសំភារៈសំរាប់អប់រំ ដែល រៀបចំឡើងដោយផ្នែកពត៌មាន អប់រំ និងទំនាក់ទំនង នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ អេដស៍ សើស្បែក និងកាមរោគ
- រៀបចំធ្វើការប្រកាសផ្សព្វផ្សាយលទ្ធផល ស្តីពីការអង្កេត ការប្រព្រឹត្តផ្លូវលើកទី៤ ឆ្នាំ ២០០៣ នៅសណ្ឋាគារ សាន់វ៉េ ដោយមានការចូលរួមពីមន្ត្រីគ្រប់ផ្នែករបស់មជ្ឈមណ្ឌលជាតិ មន្ទីរសុខាភិបាលខេត្ត-ក្រុងទាំង ២៤ ស្ថាប័នផ្សេងៗ និងអង្គការក្រៅរដ្ឋាភិបាលនានា ។
- ចូលរួមក្នុងវគ្គសិក្ខាសាលា ស្តីពីការវិភាគទិន្នន័យ ពីការធ្វើអង្កេតតាមបែបគុណភាព
- មន្ត្រីចំនួន២រូប ចូលរួមក្នុងសិក្ខាសាលា ស្តីពីការពិនិត្យឡើងវិញ NCHADS Strategy Plan 2004- 2007
- ចូលរួមក្នុងសិក្ខាសាលាស្តីពីការតាមដាន វាយតំលៃ និងរបាយការណ៍ នៅមជ្ឈមណ្ឌលជាតិ
- ចូលរួមក្នុងវគ្គសិក្ខាសាលា ស្តីពីការពិនិត្យឡើងវិញនៃគំរោងផែនការយុទ្ធសាស្ត្រ របស់មជ្ឈមណ្ឌលជាតិ និង ផ្លាស់ប្តូរបទពិសោធន៍ ស្តីពីការថែទាំបន្ត ពីស្រុកប្រតិបត្តិមោងឬស្សី ខេត្តបាត់ដំបង នៅវិទ្យាស្ថានជាតិ ស្រាវជ្រាវសុខភាពសាធារណៈ

**ត. ការងារអភិបាល :**

- ចុះអភិបាលការងារ ស្តីពីការអង្កេតជាមូលដ្ឋាន នៃការកាត់បន្ថយជំងឺអេដស៍ នៅក្នុងតំបន់អភិវឌ្ឍន៍ នៅខេត្ត កំពង់ស្ពឺ ខេត្តកណ្តាល ដែលរៀបចំឡើង ដោយអង្គការ World Vision Cambodia ដែលជាគំរោង HAHP / MAAP ។

**យ. សកម្មភាពផ្សេងៗ :**

- មន្ត្រីផ្នែកអង្កេតតាមដានបានធ្វើការប្រមូលទិន្នន័យដើម្បីត្រួតពិនិត្យសំណាកឈាមរកមេរោគ អេដស៍ នៅក្នុងប្រទេសកម្ពុជា ពីឆាំ ១៩៩៩ ដល់ឆ្នាំ ២០០២ ។
- រៀបចំធ្វើការវិភាគទិន្នន័យស្តីពីការអង្កេតឈាមរកអត្រាផ្ទុកមេរោគអេដស៍ ឆ្នាំ២០០៤
- រៀបចំកម្មវិធីបញ្ចូលទិន្ន័យ និងធ្វើការបញ្ចូលទិន្នន័យ ស្តីពីការអង្កេត ជាមូលដ្ឋាននៃការកាត់បន្ថយ ជម្ងឺអេដស៍ នៅក្នុងតំបន់អភិវឌ្ឍន៍ ក្នុងនាមជាអ្នកអភិបាលការងារសំភាសន៍ ដែលរៀបចំឡើងដោយអង្គការ World vision Cambodia ដែលជាគំរោង HAHP/MAAP

- រៀបចំឯកសារសំរាប់ប្រជុំផ្សព្វផ្សាយលទ្ធផលអង្កេតតាមដានចំណេះដឹងស្តីពីជម្ងឺអេដស៍ និងការប្រព្រឹត្ត ផ្លូវភេទ លើកទី ៦
- រៀបចំបង្កើតបណ្តាញ Website នៅក្នុងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និង កាមរោគ

## ១.២.៦. គ្លីនិកជាតិសើស្បែក និងកាមរោគ

### ក. ការពិនិត្យ និងព្យាបាលជម្ងឺ ( CONSULTATION AND TREATMENT ) :

| Disease | Dermatology | | STD | | Surgery | | HIV Cases follow up | |
|---|---|---|---|---|---|---|---|---|
| **Month** | Male | Female | Male | Female | Male | Female | Male | Female |
| **January** | 1472 | 1422 | 71 | 79 | 11 | 6 | 16 | 7 |
| **February** | 1121 | 1225 | 82 | 137 | 5 | 2 | 9 | 4 |
| **March** | 1446 | 1742 | 71 | 72 | 2 | 4 | 8 | 3 |

### ខ. មន្ទីរពិសោធន៍វេជ្ជសាស្ត្រ ( Laboratory ) :

- **Serology :**

| Test | RPR | | TPPA | | HBs-Ag | | HBs-Ab | | HCV-Ab | | HIV-Ab | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| **Month** | Total | + | Total | + | Total | + | Total | + | Total | + | Total | + |
| **January** | 144 | 4 | 18 | 5 | 56 | 4 | 55 | 12 | 55 | 4 | 183 | 28 |
| **February** | 182 | 4 | 17 | 6 | 67 | 3 | 68 | 12 | 66 | 6 | 222 | 29 |
| **March** | 199 | 4 | 10 | 3 | 53 | 7 | 51 | 10 | 53 | 3 | 234 | 32 |

- **Bacteriology**

| Method | Gram Stain | | | | Gen-Probe | | | Wet mount | |
|---|---|---|---|---|---|---|---|---|---|
| **Months** | GNID | PMNs >30 | Yeast | # of test | Gonorrhea | Chlamydia Trachomatis | # of test | Trichomonas | # of test |
| **January** | 18 | 12 | 29 | 78 | 3 | 2 | 67 | 0 | 51 |
| **February** | 8 | 2 | 47 | 103 | 1 | 0 | 67 | 1 | 80 |
| **March** | 11 | 23 | 22 | 283 | 4 | 0 | 95 | 1 | 67 |

- **VCCT**

| | Pretest Counseling | | Testing | | | | | | Posttest Counseling | |
|---|---|---|---|---|---|---|---|---|---|---|
| | Male | Female | Male | | | Female | | | Male | Female |
| | | | # of test | HIV + | % | # of test | HIV + | % | | |
| **January** | 151 | 119 | 130 | 26 | 20% | 98 | 30 | 31% | 99 | 80 |
| **February** | 236 | 201 | 209 | 37 | 18% | 178 | 26 | 15% | 178 | 159 |
| **March** | 143 | 108 | 143 | 41 | 29% | 108 | 27 | 25% | 133 | 93 |

**គ. ក្រុមគ្លីនិកចល័ត :**

- ក្រុមចល័តដែលមានគ្រូពេទ្យម្នាក់ និងបុគ្គលិកចំនួន២រូប បានសហការជាមួយអង្គការឱសថការីគ្មានព្រំដែន ចុះធ្វើការពិនិត្យព្យាបាល ស្ត្រីដែលប្រឈមមុខនិងគ្រោះថ្នាក់ឆ្លងមេរោគអេដស៏កាមរោគ នៅតាមចំណុច គោលដៅមួយចំនួនក្នុងរាជធានីភ្នំពេញ ។

**ឃ. សកម្មភាពបណ្តុះបណ្តាល និងបំប៉នចំណេះដឹង :**

- វគ្គសិក្ខាសាលាស្តីពីការពង្រឹងបច្ចេកទេសមន្ទីរពិសោធន៏ ដល់មន្ត្រីផ្នែកមន្ទីរពិសោធន៏នៅគ្លីនិកជាតិ និង មន្ត្រីមន្ទីរពិសោធន៏មកពីខេត្តកោះកុង ក្រុងព្រះសីហនុ ខេត្តព្រៃវែង។

- វគ្គសិក្ខាសាលាស្តីពីការពង្រឹងបច្ចេកទេសព្យាបាល ដល់មន្ត្រីផ្នែកពិនិត្យជំងឺនៅគ្លីនិកជាតិ និងមន្ត្រីគ្លីនិកកាម រោគ មកពីខេត្តបន្ទាយមានជ័យ កោះកុង ក្រុងព្រះសីហនុ និងខេត្តព្រៃវែង។
- ចូលរួមក្នុងកិច្ចប្រជុំស្តីពី Discussion on the draft Strategic Planning on VCCT 2003-2007.
- មន្ត្រីគ្លីនិកជាតិសើស្បែក និងកាមរោគពីររូប ចូលរួមក្នុងសិក្ខាសាលា ស្តីពីជម្ងឺហង់សិន នៅមជ្ឈមណ្ឌលជាតិ កំចាត់រោគរបេង
- មន្ត្រីគ្លីនិកជាតិសើស្បែកនិងកាមរោគ មួយរូបចូលរួមក្នុងកិច្ចប្រជុំ បង្ហាញបច្ចេកទេស ដោយប្រើកម្មវិធី Pedagogic@ ថ្មីកមពីសកលវិទ្យាល័យ Lyon នៅមហាវិទ្យល័យ វិទ្យាសាស្ត្រ សុខាភិបាល។

**៦. សកម្មភាពផ្សេងៗ :**

- លោកវេជ្ជ.ចាន់ វិចិត្រ ប្រធានគ្លីនិកជាតិ បានជួបសំភាសន៍ជាមួយក្រុមគំរោងសេវាផ្សព្វផ្សាយ អប់រំសុខភាព កម្ពុជានេមស៍ (CHEMS) ក្នុងកម្មវិធីពិសេសសំរាប់យុវវ័យ។

**បេសកកម្មក្រៅប្រទេស :**

- មន្ត្រីមជ្ឈមណ្ឌលជាតិចំនួន ១រូបអញ្ជើញទៅចូលរួមក្នុងសន្និសីទ ស្តីពីប្រពន្ធ័អង្កេតតាមដាន នៃ ជម្ងឺអេដស៍ នៅប្រទេសអេត្យូពី ពីថ្ងៃទី ២៤-៣១ ខែមករា ឆ្នាំ ២០០៤
- មន្ត្រីមជ្ឈមណ្ឌលជាតិចំនួន ៣រូប ចូលរួមក្នុងទស្សនៈកិច្ចសិក្សាស្វែងយល់ពី HIV Vaccine Trial and Microbicide នៅប្រទេសថៃ ពីថ្ងៃទី ២៣ -២៦ ខែកុម្ភៈ ឆ្នាំ ២០០៤
- មន្ត្រីមជ្ឈមណ្ឌលជាតិចំនួន ១រូប ចូលរួមក្នុង ARV Symposium នៅទីក្រុងបាងកក ប្រទេសថៃ ពីថ្ងៃទី០៩ -១០ ខែមករា ឆ្នាំ ២០០៤ ក្រោមការឧបត្ថម្ភរបស់អង្គការ ROCH
- មន្ត្រីមជ្ឈមណ្ឌលជាតិចំនួន ១រូប ចូលរួមក្នុងវគ្គសិក្សាផ្នែក Master of Clinical Tropical Medicine នៅ ប្រទេសថៃ ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៤ ដល់ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៥
- មន្ត្រីមជ្ឈមណ្ឌលជាតិ ចំនួន១រូប ចូលរួមក្នុងសិក្ខាសាលាស្តីពីការរៀបចំផែនការជម្ងឺអេដស៍ នៅទីក្រុងបាងកក ប្រទេសថៃ ពីថ្ងៃទី២៩ -៣១ ខែមិនា ឆ្នាំ ២០០៤ ។

## ២, សកម្មភាពការងារនៅថ្នាក់ខេត្ត

### ១. ខេត្ត បន្ទាយមានជ័យ

**១. កម្មវិធីអប់រំផ្ទាល់ និង មិត្តអប់រំមិត្ត**

- ការចុះអប់រំប្រចាំខែ របស់មន្ត្រីអប់រំផ្ទាល់ថ្នាក់ខេត្ត ដល់នារីបំរើផ្លូវភេទនៅតាមផ្ទះបន និងទីកន្លែង សេវាកំសាន្តសប្បាយនានាចំនួន ៥០កន្លែង អប់រំស្ត្រីបានចំនួនជាមធ្យម ២៩៥នាក់ ។
- រៀបចំការប្រជុំប្រចាំខែ ដល់ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត ដែលមានចំនួន ១១នាក់ ម្នាក់មកពីមន្ត្រីកម្ម វិធីប្រយុទ្ធនិងជម្ងឺអេដស៍
- រៀចំការប្រជុំក្រុមមិត្តអប់រំមិត្ត នៃក្រុមនារីរកស៊ីផ្លូវភេទដោយផ្ទាល់ និងដោយប្រយោល ចំនួន ២លើក ដែលមាន អ្នកចូលរួមចំនួន ៦១ នាក់ ក្នុងមួយលើកៗ។
- រៀបចំការប្រជុំប្រចាំត្រីមាសជាមួយម្ចាស់បន និងសេវាបំរើការកំសាន្តនានា មានការចូលរួមចំនួន ៥២នាក់ និងមន្ត្រីអប់រំផ្ទាល់ថ្នាក់ខេត្តចំនួន ១០នាក់ មន្ត្រីក្រុមការងារស្រោមអនាម័យ ១០០% ចំនួន ០៨នាក់ និងអ្នក ធ្វើមេអណ្តើកចំនួន ១១នាក់ ។

➢ **កម្មវិធីអប់រំផ្ទាល់ និង មិត្តអប់រំមិត្តនៅក្នុងសហគមន៍**

- រៀបចំការប្រជុំប្រចាំខែក្រុមមិត្តអប់រំមិត្ត ក្នុងសហគមន៍ ដោយអ្នកចូលរួមចំនួន ៨៨នាក់ មកពីឃុំបន្ទាយ នាង ចំនួន ២៩នាក់ , ឃុំប៉ោយប៉ែត ចំនួន ៣៤នាក់, ឃុំព្រះពន្លា ចំនួន ២៥នាក់ និងមន្ត្រីសុខាភិបាល ចំនួន ៣នាក់។
- ចុះធ្វើការអប់រំផ្សព្វផ្សាយ ដល់ក្រុមមិត្តអប់រំមិត្តប្រជាជនក្នុងសហគមន៍ ស្តីពីជម្ងឺអេដស៍/កាមរោគ ក្នុងឃុំប៉ោយប៉ែត ឃុំបន្ទាយនាង ឃុំព្រះពន្លា បានចំនួន ១២៨៥ ក្នុងខែមករា និងបានចំនួន១២៥៩ ភូមិក្នុងខែ កុម្ភៈ និងបានចំនួន ១៥៩៦ ភូមិក្នុងខែមិនា។

**៣. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%**

រៀបចំប្រជុំក្រុមការងារស្រោមអនាម័យ១០០% ប្រចាំសប្តាហ៍ ចំនួន ១២លើក ដែលមានអ្នកចូល រួមប្រជុំ ១៦ នាក់ក្នុង ១លើកៗ( មកពីស៊ីសុផុន ចំនួន ៦នាក់ អូរជ្រៅចំនួន ៦នាក់ ថ្មពួកចំនួន ២នាក់ មង្គលបូរីចំនួន ២នាក់ ) ។

**៤. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ**

- រៀបចំវគ្គសិក្ខាសាលាស្តីពីការគ្រប់គ្រងជំងឺកាមរោគ និងការអភិបាលដល់មន្ត្រីសំរបសំរួល ផ្នែកថែទាំជំងឺកាមរោគ នៅថ្នាក់ស្រុកប្រតិបត្តិ ដែលមានសិក្ខាកាមចូលរួមចំនួន ២១ រូប មកពីស្រុកប្រតិបត្តិ៤។
- ចំនួនអ្នកជំងឺ និងស្ត្រីរកស៊ីផ្លូវភេទ ដែលមកពិនិត្យនៅគ្លីនិកកាមរោគៈ

| | ចំនួនប្រជាជនទូទៅ | ចំនួននារីរកស៊ីផ្លូវភេទ |
|---|---|---|
| ខែមករា | 145 | 204 |
| ខែកុម្ភៈ | 145 | 228 |
| ខែមិនា | 201 | 222 |

## ៥. កម្មវិធីថែទាំអ្នកជំងឺអេដស៍

- មន្ទីរសុខាភិបាលខេត្ត ជួយរៀបចំចាត់ចែង និងចំណាយទៅលើការបូជាសពអ្នកដែលស្លាប់ដោយសារ ជម្ងឺអេដស៍ ក្រីក្រ ចំនួន ៣នាក់ ក្នុងខែមករា ខែកុម្ភៈចំនួន ៩នាក់ និង ខែមិនាចំនួន១០នាក់ ។

✰ *ការបង្កាការចំលងពីម្តាយទៅកូន :*

- រៀបចំជួសជុលអាគារ PMTCT នៅប៉ោយប៉ែត
- សកម្មភាព PMTCT:

| Date | No of ANC | # of Women attended mother's class | # of Women got HIV testing | # of HIV (+) | # of Women received Nevirapine |
|---|---|---|---|---|---|
| Jan | 382 | 323 | 122 | 6 | 3 |
| Feb | 509 | 373 | 149 | 11 | 2 |
| March | 438 | 244 | 156 | 10 | 4 |

✰ *ការថែទាំអ្នកជំងឺក្នុងមន្ទីរពេទ្យ:* (Institutional Care)

- ផ្តត់ផ្គង់ឱសថព្យាបាលជម្ងឺឱកាសនិយម
- ផ្គត់ផ្គង់ចំណីអាហារដល់អ្នកជំងឺអេដស៍ ដែលក្រីក្រ សំរាកក្នុងមន្ទីរពេទ្យ
- ចំនួនអ្នកជំងឺអេដស៍សំរាកពេទ្យ

| | ចំនួនអ្នកជំងឺថ្មី | អ្នកជំងឺអេដស៍ ចាស់ | ចំនួនអ្នកជំងឺស្លាប់ | ចំនួនជំងឺសរុប |
|---|---|---|---|---|
| ខែមករា | ៣៩ | ៣៥ | ៣ | ៧៤ |
| ខែកុម្ភៈ | | | ៩ | ៨៨ |
| ខែមិនា | | | ១០ | ៩៦ |

*✰ការថែទាំអ្នកជំងឺនៅតាមផ្ទះ*

- ការធ្វើទស្សនៈកិច្ចសិក្សារដកស្រង់បទពិសេសាធន៍លើការងារថែទាំអ្នកជម្ងឺអេដស៍តាមផ្ទះ នៅខេត្ត កោះកុង ដោយមន្ត្រីមកម្មវិធីអេដស៍ចំនួន ៨រូប
- ការបញ្ជូនអ្នកជំងឺទៅ មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងមណ្ឌលធ្វើតេស្តឈាម ខែមករា មាន ចំនួន ១នាក់ ខែកុម្ភៈមានចំនួន ៣នាក់ ខែមិនា មានចំនួន ៥នាក់។
- រៀបចំកិច្ចប្រជុំប្រចាំត្រីមាស របស់ក្រុមថែទាំអ្នកជំងឺតាមផ្ទះ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងរៀបចំ ផែនការអនុវត្តន៍កម្មវិធីបន្ត ដែលមានចំនួន ១៦នាក់ចូលរួម និង ២នាក់មកពី មណ្ឌលថែទាំអ្នកជម្ងឺ អេដស៍គ្មានទីពឹង ០៥ នាក់មកពីកម្មវិធីប្រយុទ្ធនឹងជម្ងឺអេដស៍ ។

- ការផ្គត់ផ្គង់កញ្ចប់ថ្នាំ សំរាប់ថែរក្សាសុខភាព (Home Care Kit) អោយដល់អ្នកជំងឺអេដស៍ ក្រីក្រ ចំនួន៣៦ នាក់ ក្នុងខែមករា ចំនួន ៣៧នាក់ក្នុងខែកុម្ភៈ និងចំនួន ៤៧នាក់ក្នុងខែមិនា ។

*✰មណ្ឌលថែទាំអ្នកជម្ងឺអេដស៍គ្មានទីពឹង (Hospice Care Center)៖*

- ការផ្គត់ផ្គង់ចំណីអាហារ និងសំភារៈប្រើប្រាស់ ដល់អ្នកជំងឺអេដស៍ អ្នកផ្ទុកមេរោគអេដស៍ ដែល ក្រីក្រ គ្មានទីពឹង ចំនួន ៦នាក់ ក្នុងខែមករា ចំនួន ៥នាក់ក្នុងខែកុម្ភៈ ចំនួន ១នាក់ក្នុងខែមិនា នៅក្នុង មណ្ឌលថែទាំអ្នក ជំងឺអេដស៍ គ្មានទីពឹង (Hospice Care Center)។

*✰មណ្ឌល ផ្តល់ប្រឹក្សា ធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និង រក្សារការសំងាត់ :*

- កិច្ចប្រជុំប្រចាំត្រីមាស របស់ក្រុមអ្នកផ្តល់ប្រឹក្សា ចំនួន៤រូប ផ្នែកមន្ទីរពិសោធន៍ ចំនួន ៤រូប មន្ត្រីកម្មវិធីអេដស៍ ចំនួន ៤រូប និង ៣រូប មកពីការិយាល័យស្រុកប្រតិបត្តិ។

- រៀបចំកិច្ចប្រជុំប្រចាំខែ របស់បណ្តាញក្រុមអ្នកផ្ទុកមេរោគអេដស៍ ចំនួនចូលរួម ១០នាក់ ក្នុងខែ មករា, ២១នាក់ក្នុង ខែកុម្ភៈ និង ២៨នាក់ក្នុងខែមិនា។






☆ *កម្មវិធីរបេង/អេដស៍ :*

- ធ្វើការបញ្ជូនអ្នកផ្ទុកមេរោគអេដស៍ ឱ្យទៅធ្វើតេស្តរកមេរោគរបេង ដោយផ្នែកធ្វើតេស្តឈាមៈ

| | ចំនួនអ្នកផ្ទុកមេរោគអេដស៍ បញ្ជូនទៅពិនិត្យ រកមេរោគរបេង | ចំនួនអ្នកជំងឺដែលមាន របេង វិជ្ជមាន | |
|---|---|---|---|
| ខែមករា | ៤០ | ៥ | ១២.៥% |
| ខែកុម្ភៈ | ៩៤ | ៩ | ៩.៥ % |
| ខែមិនា | ៧៩ | ២ | ២.៥ % |
| សរុប | ២១៣ | ១៦ | ៧.៥% |

- ធ្វើការបញ្ជូនអ្នកជម្ងឺរបេង ទៅធ្វើតេស្តរកមេរោគអេដស៍ នៅមណ្ឌលធ្វើតេស្តឈាម

| | ចំនួនអ្នកជំងឺរបេង បញ្ជូនទៅពិនិត្យ រកមេរោគអេដស៍ | ចំនួនអ្នកជំងឺដែលមាន មេរោគអេដស៍ វិជ្ជមាន | |
|---|---|---|---|
| ខែមករា | ៣៤ | ២ | ៥.៨% |
| ខែកុម្ភៈ | ៣៥ | ៤ | ១១.៤ % |
| ខែមិនា | ៣៦ | ៥ | ១៣.៨ % |
| សរុប | ១០៥ | ១១ | ១០.៤% |

## ៦. ផែនការ និងការសំរបសំរួលកម្មវិធី

- រៀបចំកិច្ចប្រជុំប្រចាំខែ របស់ HACC ជាមួយ អង្គការនានា ដែលមានចំនួន ២៥នាក់ចូលរួម
- ការចុះអភិបាលរបស់ផ្នែកទាំង ៩នៃកម្មវិធីប្រយុទ្ធនឹងជម្ងឺអេដស៍ ដើម្បីពង្រឹងសកម្មភាពការងារ
- មន្ត្រីសុខាភិបាល ចំនួន ១០រូប បានបញ្ជូនទៅសិក្សាផ្នែកភាសាអង់គ្លេស និងកុំព្យូទ័រ ។

# ២. ខេត្ត បាត់ដំបង

## ១. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- ចុះអប់រំជារៀងរាល់ខែរបស់មន្ត្រីអប់រំផ្ទាល់ ដល់នារីបំរើសេវាផ្លូវភេទ នៅតាមផ្ទះបន និងទីកន្លែង កំសាន្តសប្បាយ ចំនួន ៥៥ផ្ទះ នៅស្រុកបាត់ដំបង និងស្រុកសង្កែ ។

| | ចំនួនសេវា | ចំនួនស្រី |
|---|---|---|
| ខែមករា | 95 | 605 |
| ខែកុម្ភៈ | 94 | 612 |
| ខែមិនា | 95 | 604 |

- រៀបចំការប្រជុំប្រចាំខែ ដល់ក្រុមមន្ត្រីអប់រំផ្ទាល់ថ្នាក់ខេត្ត ដែលមានសមាជិកចំនួន ១០រូប ។

## ២. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

- រៀបចំប្រជុំក្រុមការងារ ១០០% ប្រចាំសប្តាហ៍ ដែលមានអ្នកចូលរួមប្រជុំ ៦ នាក់ ។
- រៀបចំប្រជុំប្រចាំខែ របស់គណៈកម្មាការ តាមដាន និងវាយតំលៃ កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០% ដែលមួយលើកមានអ្នកចូលរួមប្រជុំ ចំនួន ៥នាក់ ។

## ៣. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

- ការពិនិត្យ និងព្យាបាលជំងឺកាមរោគនៅគ្លីនិកកាមរោគខេត្តបាត់ដំបង

| Date | Male (A) | Female (B) | DSW | IDSW | Total=A+B |
|---|---|---|---|---|---|
| 01/04 | 17 | 109 | 121 | 14 | 123 |
| 02/04 | 25 | 109 | 121 | 20 | 134 |
| 03/04 | 26 | 100 | 136 | 26 | 126 |

## ៤. កម្មវិធីថែទាំអ្នកជំងឺអេដស៍

- *ក្រុមថៃទាំអ្នកជំងឺអេដស៍តាមផ្ទះ*

ក្រុមថៃទាំអ្នកជំងឺអេដស៍បានស្រាវជ្រាវឃើញអ្នកជំងឺរ៉ាំរ៉ៃដែលជាមធ្យមក្នុងមួយខែមានប្រហែល ១៣០ នាក់ ហើយមានអ្នកជំងឺអេដស៍ប្រហែល ៤០ នាក់ ហើយក្រុមនេះក៏បានផ្តល់ថ្នាំសំរាប់ព្យាបាល ដល់អ្នក ជំងឺរ៉ាំរ៉ៃផងដែរ

➢ *ការធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងផ្តល់ប្រឹក្សា នៅមណ្ឌលធ្វើតេស្តឈាមបាត់ដំបង*

| Date | No of Male clients | | No of Female clients | | Total |
|---|---|---|---|---|---|
| | HIV (-) | HIV (+) | HIV (-) | HIV (+) | |
| January* | 225 | 48 | 190 | 42 | 415 |
| February | 144 | 24 | 107 | 31 | 251 |
| March | 137 | 46 | 135 | 32 | 272 |

*កំណត់ចំណាំ: នៅក្នុងខែមករា តួលេខសរុបទាំងពាមណ្ឌលធ្វើតេស្តឈាម (ទីរួមខេត្តបាត់ដំបង មោងឫស្សី និងនៅសំពៅលូន)*

➢ ការធ្វើតេស្តឈាម និងផ្តល់ប្រឹក្សានៅ មណ្ឌលធ្វើតេស្តឈាមមោងឫស្សី

| Date | No of Male clients | | No of Female clients | | Total |
|---|---|---|---|---|---|
| | HIV (-) | HIV (+) | HIV (-) | HIV (+) | |
| January | | | | | |
| February | 21 | 4 | 36 | 8 | 57 |
| March | 38 | 8 | 81 | 12 | 119 |

➢ ការធ្វើតេស្តឈាម និងផ្តល់ប្រឹក្សានៅ មណ្ឌលធ្វើតេស្តឈាមសំពៅលូន

| Date | No of Male clients | | No of Female clients | | Total |
|---|---|---|---|---|---|
| | HIV (-) | HIV (+) | HIV (-) | HIV (+) | |
| January | | | | | |
| February | 17 | 2 | 22 | 5 | 39 |
| March | 19 | 5 | 45 | 10 | 64 |

## ៥. ផែនការ និងការសំរបសំរួលកម្មវិធី

# ៣. ខេត្ត ព្រៃវែង

## ១. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- ការចុះអប់រំជារៀងរាល់ខែរបស់មន្ត្រីអប់រំផ្ទាល់ថ្នាក់ខេត្ត ដល់នារីបំរើសេវាផ្លូវភេទ នៅតាមផ្ទះបន និងនៅតាមទីកន្លែងកំសាន្តសប្បាយ ចំនួន ៥៦ហាង នៅព្រៃវែង មេបុណ្យ អ្នកលឿង
- រៀបចំការប្រជុំដល់ក្រុមមិត្តអប់រំមិត្តរបស់នារីបំរើសេវាផ្លូវភេទដោយផ្ទាល់និងដោយប្រយោល ចំនួន៧១ នាក់ នៅកំពង់លាវ មេបុណ្យ និងអ្នកលឿង ។
- ការចុះអភិបាលលើសកម្មភាពអប់រំផ្ទាល់របស់កម្មវិធីអេដស៍ខេត្ត នៅតាមស្រុកប្រតិបត្តិ ។
- រៀបចំការប្រជុំប្រចាំខែ ដល់ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត ដែលមានចំនួន ១៣នាក់ ។

## ២. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

- រៀបចំប្រជុំក្រុមការងារ ១00% ប្រចាំសប្តាហ៍ដែលមានអ្នកចូលរួមប្រជុំ ៥-៧ នាក់ក្នុងមួយលើក ។
- រៀបចំប្រជុំប្រចាំខែ របស់គណៈកម្មាការ តាមដាន និងវាយតំលៃ កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១00% ដែលមួយលើកមានអ្នកចូលរួមប្រជុំ ចំនួនពី ១៤នាក់ ។
- ទិញស្រោមអនាម័យ សំរាប់ផ្គត់ផ្គង់ក្នុងកម្មវិធីចុះអប់រំផ្ទាល់ គ្លីនិកកាមរោគ និង មណ្ឌលធ្វើតេស្តឈាម ។

## ៣. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

- ការចុះអភិបាលរបស់ផ្នែកជំងឺកាមរោគខេត្ត ទៅកាន់ស្រុកប្រត្តិបត្តិព្រះស្តេច កំពង់ត្របែក មេសាង កំចាយ មារ អ្នកលឿង និងមណ្ឌលសុខភាព ដែលបានផ្តល់សេវាព្យាបាល ជំងឺកាមរោគ ។
- ធ្វើការពិនិត្យ និងព្យាបាលដល់ស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់ និងប្រយោល ជារៀងរាល់ខែ នៅស្រុកស្វាយ អន្ទរ និងមេបុណ្យ តាមរយៈក្រុមគ្លីនិកកាមរោគចល័ត ។

Coverage of SWs in Kampong Leav STD clinic

| Date | No of SWs register by CUWG | No of SWs attended in STD clinic | Coverage |
|---|---|---|---|
| January | 73 | 52 | 71% |
| February | 66 | 57 | 86% |
| March | NA | NA | NA |

Coverage of SWs in Neak Loeung STD clinic

| Date | No of SWs register by CUWG | No of SWs attended in STD clinic | Coverage |
|---|---|---|---|
| January | 77 | 58 | 75% |
| February | 77 | 65 | 84% |
| March | NA | NA | NA |

## ៤. កម្មវិធីថែទាំអ្នកជំងឺអេដស៍

*១. ក្រុមគាំទ្រដល់អ្នកជំងឺអេដស៍ :*

- ចុះថែទាំ និងលើកទឹកចិត្ត ដល់អ្នកជំងឺអេដស៍ នៅតាមសហគមន៍ នៅមណ្ឌលសុខភាព កំពង់លាវ ពពឺស ព្រែកឈ្លើង ព្រែកខ្សាយ ព្រែកអ្នកលឿង និងពាមរក៍។

| | ម. កពង់លាវ | ម. ពពឺស | ម. ព្រែកឈ្លើង | ម. ព្រែកខ្សាយខ | ម. ព្រែកអ្នកលឿង | ម. ពាមរមក៏ |
|---|---|---|---|---|---|---|
| ខែមករា | ២៧នាក់ | ១៨ នាក់ | ១៤ នាក់ | ១២ នាក់ | ១១ នាក់ | ៩ នាក់ |
| ខែកុម្ភៈ | ១៦ នាក់ | ១១ នាក់ | ២១ នាក់ | ៣៦ នាក់ | ២៥ នាក់ | ១៣ នាក់ |
| ខែមិនា | | | | | | |

*២. ការថែទាំអ្នកជំអឺនៅក្នុងមន្ទីរពេទ្យ:*

- ប្រជុំប្រចាំខែរបស់គណៈកម្មការថែទាំនិងព្យាបាលបន្ត នៅស្រុកប្រតិបត្តិ អ្នកលឿងនិងព្រៃវែង
- ចុះអភិបាលលើកម្មវិធីថែទាំអ្នកជំងឺនៅក្នុងមន្ទីរពេទ្យ អ្នកលឿង និងមន្ទីរពេទ្យខេត្ត របស់មន្ត្រីកម្មវិធីអេដស៍ ខេត្ត។

*៣. ការថែទាំអ្នកជំងឺនៅតាមផ្ទះនិងតាមសហគមន៍:*

- រៀបចំវគ្គសិក្ខាសាលា ចំនួន២វគ្គ ស្តីពីការថែទាំអ្នកជំងឺអេដស៍ នៅតាមផ្ទះ និងតាមសហគមន៍ ដល់ក្រុម ថែទាំអ្នកជំងឺអេដស៍តាមផ្ទះ ចំនួន ៥០ នាក់។
- ផ្គត់ផ្គង់ឱសថសំរាប់ថែទាំអ្នកជំងឺអេដស៍
- ចុះអភិបាលលើការងារថែទាំអ្នកជំងឺអេដស៍ នៅមណ្ឌលសុខភាពកំពង់លាវ ពពឺស ព្រែកឈ្លើង ព្រែកខ្សាយ ព្រែកអ្នកលឿង និងពាមរក៍។

- កិច្ចប្រជុំប្រចាំខែនៃបណ្តាញក្រុមការងារថែទាំអ្នកជំងឺអេដស៍ដែលមានអ្នកចូលរួមចំនួន៧៨នាក់ មកពីមណ្ឌល សុខភាពកំពង់លាវ ពពឺស ព្រៃកណ្តៀង ព្រៃកខ្សាយ ព្រៃកអ្នកលឿង និងពាមរក៏ ។

*៤. ការផ្តល់ប្រឹក្សា ធ្វើតេស្តឈាមដោយស្មគ្រ័ចិត្ត និងរក្សាការសំងាត់:*

- Monthly VCCT caseload in Kampong Leav VCCT

| Date | No of Male clients | | No of Female clients | | Total | HIV (+) |
|---|---|---|---|---|---|---|
| | HIV (+) | HIV (-) | HIV (+) | HIV (-) | | |
| January | 17 | 39 | 15 | 42 | 113 | 32 |
| February | 24 | 40 | 16 | 50 | 140 | 40 |
| March | NA | NA | NA | NA | NA | NA |

- Monthly VCCT caseload in Neaak LoeungVCCT

| Date | No of Male clients | | No of Female clients | | Total | HIV (+) |
|---|---|---|---|---|---|---|
| | HIV (+) | HIV (-) | HIV (+) | HIV (-) | | |
| January | 13 | 33 | 5 | 19 | 70 | 18 |
| February | 12 | 37 | 14 | 41 | 104 | 26 |
| March | NA | NA | NA | NA | NA | NA |

## ៥. ផែនការ និងការសំរបសំរួលកម្មវិធី

បុគ្គលិកកម្មវិធីអេដស៍ចំនួន ៦នាក់ ត្រូវបានបញ្ជូនអោយទៅរៀនភាសាអង់គ្លេស ។

# ៤, ខេត្ត ស្វាយរៀង

## ១. ពត៌មានអប់រំ និងទំនាក់ទំនង មហាជន

- ការផ្សព្វផ្សាយតាមប្រព័ន្ធទូរទស្សន៍ខ្សែកាបនូវពត៌មាន ស្តីពីជំងឺអេដស៍ កាមរោគ រឿង " សែនអនិច្ចា និងរឿង " ពេលដែលកន្លង " ។

## ២. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- ការចុះអប់រំជារៀងរាល់ខែរបស់មន្ត្រីអប់រំផ្ទាល់ថ្នាក់ខេត្ត ដល់នារីបំរើសេវាផ្លូវភេទ នៅតាមផ្ទះបន និងនៅ តាមទីកន្លែងកំសាន្តសប្បាយចំនួន៨កន្លែង និងដល់ក្រុមរាជអាវុធហត្ថ នៅក្នុងស្រុក ស្វាយរៀង

| | SWs | PM |
|---|---|---|
| ខែមករា | 108 | 0 |
| ខែកុម្ភៈ | 129 | 0 |
| ខែមិនា | 103 | 61 |

- រៀបចំវគ្គសិក្ខាសាលា ស្តីពី ការពង្រឹងសមត្ថភាព ក្នុងការងារអប់រំពី ជំងឺអេដស៍ កាមរោគ ដល់មន្ត្រីអប់រំ ផ្ទាល់ថ្នាក់ខេត្តមន្ត្រីថ្នាក់សំរបសំរួលកម្មវិធីអេដស៍នៅថ្នាក់ស្រុកប្រតិបត្តិ ដែលមានអ្នកចូលរួមចំនួន ១២នាក់ ។
- រៀបចំវគ្គបណ្តុះបណ្តាលបំប៉ន ស្តីពីជំងឺអេដស៍ និងកាមរោគ ចំនួន ២វគ្គ រយៈពេល២ថ្ងៃ ដល់អ្នកអប់រំបន្ត នៃក្រុមនារីរកស៊ីផ្លូវភេទ នៅស្រុកស្វាយរៀង និងនៅបាវិត ដែលមានអ្នកចូលរួមចំនួន ២៨នាក់ ។
- រៀបចំវគ្គបណ្តុះបណ្តាលបំប៉ន ស្តីពីជំងឺអេដស៍ និងកាមរោគ ចំនួន ១វគ្គ រយៈពេល២ថ្ងៃ ដល់អ្នកអប់រំបន្ត នៃក្រុមរាជអាវុធហត្ថ ដែលមានអ្នកចូលរួមចំនួន ១៦នាក់ មកពី ៨ កងពលក្នុងទីរួមខេត្ត និង ៧ ស្រុក ។
- រៀបចំការប្រជុំ ២ដង ក្នុងមួយត្រីមាស ដល់ក្រុមមិត្តអប់រំមិត្តរបស់នារីបំរើសេវាផ្លូវភេទ បានចំនួន ២៤ នាក់ នៅស្វាយរៀង និង ៨នាក់ នៅបាវិត
- ប្រជុំក្រុមមិត្តអប់រំមិត្ត នៃក្រុមកងរាជអាវុធហត្ថចំនួន ១៦ នាក់ មកពី ៨ កងពល ក្នុងទីរួមខេត្ត និង ៧ ស្រុក

- ការចុះអភិបាលលើសកម្មភាពអប់រំផ្ទាល់របស់កម្មវិធីអេដស៍ខេត្ត នៅលើអារុំធហត្ថជាតិ ។
- រៀបចំការប្រជុំប្រចាំខែ ដល់ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត ដែលមានចំនួន ១៣នាក់ ។
- រៀបចំប្រជុំប្រចាំត្រីមាស ជាមួយម្ចាស់សេវាចំនួន ២៨ផ្ទះ នៅទីរួមខេត្តស្វាយរៀង និងបាវិត ។

## ៣. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

- រៀបចំប្រជុំក្រុមការងារ១០០% ប្រចាំសប្តាហ៍ ដែលមានអ្នកចូលរួមប្រជុំ ៨នាក់ ក្នុងមួយលើក
- រៀបចំប្រជុំប្រចាំខែ របស់គណៈកម្មាការ តាមដាន និងវាយតំលៃ កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០% ដែលមួយលើកមានអ្នកចូលរួមប្រជុំ ចំនួន ១០នាក់ ។
- ការចុះអភិបាលរបស់ក្រុមតាមដាន និងវាយតំលៃ លើសកម្មភាពការងារ របស់ក្រុមការងារស្រោម អនាម័យ១០០% ចំនួន២លើក នៅទីរួមខេត្តស្វាយរៀង និងនៅបាវិត ។

## ៤. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

- ការចុះអភិបាលរបស់ផ្នែកជំងឺកាមរោគខេត្ត ទៅកាន់ស្រុកប្រត្តិបត្តិ និងមណ្ឌលសុខភាព ដែលបានផ្តល់សេវា ព្យាបាលជំងឺកាមរោគ ។
- អត្រាគ្របដណ្តប់របស់គ្លីនិកកាមរោគ លើក្រុមនារីរកស៊ីផ្លូវភេទ

| Date | No of SWs register by CUWG | No of SWs attended in STD clinic | Coverage |
|---|---|---|---|
| January | NA | NA | NA |
| February | 27 | 22 | 81% |
| March | 29 | 22 | 76% |

- ក្រុមការងារព្យាបាលជំងឺកាមរោគចល័ត (STD Mobile Clinic) ដែលបានផ្តល់សេវាព្យាបាល និងថែទាំជំងឺ កាមរោគ ដល់នារីរកស៊ីផ្លូវភេទ នៅបាវិត ។

## ៥. កម្មវិធីថែទាំអ្នកជំងឺអេដស៍

*១. ការធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងផ្តល់ប្រឹក្សា:*

- ការចុះអភិបាលលើសកម្មភាពការងារនៅមណ្ឌលធ្វើតេស្តឈាមដោយស្ម័គ្រចិត្តការផ្តល់ប្រឹក្សា និងរក្សាការ សំងាត់ នៅ រមាសហែក និងនៅស្វាយរៀង
- ប្រជុំសំរបសំរួលប្រចាំត្រីមាស របស់បុគ្គលិកធ្វើតេស្តឈាម និងផ្តល់ប្រឹក្សា (រមាសហែក និងនៅស្វាយរៀង)

- ការធ្វើតេស្តឈាម និងផ្តល់ប្រឹក្សានៅ មណ្ឌលធ្វើតេស្តឈាមស្វាយរៀង

| Date | No of Male clients | | No of Female clients | | Total |
|---|---|---|---|---|---|
| | HIV (-) | HIV (+) | HIV (-) | HIV (+) | |
| January | 65 | 2 | 105 | 8 | 180 |
| February | 54 | 4 | 75 | 11 | 144 |
| March | 68 | 10 | 71 | 9 | 158 |

- ការធ្វើតេស្តឈាម និងផ្តល់ប្រឹក្សានៅ មណ្ឌលធ្វើតេស្តឈាមរមាសហែក

| Date | No of Male clients | | No of Female clients | | Total |
|---|---|---|---|---|---|
| | HIV (-) | HIV (+) | HIV (-) | HIV (+) | |
| January | 6 | 1 | 5 | 1 | 13 |
| February | 8 | 2 | 3 | 1 | 14 |
| March | 14 | 1 | 8 | 0 | 23 |

*២. ការថែទាំនៅតាមមន្ទីរពេទ្យ:*

- ប្រជុំប្រចាំខែនៃក្រុមការងារថែទាំអ្នកជំងឺអេដស៍ នៅក្នុងមន្ទីរពេទ្យបង្អែករមាសហែក
- ចុះអភិបាលលើសកម្មភាពការងារថែទាំអ្នកជំងឺអេដស៍នៅក្នុងមន្ទីរពេទ្យបង្អែករមាសហែក

*៣. ការថែទាំ និងព្យាបាលបន្ត :*

- ធ្វើទស្សនៈកិច្ចសិក្សា រយៈពេល៥ថ្ងៃ ដើម្បីដកស្រង់បទពិសោធន៍ស្តីពីការថែទាំ និងព្យាបាលបន្ត នៅស្រុកប្រតិបត្តិ មោងឫស្សី ដែលមានអ្នកចូលរួម ១០នាក់
- រៀបចំកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មាការថែទាំនិងព្យាបាលបន្តនៅមន្ទីរពេទ្យបង្អែក ស្វាយរៀង និងរមាសហែក ដែលមានអ្នកចូលរួម ១០នាក់

## ៦. ផែនការ និងការសំរបសំរួលកម្មវិធី

រៀបចំវគ្គសិក្ខាសាលា រយៈពេល៣ថ្ងៃ ស្តីពីការរៀបចំគំរោងផែនការប្រចាំឆ្នាំ ២០០៥ ដែលមានអ្នកចូលរួម២៩នាក់មកពី មន្ទីរសុខាភិបាលខេត្ត កម្មវិធីអេដស៍/កាមរោគ មន្ទីរ ពេទ្យបង្អែក ស្រុកប្រតិបត្តិ លេខាធិការដ្ឋានអេដស៍ខេត្ត ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត បុគ្គលិក មណ្ឌលធ្វើតេស្តឈាម គ្លីនិកកាមរោគ និងអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការងារប្រយុទ្ធនឹង ជំងឺអេដស៍នៅក្នុងខេត្ត។

# ៥. ខេត្ត កោះកុង

## ១. ពត៌មានអប់រំ និងទំនាក់ទំនង មហាជន

- ការផ្សព្វផ្សាយពតិមានស្តីពីជំងឺអេដស៍ កាមរោគ តាមប្រព័ន្ធទូរទស្សន៍ខ្សែកាបខេត្ត ដែលមួយខែ ចាក់ផ្សាយ ១៥លើក ដែលគ្របដណ្តប់បានស្រុកស្មាច់មានជ័យ និងស្រុកមណ្ឌលសីមា។
- ការផ្សព្វផ្សាយតាមកប៉ាល់រូយ៉ាល់ ពីកោះកុង ទៅក្រុងព្រះសីហនុ ស្តីពីជំងឺអេដស៍/កាមរោគ ជារៀងរាល់ខែ ដែលមួយជើងមានអ្នកដំណើរយ៉ាងតិច ៧០-៨០នាក់ ។

## ២. កម្មវិធអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- រៀបចំវគ្គសិក្ខាសាលារយៈពេល៣ថ្ងៃ ស្តីពីជំងឺអេដស៍ កាមរោគ ដែលមាននាក់ចូលរួមចំនួន ១៥នាក់ មកពីមន្ត្រីអប់រំផ្ទាល់ថ្នាក់ខេត្ត និងមន្ត្រីសំរបសំរួលកម្មវិធីអេដស៍នៅថ្នាក់ស្រុកប្រតិបត្តិ។
- រៀបចំវគ្គសិក្ខាសាលា ចំនួន២វគ្គ រយៈពេល៣ថ្ងៃ ស្តីពីជំងឺអេដស៍ កាមរោគ ដល់ក្រុមអ្នកអប់រំបន្ត នៃក្រុម នារីរកស៊ីផ្លូវភេទ ដោយផ្ទាល់ និងដោយប្រយោល ចំនួន២៥
- ការចុះអប់រំជារៀងរាល់ខែរបស់មន្ត្រីអប់រំផ្ទាល់ចំនួន ១០នាក់ ដល់នារីបំរើសេវាផ្លូវភេទ នៅតាមផ្ទះបន និងនៅតាមទីកន្លែងកំសាន្តសប្បាយចំនួន ១១០កន្លែង ក្រុមម៉ូតូឌុប រថយន្តឈ្នួល អ្នករត់ទូកដរ និងក្រុមអ្នក នេសាទ នៅទីរួមខេត្ត និងស្រុកស្រែអំបិល។

| Date | SWs | Fisherman | Moto-taxi & Taxi driver |
|---|---|---|---|
| January | 322 | 220 | 180 |
| Febuary | 322 | 220 | 180 |
| March | 322 | 220 | 180 |

- រៀបចំការប្រជុំ២ដង ក្នុងមួយត្រីមាស ដល់ក្រុមមិត្តអប់រំមិត្ត បស់នារីបំរើសេវាផ្លូវភេទដោយផ្ទាល់ និង ប្រយាល
- រៀបចំការប្រជុំប្រចាំត្រីមាសជាមួយម្ចាស់សេវា ចំនួន ២៥នាក់ នៅស្រុកស្មាច់មានជ័យ និង ៨ នាក់ នៅស្រុក ស្រែអំបិល
- ការចុះអភិបាលលើសកម្មភាពអប់រំផ្ទាល់របស់កម្មវិធីអេដស៍ខេត្តនៅតាមស្រុកប្រតិបត្តិស្រែអំបិល។
- រៀបចំការប្រជុំប្រចាំខែ ដល់ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត ដែលមានចំនួន ១០ នាក់។

- រៀបចំកិច្ចប្រជុំសំរបសំរួល ដែលមានអ្នកចូលរួមចំនួន ១៥នាក់ មកពីមន្ត្រីអប់រំផ្ទាល់ក្រុមការងារស្រោម អនាម័យ ១00% និង អាជ្ញាធរដែនដី ។

## ៣. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

- រៀបចំប្រជុំក្រុមការងារ ១00% ប្រចាំសប្តាហ៍ ដែលមានអ្នកចូលរួមប្រជុំ ១0 នាក់ ក្នុងមួយលើក នៅស្រុក ស្វាច់មានជ័យ និងស្រែអំបិល ។
- សកម្មភាពចុះអភិលើកម្មវិធីប្រើប្រាស់ស្រោមអនាម័យនៅស្រុកស្រែអំបិល។
- ការទិញស្រោមអនាម័យ សំរាប់ផ្គត់ផ្គង់ដល់មន្ទីរពេទ្យបង្អែក គ្លីនិកកាមរោគ និងមណ្ឌលសុខភាព ។

## ៤. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

- ចូលរួមក្នុវគ្គបណ្តុះបណ្តាល រយៈពេល៥ថ្ងៃ ស្តីពីការគ្រប់គ្រងឱសថនិងថែទាំជំងឺកាមរោគនៅស្រុកប្រតិបត្តិ ស្រែអំបិល ដែលឧបត្ថមដោយអង្គការយែរ។
- ចូលរួមជាគ្រូសំរបសំរួលក្នុងវគ្គបណ្តុះបណ្តាល រយៈពេល៥ថ្ងៃ ស្តីពីការគ្រប់គ្រង និងថែទាំជំងឺកាមរោគ ដោយ ពឹងផ្អែកលើចង្កោមរោគសញ្ញា នៅស្រុកប្រតិបត្តិរែសអំបិល ដែលឧបត្ថមដោយ អង្គការយែរ។
- ចូលរួមក្នុងវគ្គសិក្ខាសាលាស្តីពីការប្រើប្រាស់ស្រោមអនាម័យ១00% និង សុខភាពបន្តពូជនៅមជ្ឈមណ្ឌល លើកកំពស់សុខភាព។
- ចូលរួមក្នុវគ្គបណ្តុះបណ្តាល រយៈពេល៥ថ្ងៃ ស្តីពី STI intensive នៅ គ្លីនិកជាតិ សើស្បែក និងកាមរោគ ។
- រៀបចំកម្មសិក្សា រយៈពេល៣ថ្ងៃ ចំនួន២វគ្គ ស្តីពីការគ្រប់គ្រង និងថែទាំជំងឺកាមរោគចំពោះនារីរក ស៊ីផ្លូវភេទ ដល់បុគ្គលិកគ្លីនិកកាមរោគស្រែអំបិល និងស្វាច់មានជ័យ ចំនួន១0រូប នៅគ្លីនិកកាមរោគ ក្រុងព្រះសីហនុ។
- ការចុះអភិបាលរបស់មន្ត្រីជំងឺកាមរោគខេត្ត ទៅកាន់គ្លីនិកកាមរោគស្រុកស្រែអំបិល
- ការចុះអភិបាលរបស់មន្ត្រីស្រុកប្រតិបត្តិទៅកាន់មណ្ឌលសុខភាពចំនួន៧ ដែលបានផ្តល់សេវាព្យាបាលជំងឺកាម រោគ នៅស្រុកប្រតិបត្តិស្រែអំបិល និងស្វាច់មានជ័យ។
- រៀបចំកិច្ចប្រជុំសំរបសំរួល ដែលមានអ្នកចូលរួមចំនួន ១០នាក់ មកពីស្រុកប្រតិបត្តិទាំង២ គ្លីនិកកាមរោគ មន្ត្រីកម្មវិធីអេដស៍ និង មន្ទីរសុខាភិបាល

## ៥. ការបង្ការ

- រៀបចំវគ្គបណ្តុះបណ្តាល រយៈពេល៣ថ្ងៃស្តីពីជំងឺអេដស៍ និងកាមរោគ និងការបង្ការ ដែលមានអ្នកចូលរួម ចំនួន ២០នាក់មកពី មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព

## ៦. កម្មវិធីថែទាំអ្នកជំងឺអេដស៍

*១.ការថែទាំអ្នកជំងឺអេដស៍ នៅក្នុងមន្ទីរពេទ្យ*

- រៀបចំកិច្ចប្រជុំសំរបសំរួល ដែលមានអ្នចូលរួមចំនួន១០នាក់មកពី មន្ទីរពេទ្យបង្អែក ស្រុកស្វាច់មានជ័យ

*២.ការថែទាំបន្ត:*

- រៀបចំកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មាការ សំរាប់ការថែទាំបន្ត ជំងឺអេដស៍មានចំនួន២៥ នាក់

*១. មណ្ឌលធ្វើតេស្តឈាមដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់*

- ចូលរួលកិច្ចប្រជុំ ស្តីពីការផ្លាស់ប្តូរបទពិសោធន៍ លើការផ្តល់ប្រឹក្សា នៅខេត្តបាត់ដំបង ដែលឧបត្ថម ដោយ អង្គការវ៉ៃរ
- មន្ត្រីផ្នែកធ្វើតេស្តឈាម ចំនួន ៤រូប ធ្វើកម្មសិក្សារយៈពេល៥ថ្ងៃនៅគ្លីនិកជាតិសើស្បែក និងកាមរោគ នៅ ក្រុងភ្នំពេញ

## ៦. ផែនការ និងការសំរបសំរួលកម្មវិធី

- បុគ្គលិកកម្មវិធីអេដស៍ចំនួន ៥នាក់ ត្រូវបានបញ្ជូនអោយទៅរៀនភាសាអង់គ្លេស ។
- ចូលរួមក្នុងវគ្គសិក្ខសាលា ស្តីពី Health Facility Assessment នៅក្រុងព្រះសីហនុ ដែលរៀបចំ ដោយ URC
- រៀបចំវគ្គសិក្ខាសាលាស្តីពី ការរៀបចំផែនការប្រចាំឆ្នាំ ២០០៥ ដែលមានអ្នកចូលរួមចំនួន ៤០នាក់មកពី ស្រុកប្រតិបត្តិទាំង២ មន្ត្រីអប់រំផ្ទាល់ ក្រុមការងារតាមដាន និងវាយតំលៃ ក្រុមការងារស្រោមអនាម័យ ១០០% និង អង្គការជាដៃគូ។

# ៦. ខេត្ត កំពង់ចាម

## ១. ពត៌មានអប់រំ និងទំនាក់ទំនង មហាជន

- ការផ្សព្វផ្សាយពតិមាន ស្តីពីជំងឺអេដស៍/កាមរោគ តាមប្រព័ន្ធវិទ្យុ 92.5 MHz ជាប្រចាំ មានចំនួន ៤៥ដង ក្នុងមួយខែ គ្របដណ្តប់បាន ៧០% ទូទាំងខេត្ត និងតាមទូរទស្សន៍ខ្មែរកាប ចំនួន ៣០ដង ក្នុង ១ខែ ទូទាំងស្រុកកំពង់ចាម

## ២. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- ការចុះអប់រំប្រចាំខែរបស់ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត ដល់នារីបំរើសេវាផ្លូវភេទដោយផ្ទាល់ និងដោយប្រយោលនៅតាមផ្ទះបន និងនៅទីកន្លែងកំសាន្តសប្បាយ ចំនួន ៥០កន្លែង ដល់ក្រុមម៉ូតូឌុប ចំនួន ៣០កន្លែង និងដល់ ក្រុមអ្នករត់តាក់ស៊ីមានចំនួន១០កន្លែង។

| | ចំនួនស្ត្រីរកស៊ីផ្លូវភេទ | ចំនួនអ្នករត់មូតូឌុប | ចំនួនអ្នកបើកតាក់ស៊ី |
|---|---|---|---|
| ខែកុម្ភៈ | 50PE/50 កន្លែង | 468p/30 កន្លែង | 179p/10 កន្លែង |
| ខែមិនា | 90PE/90 កន្លែង | 384p/30 កន្លែង | 277p/10 កន្លែង |

- រៀបចំការប្រជុំ ក្រុមមិត្តអប់រំមិត្ត នៃក្រុមនារីរកស៊ីផ្លូវភេទដោយផ្ទាល់ ដែលមានអ្នកចូលរួម ចំនួន ៣៤នាក់ ក្នុងមួយលើក (២ដង/មួយត្រីមាស)
- រៀបចំការប្រជុំជាមួយម្ចាស់សេវាបំរើផ្លូវភេទនិងសេវាកំសាន្តសប្បាយនានា ចំនួន ១ដង ក្នុងត្រីមាស ទី១ ដែលមានអ្នកចូលរួមចំនួន ៦៤នាក់
- រៀបចំការប្រជុំប្រចាំខែ ដល់ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត ដែលមានអ្នកចូលរួមចំនួន ១០នាក់
- រៀបចំធ្វើផែនទីកំណត់ទីតាំងបំរើសេវាផ្លូវភេទនិងសេវាកំសាន្តសប្បាយនានា

| | ចំនួនសេវា | ចំនួនស្រី |
|---|---|---|
| ផ្ទះបន | ៣២ ផ្ទះ | ១៣១ នាក់ |
| ស្រាបៀរ | ៨កន្លែង | ១២២ នាក់ |
| ម៉ាស្សា មានខារ៉ាអូខេ | ១៤ កន្លែង | |
| ភោជនីយដ្ឋានគ្រឿងក្លែម មានខារ៉ាអូខេ | ៣ កន្លែង | ២០ នាក់ |
| ភោជនីយដ្ឋាន គ្រឿងក្លែម មាននារីកំដរ | ៩ កន្លែង | ៦០ នាក់ |
| សណ្ឋាគារ មានម៉ាស្សា និង ខារ៉ាអូខេ | ២ កន្លែង | ៥៧ នាក់ |

- រៀបចំវគ្គបណ្តុះបណ្តាល រយៈពេល ៣ថ្ងៃ ស្តីពីជម្ងឺអេដស៍ /កាមរោគដល់មន្ត្រីអប់រំផ្ទាល់ថ្នាក់ខេត្ត និងមន្ត្រី សំរបសំរួលថ្នាក់ស្រុកប្រតិបត្តិ
- ការអភិបាលចំនួន ១ដង របស់មន្ត្រីកម្មវិធីអេដស៍ខេត្ត លើការងារអប់រំផ្ទាល់ ។

## ៣. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

- រៀបចំប្រជុំក្រុមការងារ១00%ប្រចាំសប្តាហ៍ ដែលមានអ្នកចូលរួមប្រជុំ ៧នាក់ ក្នុងមួយលើក
- រៀបចំកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មាការតាមដាននិងវាយតំលៃកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១00% ដែលមួយលើកមានអ្នកចូលរួមប្រជុំ ចំនួនពី ៦-៨ នាក់ ។
- ទិញស្រោមអនាម័យផ្គត់ផ្គង់ដល់កម្មវិធីអប់រំផ្ទាល់ គ្លីនិកកាមរោគ និងមណ្ឌលធ្វើតេស្តឈាម ។

## ៤. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

- រៀបចំវគ្គបណ្តុះបណ្តាលរយៈពេល៥ថ្ងៃ ស្តីពីការគ្រប់គ្រងនិងព្យាបាលជម្ងឺកាមរោគ សំរាប់មន្ត្រីស្រុកប្រតិបត្តិ ចំនួន ១០ សិក្ខាកាមចូលរួមចំនួន ២១នាក់
- ការចុះអភិបាលការងាររបស់ផ្នែកជំងឺកាមរោគស្រុកប្រត្តិបត្តិ ទៅមណ្ឌលសុខភាពដែលបានផ្តល់សេវាព្យាបាល ជំងឺកាមរោគ
- ការចុះអភិបាលការងាររបស់ផ្នែកជំងឺកាមរោគខេត្ត ចំនួន២រូប ទៅស្រុកប្រត្តិបត្តិ ដែលបានផ្តល់សេវាថៃទាំ ជំងឺកាមរោគ រៀងរាល់ត្រីមាស ។

- Monthly STI caseload in STD clinic

| Date | Male clients (A) | Female clients (B) | Partner | DSWs | IDSWs | Total A & B |
|---|---|---|---|---|---|---|
| January | 11 | 33 | 10 | 128 | 6 | 44 |
| February | 18 | 17 | 9 | 133 | 12 | 35 |
| March | 20 | 43 | 15 | 121 | 9 | 63 |
| **Total** | **49** | **93** | **34** | **382** | **27** | **142** |

- Coverage of STD clinic

| Date | No of SWs register by CUWG | No of SWs attended in STD clinic | Coverage |
|---|---|---|---|
| January | 112 | 128 | 114% |
| February | 136 | 133 | 98% |
| March | 123 | 121 | 98% |

## ៥. កម្មវិធីថែទាំអ្នកជំងឺអេដស៍

- ប្រជុំបង្កើតគណៈកម្មការសំរបសំរួលការថែទាំព្យាបាលបន្តអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ ចំនួ ២លើក អ្នកចូលរួមមកពី DAC, OD, RH, PAO, NGOs, PLHA, ចំនួន ២៦នាក់ ។
- បោះពុម្ព Referral Directory ចំនួន ២៥០ក្បាល ដើម្បីចែកជូនដល់ ស្ថាប័ន ឬអង្គការជាដៃគូធ្វើការនៅ ក្នុងខេត្ត

## ៦. ផែនការ និងការសំរបសំរួលកម្មវិធី

- បុគ្គលិកកម្មវិធីអេដស៍ចំនួន ១៤នាក់ ត្រូវបានបញ្ជូនអោយទៅសិក្សាកុំព្យូទ័រ
- រៀបចំការប្រជុំសំរបសំរួលរវាងមន្ត្រីកម្មវិធីប្រយុទ្ធនឹងជម្ងឺអេដស៍មន្ត្រីស្រុកប្រតិបត្តិជាមួយអង្គការ នានា ក្នុងត្រីមាសទី ១ អ្នកចូលរួមចំនួន៣០នាក់

# ៧. ខេត្ត កំពង់ឆ្នាំង

## ១. ពត៌មានអប់រំ និងទំនាក់ទំនង មហាជន

- ការផ្សព្វផ្សាយសារអប់រំជម្ងឺអេដស៍ កាមរោគ តាមរយៈទូរទស្សន៍ ខ្សែរកាបខេត្ត ចំនួន និង វិទ្យុខេត្ត ចំនួន ១0ដង ក្នុង ១ខែ

## ២. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- ការចុះអប់រំប្រចាំខែរបស់មន្ត្រីអប់រំផ្ទាល់ថ្នាក់ខេត្តចំនួន0២រូប ដល់នារីបំរើសេវាផ្លូវភេទដោយផ្ទាល់ និងដោយ ប្រយោល នៅតាមផ្ទះបន និងនៅទីកន្លែងកំសាន្តសប្បាយចំនួន 0៩លើក បាន ២៥កន្លែង ។

| ស្រុក | DSWs | | IDSWs | |
|---|---|---|---|---|
| | Brothels | SWs | Places | DSWs |
| ស្រុកកំពង់ឆ្នាំង | 15 | 64 | 26 | 56 |
| ស្រុករលៀប្បៀ | 4 | 9 | 5 | 2 |
| ស្រុកកំពង់ត្រឡាច | 2 | 10 | 0 | 0 |
| ស្រុកបរិបូរ | 4 | 15 | 2 | 3 |

- ក្រៅពីនេះកម្មវិធីប្រយុទ្ធ នឹងជំងឺអេដស៍/កាមរោគ ខេត្តបានរៀបចំការប្រជុំប្រចាំខែ ដល់ក្រុមអប់រំផ្ទាល់ ថ្នាក់ខេត្ត ៩នាក់(៨ នាក់ជាមន្ត្រីក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត និងម្នាក់ជាមន្ត្រីកម្មវិធីអេដស៍ ) ។
- រៀបចំកិច្ចប្រជុំរបស់ក្រុមមិត្តអប់រំមិត្តនៃក្រុមនារីរកស៊ីផ្លូវភេទដោយផ្ទាល់ និងដោយប្រយោល ចំនួន២លើក ដែលមានអ្នកចូលរួមចំនួន ៤៥នាក់ក្នុងមួយលើកៗ ដែលឧបត្ថមដោយអង្គការ FHI
- ប្រជុំម្ចាស់សេវាកំសាន្តសប្បាយ ដែលមានអ្នកចូលរួមចំនួន ៣៥នាក់ ដែលឧបត្ថមដោយអង្គការ FHI
- រៀបចំវគ្គបណ្តុះបណ្តាលបំប៉ន រយៈពេល៣ថ្ងៃ ស្តីពីការពង្រឹងសមត្ថភាព ដល់មន្ត្រីមកពីក្រុមអប់រំផ្ទាល់ថ្នាក់ ខេត្ត ក្រុមការងារស្រោមអនាម័យ១00% គ្លីនិកកាមរោគ ដែលឧបត្ថមដោយអង្គការ CESVI

## ៣. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

រៀបចំប្រជុំក្រុមការងារ១០០%ប្រចាំសប្តាហ៍ បានចំនួន ០៩ លើកដែលមានអ្នកចូលរួម ប្រជុំចំនួន ១០ រូប (ដែលក្នុងនោះមានមន្ត្រីក្រុមការងារស្រោមអនាម័យចំនួន ៨រូប មន្ត្រីមក ពីស្រុកប្រតិបត្តិចំនួន០១រូប មន្ត្រី មកពីកម្មវិធីអេដស៍ចំនួន០១រូប)

**៤. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ**

- ការចុះអភិបាលលើការងារថែទាំនិងព្យាបាលជម្ងឺកាមរោគពីស្រុកប្រតិបត្តិទៅ មណ្ឌលសុខភាព បានចំនួន ២៩ និង ពីខេត្តទៅស្រុកប្រតិបត្តិទាំង២ បានចំនួន០២លើក។

**៥. កម្មវិធីថែទាំអ្នកជំងឺអេដស៍**

*១.ការថែទាំអ្នកជំងឺអេដស៍នៅតាមផ្ទះ:*

- ចូលប្រជុំជាមួយអង្គការទស្សនៈពិភពលោក ស្តីពីការរៀបចំបង្កើតក្រុមថែទាំអ្នកជំងឺ អេដស៍ចំនួន៤ ក្រុម
- ក្រុមអ្នកថែទាំអ្នកជំងឺអេដស៍បានចុះស្វែងរកនិងផ្តល់ការថែទាំ លើកទឹកចិត្តដល់អ្នកជំងឺ

| | ចំនួនអ្នកជំងឺអេដស៍ | ចំនួនអ្នកស្លាប់ |
|---|---|---|
| ខែមករា | 123 | 13 |
| ខែកុម្ភៈ | 121 | 03 |
| ខែមិនា | 127 | 04 |

- ចុះអភិបាលលើការងារថែទាំអ្នកជំងឺអេដស៍ តាមផ្ទះ បាន៧ដង។

*២. មណ្ឌលធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងផ្តល់ប្រឹក្សា:*

- ចុះពិនិត្យទីតាំងដើម្បីបង្កើតមណ្ឌលធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត នៅស្រុកប្រតិបត្តិកំពង់ ត្រឡាច

| | ចំនួនអតិថិជន | **HIV (+)** |
|---|---|---|
| ខែមករា | 119 | 17 |
| ខែកុម្ភៈ | 80 | 15 |
| ខែមិនា | 105 | 18 |

## ៦. ផែនការ និងការសំរបសំរួលកម្មវិធី

- ការរៀបចំកិច្ចប្រជុំប្រចាំខែ របស់កម្មវិធីប្រយុទ្ធជំងឺអេដស៍/កាមរោគ ខេត្ត
- បានបញ្ជូន មន្ត្រីចំនួន ៦រូប ទៅសិក្សាផ្នែកកំព្យូទ័រ និង ចំនួន ១៨រូប ទៅរៀនភាសាអង់គ្លេស
- ការប្រជុំអ្នកសំរបសំរួលថ្នាក់ស្រុកប្រតិបត្តិ ចំនួន ០១លើក អ្នកចូលរួមចំនួន០៨រូប
- រៀបចំសិក្ខាសាលាស្តីពីការធ្វើផែនការសកម្មភាពសំរាប់ ឆ្នាំ ២០០៥ ដែលមានអ្នកចូលរួមមកពីស្រុក ប្រតិបត្តិ មន្ត្រីកម្មវិធីអេដស៍ខេត្ត មន្ទីរសុខាភិបាលខេត្ត និងអង្គការជាដៃគូ
- ចូលរួមប្រជុំក្រុមប្រឹក្សាបច្ចេកទេស និងកិច្ចប្រជុំបច្ចេកទេស នៅមន្ទីរសុខាភិបាលខេត្ត
- ចូលរួមកិច្ចប្រជុំប្រចាំត្រីមាស របស់លេខាធិការដ្ឋានអេដស៍ខេត្ត ដែលមានអ្នកចូលរួមចំនួន ៤០នាក់ ដែលក្នុងនោះមាន២១នាក់មកពីលេខាធិការដ្ឋានអេដស៍ខេត្ត ៦នាក់ មកពី ការិយាល័យ អេដស៍ស្រុក ២ នាក់មកពី ការិយាល័យស្រុកប្រតិបត្តិ ១នាក់មកពីមន្ទីរសុខាភិបាលខេត្ត ១រូបមកពី មន្ទីរពេទ្យបង្អែក និង៩នាក់ មកពី អង្គការក្រៅរដ្ឋាភិបាលជាដៃគូ ដែលឧបត្ថមដោយអង្គការ ទស្សនៈពិភពលោក
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីអ្នកឧទ្ទេសនាមមេរោគអេដស៍ ជំងឺអេដស៍ នៅភ្នំពេញ ដែលរៀបចំដោយ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ចូលរួមកិច្ចប្រជុំលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំភូមិភាគពាយព្យនិងនិរតី រយៈពេល ៣ថ្ងៃ នៅ ក្រុងព្រះសីហនុ ដែលរៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

*ការងារសហការជាមួយអង្គការផ្សេងៗ*

- ចូលរួមប្រជុំជាមួយម្ចាស់រោងចក្រតំបាញ M&V ក្នុងខេត្ត សំរាប់ចុះអប់រំសុខភាព ជំងឺអេដស៍ កាមរោគ និងសុខភាពបន្តពូជ និងការចាក់ថ្នាំបង្ការ
- សហការជាមួយអង្គការ LWF រៀបចំវគ្គសិក្ខាសាលា រយៈពេល៣ថ្ងៃ ស្តីពីការពង្រឹងសមត្ថភាព ដល់ព្រះសង្ឃ តាអាចារ្យ នីងធម្មការស្រុក នៅស្រុកទឹកផុសដែលមាន អ្នកចូលរួម ២៣នាក់ ។
- សហការជាមួយអង្គការ LWF រៀបចំវគ្គសិក្ខាសាលា រយៈពេល៣ថ្ងៃ ស្តីពីការពង្រឹងសមត្ថភាព ដល់មិត្តអប់រំមិត្ត នៅស្រុកទឹកផុស ដែលមានអ្នកចូលរួម២៣នាក់
- សហការជាមួយអង្គការ LWF រៀបចំវគ្គសិក្ខាសាលា រយៈពេល៣ថ្ងៃ ស្តីពីការពង្រឹងសមត្ថភាព ដល់គណៈកម្មាការអេដស៍ស្រុក នៅស្រុកសាមគ្គីជ័យ ដែលមានអ្នកចូលរួម២០នាក់

សហការជាមួយអង្គការ LWF រៀបចំវគ្គសិក្ខាសាលា រយៈពេល៣ថ្ងៃ ស្ដីពីជំងឺអេដស៍ ដល់ព្រះសង្ឃ តាអាចារ្យ និងធម្មការស្រុក នៅស្រុកសាមគ្គីមានជ័យ ដែលមានអ្នកចូល រួម២៦នាក់ ។

## ៨. ខេត្ត កំពង់ស្ពឺ

### ១. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- ការចុះអប់រំប្រចាំខែក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត ដល់នារីបំរើសេវាផ្លូវភេទ នៅតាមគ្រឹះស្ថាន ចំនួន ៣៦ និងអប់រំ ស្ត្រីបានជមធ្យមចំនួន ១១៩ នាក់ ។
- រៀបចំការប្រជុំប្រចាំខែរបស់ក្រុមមន្ត្រីអប់រំផ្ទាល់ថ្នាក់ខេត្ត ដើម្បីពិនិត្យមើលលើការអនុវត្តន៍សកម្មភាព និង បូកសរុបការងារកន្លងមក
- រៀបចំគូផែនទីកំណត់ទីតាំងសេវាបំរើផ្លូវភេទ និងសេវាកំសាន្តសប្បាយនានាដើម្បីសំរួលក្នុងការងារ គ្រប់គ្រង របស់កម្មវិធី ។

### ៣. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

- រៀបចំប្រជុំក្រុមការងារ ១០០% ប្រចាំសប្ដាហ៏ ចំនួន ៣ក្រុម ក្នុងមួយក្រុមប្រជុំបានចំនួន ៤លើក ដើម្បីពិនិត្យលើកលើការងារគ្រប់គ្រងលើចំនួនសេវា និងចំនួនស្ត្រី និងធ្វើការសំរបសំរួល រាល់បញ្ហាដូចជាការអនុវត្តន៍លិខិតបទដ្ឋាននានារបស់ខេត្តនិងការប្រើប្រាស់ស្រោមអនាម័យ ១០០% ។

### ៤. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

- រៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីការគ្រប់គ្រង និងថែទាំជម្ងឺកាមរោគដោយពឹងលើចង្កោមរោគ សញ្ញាសំរាប់ សិក្ខាកាមមកពីមណ្ឌលសុខភាពចំនួន ២១នាក់ ។
- ការចុះអភិបាលរបស់ផ្នែកជំងឺកាមរោគខេត្ត ទៅកាន់ស្រុកប្រត្តិបត្តិចំនួន៣ ដែលបានផ្ដល់សេវា ព្យាបាល ជំងឺកាមរោគដោយបានធ្វើការកែលំអនូវរាល់ចំណុចខ្វះខាតនានា ។
- ផ្គត់ផ្គង់សំភារៈការិយាល័យសំរាប់គ្លីនិកកាមរោគ

### ៥. ផែនការ និងការសំរបសំរួលកម្មវិធី :

- ការឡើងមកទំនាក់ទំនងការងារ រវាងមន្ត្រីកម្មវិធីអេដស៍មន្ត្រីគណនេយ្យមន្ទីរសុខាភិបាលខេត្ត ជាមួយ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ
- ការផ្គត់ផ្គង់សំភារៈសំរាប់ការិយាល័យរបស់កម្មវិធីអេដស៍

## ៩. ខេត្ត កំពង់ធំ

### ១. ពត៌មានអប់រំ និងទំនាក់ទំនង មហាជន

- ការផ្សព្វផ្សាយតាមប្រព័ន្ធទូរទស្សន៍ ខ្សែកាបខេត្ត ជាប្រចាំស្តីពីជំងឺអេដស៍ ដែលក្នុងនោះមានចំនួន ៧ស្ពត ដែលមានចំនួន ២០លើក និងតាមប្រព័ន្ធវិទ្យុខេត្ត ចំនួន ០៣ស្ពត ចំនួន ២០លើក

### ២. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- ចុះគូផែនទី និងស្រង់ស្ថិតិស្ត្រី និងសេវាកំសាន្តសប្បាយ

| | No of brothels | No of entertainment | No of DSWs | No of IDSWs | Total of SWs |
|---|---|---|---|---|---|
| ស្រុកស្ទឹងសែន | 13 | 31 | 34p | 177p | 211p |
| ស្រុកបារាយណ៍ | 15 | 5 | 23p | 12p | 35p |
| ស្រុកស្ទោង | 4 | 5 | 7p | 25p | 32p |

- កម្មវិធីចុះអប់រំផ្ទាល់ ដល់នារីបំរើសេវាផ្លូវភេទដោយផ្ទាល់ និងដោយប្រយោល នៅតាមផ្ទះបន និង នៅទីកន្លែងកំសាន្តសប្បាយ នៅទីរួមខេត្ត និងស្រុកចំនួន ២ គឺ ស្រុកបារាយណ៍ និង ស្ទោង

| | No of places | No of SWs |
|---|---|---|
| ខែមករា | 74 | 278 |
| ខែកុម្ភៈ | 73 | 275 |
| ខែមិនា | 70 | 282 |

- រៀបចំការប្រជុំប្រចាំខែ ដល់ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត ចំនួន ០២លើកក្នុងត្រីមាសទី១ឆ្នាំ២០០៤។
- រៀបចំកិច្ចប្រជុំរបស់ក្រុមមិត្តអប់រំមិត្តនៃក្រុមនារីរកស៊ីផ្លូវភេទដោយផ្ទាល់ និងដោយប្រយោល ចំនួន២លើក ដែលមានអ្នកចូលរួមចំនួន ៥៩ នាក់ក្នុងមួយលើក១ ដែលឧបត្ថមដោយអង្គការ FHI

- ប្រជុំម្ចាស់សេវាកំសាន្តសប្បាយ ដែលមានអ្នកចូលរួមចំនួន ៥៣ នាក់ ដែលឧបត្ថមដោយអង្គការ FHI

## ៣. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

- រៀបចំប្រជុំក្រុមការងារ ១០០%ប្រចាំសប្តាហ៍ ដែលមានអ្នកចូលរួមប្រជុំពី ៨-១៣ នាក់ ក្នុងមួយ លើក២ ( ស្រុកស្ទឹងសែន ចំនួន ៨នាក់ ស្រុកបារាយណ៍ ចំនួន ៥នាក់ ) ។
- ប្រជុំប្រចាំខែ របស់ក្រុមការងារតាមដាន និងវាយតំលៃការប្រើប្រាស់ស្រោមអនាម័យ១០០% ដែលមានអ្នក ចូលរួមចំនួន១០នាក់

## ៤. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

- ការចុះអភិបាលរបស់ផ្នែកជំងឺកាមរោគខេត្ត ទៅកាន់ស្រុកប្រត្តិបត្តិទាំងពីរ ចំនួន ១លើក
- ការចុះអភិបាលរបស់ផ្នែកជំងឺកាមរោគស្រុកប្រតិបត្តិទៅកាន់មណ្ឌលសុខភាពដែលបាន ផ្តល់សេវា ព្យាបាលជំងឺកាមរោគ ចំនួន ២៤មណ្ឌលសុខភាព ក្នុងខែកុម្ភៈ និងចំនួន ១០ មណ្ឌលសុខភាព ក្នុង ខែមិនា ។

## ៥. ផែនការ និងការសំរបសំរួលកម្មវិធី

- ផ្តត់ផ្តង់លើតំលៃនៃការប្រើប្រាស់ប្រពន្ធ័ Email/Fax/Phone ដើម្បីសំរួល ដល់ការងារ ទំនាក់ទំនងជាមួយ ថ្នាក់ជាតិ ។
- បញ្ជូនមន្ត្រីកម្មវិធីប្រយុទ្ធនឹងជម្ងឺអេដស៍/កាមរោគ ចំនួន ០២រូប និងមន្ត្រីផ្នែកគណនេយ្យ ចំនួន ០១រូប បានបញ្ជូនទៅសិក្សាភាសាអង់គ្លេស និង ០២រូប ផ្នែកកុំព្យូទ័រ
- មន្ត្រី CUMEC ចំនួន ០២រូប និងមន្ត្រី CUWG ចំនួន ០៦រូប បានទៅធ្វើទស្សនៈកិច្ច ដកស្រង់បទពិសោធន៏ ចំនួន ០៣ថ្ងៃ នៅក្រុងព្រហសីហនុ អំពីការងារប្រើប្រាស់ស្រោមអនាម័យ ១០០% ។
- សហការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារកធ្វើការវាយតំលៃដើម្បីរៀបចំបង្កើតកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយ ទៅកូន ប្រតិភូចំនួន៩នាក់ បានទៅធ្វើទស្សនៈកិច្ចសិក្សាដើម្បីដកស្រង់បទពិសោធន៏ការងារ កម្មវិធី បង្ការ ការចំលង មេរោគអេដស៍ពីម្តាយទៅកូន រយៈពេល៥ថ្ងៃ នៅខេត្តស្វាយរៀង ។

# ១០. ខេត្ត កំពត

## ១. ពតិមានអប់រំ និងទំនាក់ទំនង មហាជន

- ការផ្សព្វផ្សាយជាប្រចាំ សារអប់រំស្តីពីជំងឺអេដស៍/កាមរោគ តាមប្រព័ន្ធទូរទស្សន៍ខ្សែកាប ចំនួន២ខ្សែ (តារាវីដេអូកម្ពុជា និង រស្មីដួងចន្ទ) ជារៀងរាល់ថ្ងៃ មួយថ្ងៃ៣ដង គឺនៅម៉ោង ៧ព្រឹក ម៉ោង ១២ថ្ងៃត្រង់ និងម៉ោង ៧.៣០ នាទីយប់ តាមប្រព័ន្ធវិទ្យុ 93.25 MHz ចំនួនបីថ្ងៃ ក្នុងមួយសប្តាហ៍ ដែលលើកយក សារមកចាក់ផ្សាយ ដូចជា ការប្រើប្រាស់ ស្រោមនាម័យ-បុរសជាស្ថាន ចំលងមេរោគអេដស៍ ។

## ២. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- កម្មវិធីចុះអប់រំផ្ទាល់ របស់ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត ចំនួន ៨រូប ដល់នារីបំរើសេវាផ្លូវភេទដោយផ្ទាល់ និងដោយប្រយោលនៅតាមផ្ទះបនចំនួន ១៣កន្លែង និងនៅទីកន្លែងកំសាន្តសប្បាយ ចំនួន១១កន្លែងក្នុងស្រុកប្រតិបត្តិ ចំនួន២ និងអប់រំស្ត្រី បានជាមធ្យមចំនួន១៣៣នាក់
- កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍/កាមរោគខេត្ត បានរៀបចំការប្រជុំប្រចាំខែ ដល់ក្រុមអប់រំផ្ទាល់ថ្នាក់ ខេត្ត ចំនួន ៧រូប ។
- រៀបចំកិច្ចប្រជុំម្ចាស់សេវាបំរើការសប្បាយផ្លូវភេទនិងសេវាកំសាន្តសប្បាយនានា រៀងរាល់ត្រីមាស ដោយមានការចូលរួមពីរដ្ឋអំណាចមូលដ្ឋាន ក្រុមការងារប្រើប្រាស់ស្រោមអនាម័យ ១០០% និងក្រុមអប់រំផ្ទាល់ថ្នាក់ ខេត្ត ដែលមានអ្នកចូលរួមចំនួន៣៨នាក់ ។
- រៀបចំកិច្ចប្រជុំក្រុមមិត្តអប់រំមិត្តនៃក្រុមនារីរកស៊ីផ្លូវភេទដោយផ្ទាល់និងដោយប្រយោល រយៈពេលមួយថ្ងៃ អ្នកចូលរួម ចំនួន ៣៦នាក់ ។
- រៀបចំវគ្គបណ្តុះបណ្តាលបំប៉ន ចំនួន ៣ថ្ងៃ ដល់ក្រុមការងារអប់រំផ្ទាល់ ចំនួន ៨រូប និងគ្លីនិកកាមរោគ ចំនួន ២នាក់ ។
- រៀបចំគូផែនទីកំណត់ទីតាំងសេវាបំរើការសប្បាយផ្លូវភេទ និងសេវាកំសាន្តសប្បាយនានា និងស្ថិតិ ចំនួនស្ត្រី នៅតាមទីកន្លែងនិមួយៗ ។

## ៣. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

- រៀបចំប្រជុំក្រុមការងារ ១០០% ប្រចាំសប្តាហ៍ ដែលមានអ្នកចូលរួមប្រជុំ ៧ នាក់ក្នុងមួយលើក

- រៀបចំប្រជុំប្រចាំខែ របស់គណៈកម្មាការ តាមដាន និងវាយតំលៃ នៅក្នុងកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០% ដែលមួយលើកមានអ្នកចូលរួមប្រជុំ ចំនួន ១៣នាក់ ( គណៈកម្មាការ តាមដាន និងវាយតំលៃ កម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០% ចំនួន៨នាក់ ក្រុមការងារស្រោមអនាម័យ ១០០% ចំនួន ៣នាក់ និងមន្ត្រីកម្មវិធីអេដស៍ ចំនួន ២រូប ។
- ការចុះអភិបាលរបស់មន្ត្រីកម្មវិធីអេដស៍លើការអនុវត្តន៍សកម្មភាពរបស់កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០% ។

## ៤. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងជំងឺកាមរោគ សំរាប់នារីរកស៊ីផ្លូវភេទដល់មណ្ឌលសុខភាព ដែលនៅ ជិតសេវាបំរើផ្លូវភេទ ចំនួន ២នាក់ ដែលមាន រយៈពេល ១០ថ្ងៃ ។
- ក្រុមការងារព្យាបាលជំងឺកាមរោគចល័ត (STD Mobile Clinic) ដែលបានផ្តល់សេវាព្យាបាល និង ថែទាំជំងឺកាមរោគ ដល់នារីរកស៊ីផ្លូវភេទ ចំនួន ៣៦ នាក់ នៅស្រុកឈូក
- ការចុះអភិបាលរបស់ផ្នែកជំងឺកាមរោគខេត្ត ទៅកាន់ស្រុកប្រត្តិបត្តិ និងមណ្ឌលសុខភាព ដែលបាន ផ្តល់សេវា ព្យាបាលជំងឺកាមរោគ ។
- ការរៀបចំប្រជុំសំរបសំរួល ជាមួយមន្ទីរសុខាភិបាលខេត្ត កម្មវិធីប្រយុទ្ធនឹង ជំងឺអេដស៍/កាមរោគ និងស្រុក ប្រត្តិបត្តិ លើការងារគ្រប់គ្រងជំងឺកាមរោគ ។

## ៥. កម្មវិធីថែទាំអ្នកជំងឺអេដស៍

*១. ការថែទាំអ្នកជំងឺអេដស៍បន្ត :*

រៀបចំកិច្ចប្រជុំ របស់គណៈកម្មការថែទាំ និងព្យាបាលបន្ត ដោយមានអ្នកចូលរួម ចំនួន១៣ នាក់ ។

## ៦. ផែនការ និងការសំរបសំរួលកម្មវិធី

- រៀបចំកិច្ចប្រជុំប្រចាំខែ របស់កម្មវិធីប្រយុទ្ធជំងឺអេដស៍/កាមរោគ ខេត្ត
- រៀបចំវគ្គសិក្ខាសាលា រយៈពេល៣ថ្ងៃ ស្តីពីការរៀបចំគំរោងផែនការ សំរាប់ឆ្នាំ ២០០៥ ដែលមានអ្នក ចូលរួមចំនួន ២០ នាក់ មកពី មន្ទីរសុខាភិបាលខេត្ត កម្មវិធីអេដស៍ ស្រុកប្រតិបត្តិទាំង ៤ និងអង្គការជាដៃគូ ។

បុគ្គលិកកម្មវិធីអេដស៍ចំនួន ២នាក់ ត្រូវបានបញ្ជូនអោយទៅរៀនភាសាអង់គ្លេស ។

# ១១, ខេត្ត កណ្តាល

## ១. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- ក្រុមការងារអប់រំផ្ទាល់ថ្នាក់ខេត្ត ចំនួន ១២រូប ចែកជា ០៦ក្រុម (ក្នុង ១ក្រុម មាន ០២រូប) ចុះធ្វើ ការអប់រំផ្ទាល់ ដល់នារីបំរើសេវាផ្លូវភេទដោយផ្ទាល់ និងដោយប្រយោល នៅតាមផ្ទះបន ចំនួន ៣៨ កន្លែង និងទីកន្លែងកំសាន្តសប្បាយ ចំនួន ៥៧ កន្លែង នៅស្រុកតាខ្មៅ និងស្រុកកៀនស្វាយ ។




- កម្មវិធីប្រយុទ្ធ នឹងជំងឺអេដស៍/កាមរោគខេត្ត បានរៀបចំការប្រជុំប្រចាំខែ ដល់ក្រុមអប់រំផ្ទាល់ថ្នាក់ ខេត្តដើម្បីដោះស្រាយបញ្ហា និងផលវិបាកដែលបានជួបប្រទះនៅក្នុងការងារ សមាជិកចូលរួម ចំនួន ១២នាក់ ។
- ការគូរផែនទីកំណត់ទីតាំងសេវាបំរើការសប្បាយផ្លូវភេទនិងសេវាកំសាន្តសប្បាយនានាក្នុងស្រុក កៀន ស្វាយ មានផ្ទះបនចំនួន ៣៣កន្លែង និងកន្លែងកំសាន្តសប្បាយចំនួន ៥៥កន្លែង ដើម្បីសំរួលដល់ ការ ងារគ្រប់គ្រង
- ការប្រជុំជាមួយម្ចាស់សេវារកស៊ីផ្លូវភេទក្នុងស្រុកកៀនស្វាយ បានចំនួន ២តំបន់ អ្នកចូលរួម ចំនួន ៩២ នាក់ ដែលឧបត្ថម្ភដោយអង្គការ FHI.
- ការប្រជុំជាមួយក្រុមមិត្តអប់រំមិត្ត ចំនួន ០១លើក នៅស្រុកកៀនស្វាយអ្នកចូលរួមចំនួន ៣៣នាក់ ដែល ឧបត្ថម្ភដោយអង្គការ FHI.

## ២. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

- រៀបចំប្រជុំក្រុមការងារ ១០០% ប្រចាំសប្តាហ៍តាមតំបន់ក្នុងស្រុកកៀនស្វាយ ដើម្បីដោះស្រាយបញ្ហាផ្សេងៗ ក្នុងនោះដែរ បានចុះស្ថិតិស្ត្រី ចំនួន ១០៨នាក់ និងបញ្ជូនស្ត្រីរកស៊ីផ្លូវភេទទៅពិនិត្យសុខភាព នៅគ្លីនិកកាមរោគ ឃុំក្បាលកោះ ចំនួន ៨២នាក់ ។
- រៀបចំប្រជុំប្រចាំខែ របស់គណៈកម្មាការ តាមដាន និងវាយតំលៃកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០% ដែលមួយលើកមានអ្នកចូលរួមប្រជុំ ចំនួន ១១នាក់ (CUMEC ០៤ នាក់, CUWG ០៤ នាក់, មន្ត្រីស្រុកប្រតិបត្តិចំនួន ០១នាក់ មន្ត្រីគ្លីនិកកាមរោគចំនួន ០២នាក់ ) ។
- ផ្គត់ផ្គង់ស្រោមអនាម័យចំនួន៣៣ប្រអប់ សំរាប់ប្រើប្រាស់ក្នុងគ្លីនិកកាមរោគ នៅឃុំក្បាលកោះ ស្រុកកៀន ស្វាយ និងមណ្ឌលផ្តល់ប្រឹក្សាធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សារការសំងាត់ ស្រុកស្អាង និង សំរាប់ក្រុម ការងារចុះអប់រំផ្ទាល់ ។
- ការចុះអភិបាលការងារគ្រប់គ្រងការប្រើប្រាស់ស្រោមអនាម័យ១០០%




## ៣. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

- ការចុះអភិបាលរបស់ផ្នែកជំងឺកាមរោគខេត្តទៅកាន់ស្រុកប្រតិបត្តិស្អាង កៀនស្វាយ និងមណ្ឌលសុខភាព ដែលមានផ្តល់សេវាព្យាបាលជំងឺកាមរោគ ។

- វគ្គបណ្តុះបណ្តាលបំប៉នស្តីពីគ្រប់គ្រង និងថែទាំព្យាបាលជម្ងឺកាមរោគ ដល់ស្ត្រីរកស៊ីផ្លូវភេទ នៅគ្លីនិកសុខភាពគ្រួសារ ឃុំក្បាលកោះស្រុកកៀនស្វាយ មន្ត្រីចូលរួមចំនួន ៥រូប ឧបត្ថម្ភដោយ អង្គការ FHI
- វគ្គបណ្តុះបណ្តាលបំប៉នស្តីពីគ្រប់គ្រង និងថែទាំព្យាបាលជម្ងឺកាមរោគ ដល់បុគ្គលិកមណ្ឌល សុខភាព ដែលមាន អ្នកចូលរួមមកពី ១៤មណ្ឌលសុខភាព

## ៤. *កម្មវិធីថែទាំអ្នកជំងឺអេដស៍ :*

☆ *មណ្ឌលផ្តល់ប្រឹក្សា ធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សារការសំងាត់:* (VCCT)

- ការចុះអភិបាលរបស់មន្ត្រីកម្មវិធីអេដស៍ នៅមណ្ឌលផ្តល់ប្រឹក្សា ធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សា រការសំងាត់ស្រុកស្អាង

☆ *ការថែទាំអ្នកជំងឺអេដស៍តាមផ្ទះ :* (Home Base Care)

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីកាថែទាំអ្នកជម្ងឺអេដស៍តាមផ្ទះ ៥ក្រុម ចំនួន ១៣នាក់ ស្រុកកណ្តាលស្ទឹង ២នាក់ ស្រុកកៀនស្វាយ ៤នាក់ ស្រុកអង្គស្នួល ៣នាក់ និងមន្ត្រីកម្មវិធីអេដស៍ ចំនួន ៤នាក់
- ការចុះអភិបាលការងារលើក្រុមថែទាំអ្នកជម្ងឺអេដស៍តាមផ្ទះ ចំនួន ០៤ក្រុម :
    - នៅស្រុកកណ្តាលស្ទឹង ចំនួន០២ក្រុម មានសមាជិកចំនួន ០៦នាក់ គ្របដណ្តប់លើអ្នកជម្ងឺ អេដស៍ ចំនួន៤០នាក់ និងមានអ្នកស្ម័គ្រចិត្តចំនួន ១០នាក់ ឧបត្ថម្ភដោយ អង្គការទស្សនៈ ពិភពលោកកម្ពុជា
    - ស្រុកអង្គស្នួល មាន១ក្រុម ចំនួន ៣នាក់ គ្របដណ្តប់លើអ្នកជម្ងឺអេដស៍ចំនួន៥៩នាក់ និងមាន អ្នកស្ម័គ្រចិត្ត ០១នាក់ ឧបត្ថម្ភដោយអង្គការទស្សនៈពិភពលោកកម្ពុជា
    - ស្រុកកៀនស្វាយ មាន១ក្រុម សមាជិកចំនួន ០៤នាក់ គ្របដណ្តប់លើអ្នកជម្ងឺចំនួន ១៤៣នាក់ និងមានអ្នកស្ម័គ្រចិត្តចំនួន ១០នាក់ឧបត្ថម្ភដោយ អង្គការទស្សនៈ ពិភពលោកកម្ពុជា
- វគ្គបណ្តុះបណ្តាលចំនួន៣វគ្គស្តីពីការបង្ការរោគឆ្លងក្នុងមជ្ឈដ្ឋានថែទាំនិងព្យាបាលជម្ងឺដល់មន្ត្រីមណ្ឌលសុខភាព ក្នុងស្រុកស្អាង ចំនួន ១៦នាក់ ដែលឧបត្ថម្ភដោយអង្គការ UNICEF.

## ៥. ផែនការ និងការសំរបសំរួលកម្មវិធី

- បុគ្គលិកកម្មវិធីអេដស៍ ត្រូវបានបញ្ជូនអោយទៅរៀន ភាសាអង់គ្លេស ចំនួន ៤នាក់

- រៀបចំវគ្គសិក្ខាសាលា ស្ដីពីការរៀបចំគំរោងផែនការសំរាប់ឆ្នាំ ២០០៥ ដែលមានអ្នកចូលរួម ចំនួន ២១នាក់ មកពីស្រុក ប្រតិបត្តិ ទាំង ៨ និងអង្គការនានាចំនួន ៦

**សកម្មភាពផ្សេងៗ :**

ចូលរួមជាមួយសមាគមឥន្ទ្រទេវី ចុះអប់រំដល់សិស្សានុសិស្ស នៅវិទ្យាល័យហ៊ុនសែនតា ខ្មៅស្ដីពី ជម្ងឺអេដស៍ និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន អ្នកចូលរួមចំនួន ៥០នាក់

## ១២. ក្រុងកែប

### ១. ពត៌មានអប់រំ និងទំនាក់ទំនង មហាជន

- ចាក់បញ្ចាំង ស្ពតអប់រំស្ដីពីជម្ងឺអេដស៍កាមរោគ តាមហាងការ៉ាអូខេ ចំនួន០៦កន្លែង ចំនួន ៣០ ដង ក្នុងមួយខែៗ

### ២. កម្មវិធីអប់រំផ្ទាល់នៅតាមសហគមន៍

- ការចុះអប់រំជាប្រចាំ របស់មន្ត្រីអប់រំផ្ទាល់ថ្នាក់ខេត្ត ដល់ក្រុមយុវជនក្រៅសាលា និងប្រជាជន ទូទៅក្នុង សហគមន៍ ដែលអប់រំបានចំនួន១៣៤ នាក់នៅក្នុងខែកុម្ភៈ និង ១៩៣ នាក់នៅក្នុង ខែមិនា។
- រៀបចំកិច្ចប្រជុំក្នុងត្រីមាសទី ១ ឆ្នាំ២០០៤ ជាមួយក្រុមមិត្តអប់រំមិត្ត ចំនួន៦០រូប

### ៣. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

- ការចុះអភិបាលរបស់ផ្នែកប្រយុទ្ធនឹងជំងឺកាមរោគក្រុងកែប ទៅកាន់មន្ទីរពេទ្យបង្អែកក្រុងកែប និង មណ្ឌល សុខភាចំនួន ៥។

### ៤. ផែនការ និងការសំរបសំរួលកម្មវិធី

បញ្ជូនមន្ត្រីកម្មវិធីអេដស៍ មួយនាក់រៀនផ្នែកភាសាអង់គ្លេស និង២នាក់ទៅសិក្សាផ្នែកកំព្យូទ័រ

# ១៣. ក្រុងប៉ៃលិន

## ១. ពត៌មានអប់រំ និងទំនាក់ទំនង មហាជន

- ការផ្សព្វផ្សាយតាមប្រព័ន្ធវិទ្យុFM 91.5 MHZរយៈពេល ៣០នាទី ស្តីពីសារអប់រំពីជំងឺអេដស៍/ កាមរោគ និងរឿងទណ្ឌកម្មស្នេហ៍ ចំនួន ២ដង ក្នុង១អាទិត្យ (ថ្ងៃអង្គារ និងថ្ងៃសុក្រ ) និងតាម ទូរទស្សន៍ខ្សែកាប ស្តីពីសារអប់រំពីជំងឺអេដស៍/កាមរោគ ១២ដង ក្នុង១ខែ។

## ២. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- រៀបចំធ្វើផែនទីកំណត់ទីតាំងសេវាបំរើការសប្បាយផ្លូវភេទ និងសេវាកំសាន្តសប្បាយនានា

| Date | Brothel | | Karaoke | | Hotel | | Guest house | | Massage | | Casino | | Total | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | No | Worker | No | Worker | No | Worker | No | Worker | No | Worker | No | Worker | No | Worker |
| 02/04 | 15 | 140 | 9 | 49 | 2 | 12 | 3 | 3 | 2 | 3 | 2 | 300 | 33 | 507 |
| 03/04 | 16 | 156 | 12 | 73 | 2 | 15 | 3 | 3 | 2 | 3 | 2 | 300 | 37 | 550 |

- ការចុះអប់រំប្រចាំខែ របស់ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត ដល់នារីបំរើសេវាផ្លូវភេទ នៅតាមផ្ទះបនចំនួន ១៥ ផ្ទះ អប់រំស្ត្រីបានចំនួន ១៥៦ នាក់ និងប្រយោល ចំនួន ១៦ផ្ទះ អប់រំស្ត្រីបានចំនួន ៩៤នាក់។

| | No of DSWs | No of IDSWs |
|---|---|---|
| ខែកុម្ភៈ | 145p/15 places | 67p/ 13 places |
| ខែមិនា | 156p/16places | 94p/ 16 places |

- រៀបចំការប្រជុំប្រចាំត្រីមាស ជាមួយម្ចាស់បននិងម្ចាស់គ្រឹះស្ថានសេវាកំសាន្តសប្បាយនានា ព្រមទាំងមានការ ចូលរួមពីរដ្ឋអំណាចមូលដ្ឋាន ក្រុមការងារស្រោមអនាម័យ និងក្រុមចុះអប់រំផ្ទាល់ អ្នកចូលរួមចំនួន ៤២នាក់។

រៀបចំប្រជុំក្រុមមិត្តអប់រំមិត្ត នៃនារីបំរើសេវាផ្លូវភេទដោយផ្ទាល់ និងដោយប្រយោល ចំនួន ២លើក ដោយមានអ្នកចូលរួមមកពីកម្មវិធីប្រយុទ្ធនឹងជម្ងឺអេដស៍មន្ត្រីអប់រំផ្ទាល់ថ្នាក់ខេត្ត មន្ត្រីគ្លីនិកកាមរោគ ចំនួន ៤៥រូប ។

រៀបចំកិច្ចប្រជុំប្រចាំខែរបស់ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្តដោយមានអ្នកចូលរួមជាមន្ត្រីកម្មវិធីអេដស៍ ចំនួន១រូប មន្ត្រីអប់រំផ្ទាល់ថ្នាក់ខេត្ត ចំនួន ៦រូប មន្ត្រីគ្លីនិកកាមរោគចំនួន១រូប

## ៣. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០% :

- រៀបចំប្រជុំក្រុមការងារ១00% ប្រចាំសប្តាហ៏ដែលមានអ្នកចូលរួមប្រជុំ ពី ៨នាក់ ក្នុងមួយលើក
- ផ្គត់ផ្គង់ស្រោមអនាម័យ ចំនួន១២00ស្រោម ដល់ការងារអប់រំផ្ទាល់ គ្លីនិកកាមរោគ និងមណ្ឌលផ្តល់ប្រឹក្សា ធ្វើតេស្តឈាមដោយស្មគ្រ័ចិត្ត និងរក្សាការសំងាត់

## ៤. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ :

- រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រង និងថែទាំជម្ងឺកាមរោគ សំរាប់ស្ត្រីរកស៊ីផ្លូវភេទ ដល់មន្ត្រីគ្លីនិក កាមរោគ ចំនួន៥នាក់ ព្រមទាំងមានសំរបសំរួលពីគ្រូបង្គោលមជ្ឈមណ្ឌលជាតិ ចំនួន២រូប គ្រូបង្គោលមកពី អង្គការ FHI ចំនួន ១រូប និងគ្រូបង្គោលក្រុង ប៉ៃលិន ចំនួន ២រូប
- ផ្តល់សេវាកាមរោគចល័ត សំរាប់ព្យាបាលស្ត្រីរកស៊ីផ្លូវភេទនៅព្រំដែន ដែលមិនអាចមកកាន់ គ្លីនិក កាមរោគ ជារៀងរាល់ខែ
- មន្ត្រី៣រូបបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងជំងឺកាមរោគសំរាប់អ្នកអភិបាលនៅថ្នាក់ស្រុកប្រតិបត្តិ នៅខេត្តបន្ទាយមានជ័យ រយះពេល៥ថ្ងៃ។
- រៀបចំបញ្ចូលទិន្នន័យថ្មី នៃជម្ងឺកាមរោគ ទៅក្នុងកុំព្យូទ័រ ជារៀងរាល់ខែ
- ការប្រជុំសំរបសំរួលការងារបច្ចេកទេស ចំនួន ១ដង របស់មន្ត្រីគ្លីនិកកាមរោគ ដែលមានអ្នកចូលរួម ចំនួន ៨នាក់

## ៥. កម្មវិធីថែទាំអ្នកជំងឺអេដស៍

- សហការជាមួយអង្គការ BWAP ធ្វើការស្រាវជ្រាវ និងថែទាំអ្នកជម្ងឺអេដស៍តាមផ្ទះ លើភូមិ ចំនួន ៧៩ អ្នកជម្ងឺរ៉ាំរ៉ៃ ដែលបានទទួលការថែទាំ ចំនួន ៤៣នាក់ អ្នកផ្ទុកមេរោគអេដស៍ចូលរួមថ្មីចំនួន ៥នាក់។ ក្នុងឆ្នាំ ២00៤ នេះដែរ អ្នកផ្ទុកមេរោគអេដស៍ និអអ្នកជម្ងឺអេដស៍ ត្រូវបានបង្កើតរៀបរៀងចងក្រងឱ្យមានជា ក្រុមមិត្តជួយមិត្ត នៅតាមសហគមន៏ ចំនួន ២ក្រុម

## ៦. ផែនការ និងការសំរបសំរួលកម្មវិធី

- សិក្ខាសាលារៀបចំផែនការប្រចាំឆ្នាំ រយៈពេល ៣ថ្ងៃ អ្នកចូលរួមក្រុមការងារ ស្ថាប័នពាក់ពន្ធ័ និង NGOs ចំនួន ៣៧នាក់
- រៀបចំរបាយការណ៏ប្រចាំខែ អំពីសកម្មភាពបង្ការនិងថែទាំជម្ងឺអេដស៏/កាមរោគ ដែលបានអនុវត្តន៏ ក្នុងខែ និមួយៗ ផ្ញើមកមជ្ឈមណ្ឌលជាតិ

**សកម្មភាពផ្សេងៗ :**

- សហការជាមួយអង្គការ PSI ក្នុងការប្រគុំតន្ត្រីសម័យ ជុំរុញការប្រើប្រាស់ស្រោម អនាម័យ ១00% នៅទីក្រុងប៉ៃលិនដោយមានការចូលរួមពីលោកអភិបាលរងទី៣ក្រុងប៉ៃលិន អស់លោក មេបញ្ជារការ កងកំលាំង ប្រដាប់អាវុធ នគរបាល កងរាជអាវុធហត្ថ លោក លោកស្រី មន្ត្រីរាជការ គ្រប់ស្ថាបន័ តំណាង អង្គការនានា ព្រមទាំងប្រជាជន នៅក្នុងខណ្ឌ័ទាំងពីរ ចំនួនជាង ១ម៉ឺននាក់ ។

## ១៤. ក្រុងភ្នំពេញ

### ១. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- ការចុះអប់រំប្រចាំខែរបស់ក្រុមមិត្តអប់រំមិត្តនៃនារីបំរើសេវាផ្លូវភេទដោយផ្ទាល់ និងដោយប្រយោល នៅតាម ផ្ទះបន និងនៅទីកន្លែងកំសាន្តសប្បាយ ។

### ២. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១00%

- រៀបចំប្រជុំក្រុមការងារ ១00% ប្រចាំសប្តាហ៏ ដែលមានអ្នកចូលរួមប្រជុំ ២0នាក់ ក្នុងមួយលើក ។

-រៀបចំប្រជុំប្រចាំខែរបស់គណៈកម្មាការ តាមដាន និងវាយតំលៃកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១00% អ្នកចូលរួមប្រជុំ ២៧ នាក់ ក្នុងមួយលើក ។

### ៣. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

### ៤. កម្មវិធីថែទាំអ្នកជំងឺអេដស៏

### ៥. ផែនការ និងការសំរបសំរួលកម្មវិធី

ការរៀបចំកិច្ចប្រជុំប្រចាំខែ សំរាប់បណ្តាញការងារអេដស៏/កាមរោគ

# ១៥. ខេត្ត ពោធិសាត់

## ១. ពត៌មានអប់រំ និងទំនាក់ទំនង មហាជន

- ការចាក់ផ្សាយ ការអប់រំពីជំងឺអេដស៍ នៅតាមវិទ្យុ ៩៨.៥ MHz នៅតាមទូរទស្សន៍ ខេត្ត

## ២. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- ការចុះអប់រំប្រចាំខែ របស់ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត ដល់នារីបំរើសេវាផ្លូវភេទដោយផ្ទាល់ និងដោយប្រយោល នៅតាមទីកន្លែងកំសាន្តសប្បាយ( ដែលមានបន្ទប់សំរាប់បំរើសេវារួមភេទ ) ០៣ លើក ។
- ការងារអភិបាលរបស់ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត លើកម្មវិធីមិត្តអប់រំមិត្ត នៅស្រុកក្រគរ និង ស្រុកក្រវាញ
- កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍/កាមរោគខេត្តបានរៀបចំការប្រជុំប្រចាំខែ ដល់ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត ចំនួន ០៣លើក ក្នុងត្រីមាសទី១ ។
- ការរៀបចំកិច្ចប្រជុំសំរបសំរួលរវាង PHD, CUMEC, CUWG, POT and STI ។

## ៣. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

- រៀបចំការប្រជុំប្រចាំសប្តាហ៍របស់ក្រុម CUWG ចំនួន ០៨លើក
- ការទិញស្រោមអនាម័យចំនួន៥០ប្រអប់ សំរាប់បំរើការងារប្រយុទ្ធនឹងជម្ងឺអេដស៍ នៅក្នុងកម្មវិធីអេដស៍ ខេត្ត

## ៤. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

- ផ្គត់ផ្គង់សំភារៈការិយាល័យសំរាប់ប្រើប្រាស់ក្នុងគ្លីនិកកាមរោគ
- ការចុះអភិបាលចំនួន ០១លើក របស់មន្ត្រីផ្នែកជំងឺកាមរោគខេត្ត នៅតាមស្រុកប្រតិបត្តិ និង មណ្ឌល សុខភាពទាំង ១៣

## ៥. កម្មវិធីថែទាំអ្នកជំងឺអេដស៍

✰ *ការថែទាំអ្នកជំងឺក្នុងមន្ទីរពេទ្យ:* (Institutional Care)

✰ *មណ្ឌលផ្តល់ប្រឹក្សា ធ្វើតេស្តឈាមដោយស្មគ្រ័ចិត្ត និងរក្សាការសំងាត់ (VCCT):*

- ធ្វើការផ្សព្វផ្សាយអំពីមណ្ឌលផ្តល់ប្រឹក្សា ធ្វើតេស្តឈាមដោយស្មគ្រ័ចិត្ត និងរក្សាការសំងាត់ ចំនួន ៦០លើក តាមរយៈវិទ្យុ FM 98.5 MHz និងតាមរយៈ TVK
-

| Date | Male clients | Male HIV (+) | Female clients | Female HIV (+) |
|---|---|---|---|---|
| January | 63 | 7 | 86 | 9 |
| February | 56 | 5 | 44 | 11 |
| March | 78 | 14 | 50 | 12 |

- ផ្គត់ផ្គង់សំភារៈមន្ទីរពិសោធន៍ សំរាប់មណ្ឌលផ្តល់ប្រឹក្សា ធ្វើតេស្តឈាមដោយស្មគ្រ័ចិត្ត និង រក្សាការ សំងាត់ក្នុងទីរួមខេត្ត
- ផ្គត់ផ្គង់សំភារៈការិយាល័យ សំរាប់ប្រើប្រាស់ក្នុងមណ្ឌលផ្តល់ប្រឹក្សាធ្វើតេស្តឈាមដោយស្មគ្រ័ចិត្ត និង រក្សាការសំងាត់

✰ *សកម្មភាពថែទាំបន្ត (CoC):*

- រៀបចំការប្រជុំប្រចាំខែរបស់គណៈកម្មាធិការការងារថែទាំបន្ត ( CoC ) ចំនួន០២លើក
- ធ្វើការផលិតសៀវភៅឯកសារចំនួន១៥០ក្បាល ស្តីពីពតិមានសំរាប់ផ្តល់សេវាថែទាំសុខភាពដល់អ្នកផ្ទុកមេរោគអេដស៍/អ្នកជម្ងឺអេដស៍នៅក្នុងខេត្ត នៅខេត្តពោធិសាត់ និងតាមបណ្តាខេត្តនានា
- រៀបចំការប្រជុំប្រចាំខែរបស់មណ្ឌលមិត្តជួយមិត្ត (MMM)ចំនួន ០២លើក
- ចុះអភិបាលលើការងារថែទាំបន្ត នៅតាមស្រុកប្រត្តិបត្តិ និងមណ្ឌលសុខភាព ចំនួន ០១លើក

✰ *សកម្មភាពបង្ការចំលងមេរោគអេដស៍ពីម្តាយទៅទារក (PMTCT):*

- ដំណើរការសិក្ខាសាលាស្តីពីការផ្តល់ប្រឹក្សា ធ្វើតេស្តឈាមដោយស្មគ្រ័ចិត្ត និងរក្សាការសំងាត់ និង ការការពារ ការចំលងមេរោគអេដស៍ ពីម្តាយទៅកូន

| Date | No of ANC | No of Women attended mother's class | No of Women got HIV testing | No of HIV (+) | No of Women received Nevirapine |
|---|---|---|---|---|---|
| Jan | 194 | 194 | 59 | 5 | 0 |
| Feb | 188 | 188 | 50 | 0 | 1 |
| March | 222 | 222 | 52 | 0 | 1 |

## ៦. ផែនការ និងការសំរបសំរួលកម្មវិធី

- ដំណើការសិក្ខាសាលាស្តីពីការរៀបចំធ្វើផែនការបង្ការ និងថែទាំជម្ងឺអេដស៍/កាមរោគសំរាប់ឆ្នាំ ២០០៥ រយៈពេល ០៣ថ្ងៃ នៅទីរួមខេត្តពោធិសាត់
- ការឡើងមកទំនាក់ទំនងការងារបច្ចេកទេស និងការងារថវិកា ជាមួយមជ្ឈមណ្ឌលជាតិ រវាងមន្ត្រីកម្មវិធី អេដស៍ខេត្ត និងមន្ត្រីគណនេយ្យមន្ទីរសុខាភិបាលខេត្ត
- មន្ត្រីកម្មវិធអេដស៍ ចំនួន ០៥រូប បានអនុញ្ញាតិឱ្យសិក្សាផ្នែកភាសាអង់គ្លេស នៅមជ្ឈមណ្ឌល ACD + PILC Pursat.
- ផ្គត់ផ្គង់លើមធ្យោបាយទំនាក់ទំនងដូចជា ទូរសព្ទ័លើតុក្នុងការិយាល័យ និងប្រពន្ធ័អ៊ីមែល
- ផ្គត់ផ្គង់សំភារៈការិយាល័យមួយចំនួនសំរាប់កម្មវិធីប្រយុទ្ធនឹងជម្ងឺអេដស៍ខេត្ត

## ១៦. ខេត្ត រត្តនៈគិរី

### ១. ពត៏មានអប់រំ និងទំនាក់ទំនង បហាផន

- ការផ្សព្វផ្សាយតាមប្រព័ន្ធទូរទស្សន៍ខ្សែកាប ស្តីពីជំងឺអេដស៍/កាមរោគ

### ២. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- កម្មវិធីចុះអប់រំផ្ទាល់ដល់នារីបំរើសេវាផ្លូវភេទដោយផ្ទាល់ នៅតាមផ្ទះបនចំនួន១០ និងអប់រំស្ត្រីបានចំនួន ៣៧នាក់
- ការប្រជុំសំរបសំរួលរយៈពេល១ថ្ងៃ នៅមន្ទីរសុខាភិបាលខេត្ត ដែលមានអ្នកចូលរួមចំនួន២០រូបមកពី CUMEC, CUWG, POT, និងម្ចាស់បន
- វគ្គបណ្តុះបណ្តាលស្តីពីជំងឺអេដស៍កាមរោគដល់ក្រុមមិត្តអប់រំមិត្តចំនួន១០នាក់ និងសមាជិកកម្មវិធី ប្រយុទ្ធនឹងជម្ងឺអេដស៍ខេត្ត ចំនួន ០២នាក់
- ការប្រជុំដោយមានការចូលរួមពីក្រុមមិត្តអប់រំមិត្តចំនួន០៨នាក់ និងសមាជិកក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត ចូលរួម ចំនួន៤ក្រុម
- ការប្រជុំប្រចាំខែរបស់កម្មវិធីប្រយុទ្ធនឹងជម្ងឺអេដសដ៏ថ្នាក់ខេត្ត ដោយមានដមាជិកចូលរួមចំនួន ០៥រូប ។

### ៣. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

- រៀបចំប្រជុំប្រចាំខែ របស់គណៈកម្មាការ តាមដាន និងវាយតំលៃកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ចំនួនបី លើក ក្នុងទ្រីមាសទី១ សមាជិកចូលរួមចំនួន០៦នាក់ ។
- រៀបចំប្រជុំក្រុមការងារ ១០០% ប្រចាំសប្តាហ៍ ចំនួន ៤៨លើក ដែលមានអ្នកចូលរួមប្រជុំ ៤នាក់ ក្នុងមួយ លើក ។

- ផ្គត់ផ្គង់សំភារៈការិយាល័យមួយចំនួនសំរាប់ការងាររបស់ក្រុម CUMEC,CUWG.
- ផ្គត់ផ្គង់ស្រោមអនាម័យ ចំនួន៦០០០ស្រោមទៅគ្លីនិកជម្ងឺកាមរោគ និងក្រុមការងារអប់រំផ្ទាល់

**៤. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ**

- ផ្គត់ផ្គង់សំភារៈសំរាប់ប្រើប្រាស់ក្នុងគ្លីនិកកាមរោគ រាល់ខែក្នុងត្រីមាសទី១ ឆ្នាំ២០០៤
- ការចុះអភិបាលការងារថែទាំជម្ងឺកាមរោគ ១៤លើកនៅមណ្ឌលសុខភាពចំនួន៧

**៥. ផែនការ និងការសំរបសំរួលកម្មវិធី :**

- ការឡើងមកទំនាក់ទំនងការងារ រវាងមន្ត្រីកម្មវិធីអេដស៍មន្ត្រីគណនេយ្យមន្ទីរសុខាភិបាលជាមួយមជ្ឈមណ្ឌលជាតិចំនួន០៣លើក
- មន្ត្រីកម្មវិធីអេដស៍ខេត្ត ចំនួន ០៣រូប បានបញ្ជូនទៅសិក្សាភាសាអង់គ្លេសនៅវិទ្យាស្ថាន BBU

## ១៧. ខេត្ត សៀមរាប

**១. ពត៏មានអប់រំ និងទំនាក់ទំនង មហាជន**

- ធ្វើការផ្សព្វផ្សាយតាមរយៈ ទូរទស្សន៍ខ្សែកាបខេត្ត ចំនួន ៣៤ លើក (រយៈពេល ១៧ថ្ងៃក្នុង១ថ្ងៃ២លើក)

  និងតាមរយៈវិទ្យុនៅក្នុងទីរួមខេត្តនូវសារអប់រំពីជម្ងឺអេដស៍/កាមរោគចំនួន២០លើក(រយៈពេល១០ថ្ងៃ ក្នុង ១ថ្ងៃ២លើក)
- ធ្វើការចែកចាយសំភារៈសំរាប់ធ្វើការផ្សព្វផ្សាយ-អប់រំស្តីអំពីការការពារថែទាំ និងគាំទ្រដល់អ្នកផ្ទុកមេរោគ អេដស៍ និងអ្នកជំងឺអេដស៍ ទៅតាមស្រុកប្រតិបត្តិទាំង៣។
- ប្រារព្ធទិវាសិល្បៈផ្សព្វផ្សាយស្តីពីជម្ងឺអេដស៍ និងជំរុញឱ្យមានការប្រើប្រាស់ ស្រោមអនាម័យ ១០០% ដល់ ប្រជាជនទូទៅក្នុងទីរួមខេត្ត

**២. កម្មវិធីមិត្តអប់រំមិត្ត**

- ការចុះធ្វើការអប់រំដោយផ្ទាល់ និងត្រួតពិនិត្យសកម្មភាពការងាររបស់" មិត្តអប់រំមិត្ត" ចំនួន៧៧ លើក ដោយក្រុម POT ត្រូវបានធ្វើទៅលើផ្ទះបនចំនួន ២៦កន្លែង និងចំនួន ១៦លើក ទៅលើសេវាកំសាន្ត សប្បាយ ដែលមានបំរើសេវាផ្លូវភេទ ក្នុងនោះមាន ៩ក្រុមហ៊ុនស្រាបៀរ និង១៧កន្លែង ម៉ាស្សា-ការ៉ាអូខេ នៅក្នុងទីរួម ខេត្តសៀមរាប។

- ការប្រជុំ ៤ដង ក្នុងត្រីមាសទី១ ជាមួយក្រុមមិត្តអប់រំមិត្ត នៃនារីរកស៊ីផ្លូវភេទដោយផ្ទាល់ និងដោយ ប្រយោល ដែលមានស្ត្រីជាក្រុមមិត្តអប់រំមិត្ត ចូលរួមសរុប ៧៦នាក់ ។
- ការបជុំប្រចាំខែរបស់ក្រុមអប់រំផ្ទាល់ខេត្ត រយៈពេល១ថ្ងៃដែលមានសមាជិកចូលរួមចំនួន ១៣នាក់ ។
- ការធ្វើផែនទីកំណត់នូវទីតាំងសេវាបំរើផ្លូវភេទ ដើម្បីងាយស្រួលក្នុងការងារគ្រប់គ្រង និងចុះអនុវត្តន៏ សកម្មភាព ។
- ការចុះអភិបាលការងារអប់រំផ្ទាល់ នៅតាមសេវាបំរើផ្លូវភេទ ចំនួន ០៦លើក ដែលក្នុងនោះ នៅតាមផ្ទះបន ចំនួន៦កន្លែង ។

## ៣. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

- រៀបចំកិច្ចប្រជុំប្រចាំសប្តាហ៏របស់ក្រុមការងារអនុវត្តកម្មវិធីស្រោមអនាម័យ១00% នៅរាល់សប្តាហ៏ ចំនួន ១២លើក ដែលមានសមាជិកចូលរួមពីក្រុមការងារ និងគ្លីនិករោគ ។
- ការចុះណាត់ស្ត្រីនៅតាមផ្ទះបនមកពិនិត្យជម្ងឺកាមរោគនៅគ្លីនិកកាមរោគមណ្ឌល១ សំរាប់ជុំទី ២២ និង ២៣ តាមដានត្រួតពិនិត្យការប្រើប្រាស់ស្រោមអនាម័យ នៅតាមសេវាបំរើផ្លូវភេទ ដោយផ្ទាល់ ព្រមទាំងធ្វើការ ស្រាវជ្រាវបន្ថែមនៅលើសេវាកើតថ្មីសំរាប់ដាក់បញ្ចូលក្នុងកម្មវិធី
- ការផ្គត់ផ្គង់ស្រោមអនាម័យបន្ថែមដល់សេវសបំរើផ្លូវភេទតាមរយៈការចុះរបស់ក្រុមការងារ ក្រុមអប់រំផ្ទាល់ នៅគ្លីនិកពិនិត្យជម្ងឺកាមរោគ និងមណ្ឌលផ្តល់ប្រឹក្សាធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការ សំងាត់

## ៤. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

- រៀបចំវគ្គបណ្តុះបណ្តាលបំប៉នចំនួន០៣ថ្ងៃ ដល់មន្ត្រីគ្លីនិកកាមរោគ ចំនួន០៦រូប អំពីការ គ្រប់គ្រង និងថែទាំ និងព្យាបាលជំងឺកាមរោគ សំរាប់ស្ត្រីរកស៊ីផ្លូវភេទ
- ចុះអភិបាលការងារគ្រប់គ្រង និងថែទាំជម្ងឺកាមរោគ នៅតាមស្រុកប្រតិបត្តិទាំងបី ( សៀមរាប សូទ្រនិគម និងក្រឡាញ់)

Coverage of STD clinic

| Date | No of SWs register by CUWG | No of SWs attended in STD clinic | Coverage |
|---|---|---|---|
| January | 205p | 200p | 97% |
| February | 206p | 199p | 96% |
| March | 211p | 207p | 98% |

➢ *ចំពោះប្រជាជនទូទៅ:*

- ការព្យាបាលជំងឺកាមរោគបានចំនួន ១៧៣៥ករណី (ខែមករា ៨២៥នាក់ កុម្ភៈ ២៤៣៨នាក់ ខែមិនា ៤៧៦នាក់ ) ដែលក្នុងនោះការព្យាបាលដៃគូបានចំនួនតែ ៣៧% (ខែមករា ១០% កុម្ភៈ ១៣% ខែមិនា ១៤% )

## ៥. កម្មវិធីថែទាំអ្នកជំងឺអេដស៍

*១. ការថែទាំអ្នកជំងឺអេដស៍នៅមន្ទីរពេទ្យ និងការថែទាំបន្ត:*

- មន្ទីរពេទ្យបង្អែកខេត្តសៀមរាប មន្ទីរពេទ្យបង្អែកស្រុកសូទ្រនិគម សហការជាមួយអង្គការគ្រូពេទ្យគ្មានព្រំដែន និងអង្គការ ESTHER បានធ្វើការព្យាបាល និងផ្តល់ថ្នាំប្រឆាំងនឹងមេរោគអេដស៍ ដល់អ្នកផ្ទុក មេរោគអេដស៍ និងអ្នកជំងឺអេដស៍ថ្មីបានចំនួន នាក់ (ខែមករា ខែកុម្ភៈ ខែមិនា៤៨) សរុបករណីដែល ទទួលបានថ្នាំ ប្រឆាំង នឹងមេរោគអេដស៍ ទាំងអស់ចំនួន ៣៥៧ នាក់ ។
- ការប្រជុំរយៈពេល០១ថ្ងៃ ចំនួន០៣លើក ក្នុងត្រីមាសទី១ ឆ្នាំ២០០៤ របស់ក្រុមមិត្តជួយមិត្ត ដែលរៀបចំ

  ដោយកម្មវិធីអេដស៍ខេត្តនៅមន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិសៀមរាបដែលមានការចូលរួមពីអ្នកផ្ទុកមេរោគ អេដស៍ និងអ្នកជំងឺអេដស៍ចំនួន ៥៥នាក់ ។
- រៀបចំកិច្ចប្រជុំប្រចាំខែ(កុម្ភៈ និងមិនា)រយៈពេល ០១ថ្ងៃ របស់គណៈកម្មាការសំរបសំរួលការថែទាំ បន្ត នៅក្នុងមន្ទីរ ពេទ្យបង្អែកស្រុកប្រតិបត្តិសៀមរាប ដែលមានសមាជិកចូលរួមចំនួន២២ រូប
- កាចុះអភិបាលការងារស្តីពីការថែទាំ និព្យាបាលបន្តនៅក្នុងស្រុកប្រតិបត្តិសូត្រនិគម ចំនួន ០១លើក ។
- កាចុះអភិបាលការងារស្តីពីការថែទាំ និព្យាបាលបន្ត របស់ថ្នាក់ស្រុកប្រតិបត្តិសូត្រនិគម ចំនួន ០២លើក ។

*២.ការថែទាំអ្នកជំងឺអេដស៍នៅតាមផ្ទះ :*

- អង្គការ BFD និងអង្គការ CARITA បានចុះធ្វើការថែទាំ នឹងផ្តល់ប្រឹក្សាដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជម្ងឺអេដស៍ ព្រមទាំងអ្នកជម្ងឺកុំារ៉ែ និងក្មេងដែលទទួលរងគ្រោះដោយសារជម្ងឺអេដស៍ នៅស្រុក សៀមរាប និងស្រុកពួក ដែលមានអ្នកជម្ងឺសរុប នាក់ ( ខែមករា ខែកុម្ភៈ ខែមិនា ៣៩៨ ) ។

- សិក្ខាសាលារយៈពេល ០៤ថ្ងៃ ស្តីពីការបង្កើតបណ្តាញសំរបសំរួលអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជម្ងឺ អេដស៍ ដែលរៀបចំឡើងដោយអង្គការ KHANA.
- សិក្ខាសាលារយៈពេល ០៥ថ្ងៃ ស្តីពីការគាំទ្រផ្នែកចិត្តសាស្ត្រសង្គម ដល់អ្នកផ្ទុកមេរោគអេដ៏ និងអ្នក កើតជម្ងឺអេដស៍ នៅក្នុងបណ្តាញដែលមានស្រាប់ក្នុងខេត្ត រៀបចំដោយកម្មវិធី ESTHER.

*៣. ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សារការសំងាត់:*

- មណ្ឌលផ្តល់ប្រឹក្សា ធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ នៅមណ្ឌល១ បានទទួល អតិថិជន និងបានបញ្ជូនទៅស្វែងរកការព្យាបាល នៅក្នុងមន្ទីរពេទ្យបង្អែក នៃស្រុកប្រតិបត្តិ សៀមរាប និងសូទ្រនិគម។

| Date | Male clients | Female clients | Total | HIV (+) |
|---|---|---|---|---|
| January | 95 | 124 | 219 | 70 |
| February | 87 | 110 | 197 | 77 |
| March | 117 | 133 | 250 | 84 |

- VCCT in Sot Nikum RH:

| Date | Clients | HIV (+) |
|---|---|---|
| January | | |
| February | | |
| March | 54 | 8 |

## ៦. ផែនការ និងការសំរបសំរួលកម្មវិធី

- ការប្រជុំប្រចាំសប្តាហ៍ នៃបុគ្គលិកធ្វើការនៅក្នុងផ្នែកប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត និងបុគ្គលិក គ្លីនិកកាមរោគ មណ្ឌល១
- កិច្ចប្រជុំប្រចាំខែជាមួយបណ្តាបុគ្គលិក PAOs, DAOs, OD coordinators និងតំណាង អង្គការនានា ដែលសកម្មភាពទាក់ទងនឹងការងារអេដស៍ /កាមរោគ។
- ការឡើងទំនាក់ទំនងការងាររវាងមន្ត្រីកម្មវិធីអេដស៍/មន្ត្រីគណនេយ្យមន្ទីរសុខាភិបាលខេត្ត ជាមួយមជ្ឈ មណ្ឌលជាតិ

- ចុះអភិបាលការអនុវត្តន៍សកម្មភាពអេដស៍/កាមរោគ នៅតាមស្រុកប្រតិបត្តិទាំងបី ចំនួន ០៣លើក

រៀបចំវគ្គសិក្ខាសាលាចំនួន០៣ថ្ងៃ ស្តីពីការរៀបចំគំរោងផែនការសកម្មភាពសំរាប់ឆ្នាំ ២០០៥ នៅក្នុងទីរួមខេត្ត មានអ្នកចូលរួមចំនួនពីស្រុកប្រតិបត្តិទាំងបី និងអង្គការដៃគូ សរុបចំនួន ៣៥ នាក់។

# ១៨. ក្រុងព្រះសីហនុ

## ១. ពត៌មានអប់រំ និងទំនាក់ទំនង មហាជន

- ការផ្សព្វផ្សាយតាមប្រព័ន្ធវិទ្យុ ជាប្រចាំ ស្តីពីជំងឺអេដស៍/កាមរោគ មានចំនួន ៣០ ស្ពត ក្នុងមួយខែ

## ២. កម្មវិធីមិត្តអប់រំមិត្ត

- កម្មវិធីចុះអប់រំផ្ទាល់ ដល់ក្រុមប្រឈមមុខខ្ពស់ ដូចជានារីបំរើសេវាផ្លូវភេទដោយផ្ទាល់ និងដោយប្រយោល នៅតាមទីកន្លែងកំសាន្តសប្បាយ ដែលមានចំនួន ៦៥ កន្លែង ទៅលើក្រុមអ្នកបើកបរឡានតាក់ស៊ី ក្រុម មន្ត្រីកងរាជអាវុធហត្ថ ក្រុមអ្នកធ្វើការងារក្នុងកាស៊ីណូ និងលើក្រុមកម្មករកំពង់ផែ




- រៀបចំការប្រជុំប្រចាំខែ ដល់ក្រុមអប់រំផ្ទាល់ថ្នាក់ ខេត្ត អ្នកចូលរួមប្រជុំ ចំនួន ១០រូប

- រៀបចំការប្រជុំប្រចាំត្រីមាស ជាមួយម្ចាស់គ្រឹះស្ថានបំរើសេវាផ្លូវភេទ ដោយមានអ្នកចូលរួម ចំនួន ៦០នាក់ ដោយមានការគាំទ្រផ្នែកថវិកាពីអង្គការ FHI
- រៀបចំការប្រជុំ ជាមួយក្រុមមិត្តអប់រំមិត្ត អ្នកអប់រំបន្ត នារីបំរើសេវាផ្លូវភេទដោយផ្ទាល់ ដោយមានអ្នក ចូលរួមចំនួន ៣៩៥ នាក់ ដែលឧបត្ថមដោយអង្គការ FHI
- កម្មវិធីចុះអប់រំផ្ទាល់ដល់សហគមន៏ របស់កម្មវិធីប្រយុទ្ធនឹងជម្ងឺអេដស៏/កាមរោគ ចំនួន ២ដង ក្នុងមួយខែ និងអប់រំប្រជាជនបានចំនួន ៧៤នាក់ ( នៅខែមិនា)

## ៣. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

- រៀបចំប្រជុំក្រុមការងារ ១00%ប្រចាំសប្តាហ៏ដែលមានអ្នកចូលរួមប្រជុំ១៨នាក់ ក្នុងមួយលើក
- រៀបចំប្រជុំប្រចាំខែ របស់គណៈកម្មាការ តាមដាន និងវាយតំលៃ កម្មវិធីប្រើប្រាស់ស្រោម អនាម័យ ១00% ដែលមួយលើកមានអ្នកចូលរួមប្រជុំ ចំនួន ១៤នាក់ ។
- ផ្គត់ផ្គង់ស្រោមអនាម័យចំនួន ៥000ស្រោម សំរាប់ក្រុមការងារអប់រំផ្ទាល់ថ្នាក់ខេត្ត មណ្ឌល ផ្តល់ប្រឹក្សាធ្វើ តេស្តឈាមដោយស្ម្រគ័ចិត្ត និងរក្សាការសំងាត់ គ្លីនិកកាមរោគខេត្ត

## ៤. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

- ការចុះអភិបាលរបស់មន្ត្រីផ្នែកកាមរោគស្រុកប្រតិបត្តិ ចំនួន ២រូប ទៅមណ្ឌលសុខភាព ចំនួន ៦
- រៀបចំវគ្គបណ្តុះបណ្តាលបំប៉ន រយៈពេល ៣ថ្ងៃ ស្តីពីការគ្រប់គ្រង និងថែទាំជម្ងឺកាមរោគ ដល់មន្ត្រីមណ្ឌល សុខភាព ចំនួន ៩ និងមន្ទីរពេទ្យបង្អែកក្រុង មានសិក្ខាកាមចូលរួម ចំនួន ២៥នាក់



## ៥. កម្មវិធីថែទាំអ្នកជំងឺអេដស៍

*១. មណ្ឌលធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងផ្តល់ប្រឹក្សា:*

| Date | Total clients | HIV (+) |
|---|---|---|
| January | 36 | 22 |
| February | 105 | 39 |
| March | | |

*២. ការថែទាំក្នុងមន្ទីរពេទ្យ:*

## ៦. ផែនការ និងការសំរបសំរួលកម្មវិធី

- រៀបចំវគ្គសិក្ខាសាលា រយៈពេល ៣ថ្ងៃ ស្តីពីការរៀបចំគំរោងផែនការប្រចាំឆ្នាំ ២០០៥ ដែលមានការ ចូលរួមពី មន្ទីរពេទ្យក្រុង មន្ទីរសុខាភិបាល កម្មវិធីអេដស៍ខេត្ត មណ្ឌលសុខភាពទាំង ៩ និង អង្គការជាដៃគូ។
- ការរៀបចំកិច្ចប្រជុំសំរបសំរួលជាមួយអង្គការនានា ដោយមានអ្នកចូលរួមចំនួន ២០នាក់
- បុគ្គលិកកម្មវិធីអេដស៍ចំនួន០៤នាក់ បញ្ជូនអោយទៅរៀនភាសាអង់គ្លេស និងចំនួន៤នាក់រៀនកុំព្យូទ័រ។

# ១៩. ខេត្ត ស្ទឹងត្រែង

## ១. ពត៌មានអប់រំ និងទំនាក់ទំនង មហាជន

- ការផ្សព្វផ្សាយពីពតិមានជំងឺអេដស៍/កាមរោគ តាមរយៈទូរទស្សន៍ ខ្សែកាបខេត្តប៉ុស្តិលេខ ១ រយៈពេល ២នាទី ស្តួតស្តីពីរឿងត្រូវស្មោះត្រង់ជាមួយប្រពន្ធអ្នក ការប្រើបាស់ស្រោមអនាម័យ ១០០% ស្ត្រីត្រូវនិយាយ ជាមួយស្វាមីអំពីបញ្ហាអេដស៍ អេដស៍គ្មានថ្នាំព្យាបាលទេ (ចំនួន ២៤លើក ក្នុងមួយខែ)

## ២. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- ការចុះអប់រំផ្ទាល់ជារៀងរាល់ខែ របស់ក្រុមអប់រំផ្ទាក់ថ្នាក់ខេត្ត ចំនួន ៤រូប រយៈពេល ១៦ថ្ងៃ ដល់ នារីបំរើ សេវាផ្លូវភេទដោយផ្ទាល់ និងដោយប្រយោលនៅតាមផ្ទះបន និងនៅទីកន្លែងកំសាន្តសប្បាយ ដែលមានចំនួន ២២កន្លែង និងអប់រំស្ត្រីបានចំនួន ៦៧ នាក់។

- កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍/កាមរោគខេត្ត បានរៀបចំការប្រជុំប្រចាំខែ ដល់ក្រុមអប់រំផ្ទាល់ថ្នាក់ ខេត្ត អ្នកចូលរួមចំនួន ៧រូប (មកពីកម្មវិធីអេដស៍ចំនួន ១រូប មន្ត្រីអប់រំផ្ទាល់ថ្នាក់ខេត្ត ចំនួន ៤រូប មន្ត្រីគ្លីនិក កាមរោគ ចំនួន ២រូប)។
- រៀបចំគូរផែនទីកំណត់ទីតាំងសេវាបំរើផ្លូវភេទដោយផ្ទាល់ សេវាកំសាន្តសប្បាយ និងចុះស្ថិតិនារីរកស៊ីផ្លូវភេទដោយផ្ទាល់ និងប្រយោល។

## ៣. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

- រៀបចំប្រជុំក្រុមការងារ ១00%ប្រចាំសប្តាហ៍ ដែលមានអ្នកចូលរួមប្រជុំ ពី ៦ នាក់ ក្នុងមួយលើក
- រៀបចំប្រជុំប្រចាំខែ របស់គណៈកម្មាការ តាមដាន និងវាយតំលៃ កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១00% ដែលមួយលើកមានអ្នកចូលរួមប្រជុំ ចំនួន ៤-៦នាក់ (CUMEC ៤រូប និង CUWG២រូប)
- ការចែកចាយស្រោមអនាម័យប្រចាំខែ ដល់កម្មវិធីស្រោមអនាម័យ ១00% ផ្នែកគ្លីនិក កាមរោគ និង កម្មវិធីអប់រំផ្ទាល់ ដែលមានចំនួនសរុបទាំងអស់ ២000 ស្រោម ពីកម្មវិធីអេដស៍ខេត្ត ។
- រៀបចំប្រជុំជាមួយក្រុមមិត្តអប់រំមិត្ត នៃនារីបំរើផ្លូវភេទដោយផ្ទាល់ និងដោយប្រយោល ចំនួន ៨0នាក់។

## ៤. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

- ការចុះអភិបាល រយៈពេល៥ថ្ងៃ របស់ផ្នែកជម្ងឺកាមរោគស្រុកប្រតិបត្តិ ចំនួន២រូប ទៅមណ្ឌលសុខភាព ចំការលើ មណ្ឌលសុខភាពថាលា និងមណ្ឌលសុខភាពសៀមប៉ាង ។

## ៥. មណ្ឌលធ្វើតេស្តឈាម ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់

| Date | Male clients | Male HIV (+) | Female clients | Female HIV (+) |
|---|---|---|---|---|
| January | 16 | 3 | 14 | 1 |
| February | 10 | 0 | 7 | 1 |
| March | 14 | 1 | 15 | 2 |

## ៦. ផែនការ និងការសំរបសំរួលកម្មវិធី

- បុគ្គលិកកម្មវិធីអេដស៍ ៤រូប ត្រូវបានបញ្ជូនអោយទៅរៀន ភាសាអង់គ្លេស និង ២រូបរៀន កុំព្យូទ័រ

រៀបចំវគ្គសិក្ខាសាលារយៈពេល៣ថ្ងៃ ស្តីពី ការរៀបចំគំរោងផែនការសំរាប់ឆ្នាំ ២០០៥ ដែលមានសិក្ខាកាម ចូលរួមចំនួន ១៦នាក់មកពីកម្មវិធីអេដស៍ខេត្ត មន្ទីរសុខាភិបាលខេត្ត ក្រុមអប់រំផ្ទាល់ គ្លីនិកកាមរោគ និង អង្គការជាដៃគូ។

# ២០. ខេត្ត តាកែវ

## ១. ពត៌មានអប់រំ និងទំនាក់ទំនង មហាជន

- ការចាក់ផ្សាយពតិមានអប់រំពីជំងឺអេដស៍ជាប្រចាំ ក្នុងមួយថ្ងៃ ១ដង (រយៈពេល១៥នាទី) ១០ថ្ងៃក្នុង ១ខែ ចំនួន ៤ ស្ពត តាមរយៈទូរទស្សន៍ខ្សែកាប ក្នុងទីរួមខេត្តតាកែវ ។

## ២. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- ការចុះអប់រំជាប្រចាំរាល់ខែរបស់ក្រុមអប់រំផ្ទាល់ ដល់នារីបំរើសេវាផ្លូវភេទដោយផ្ទាល់ និង ដោយប្រយោល នៅតាមផ្ទះបន និងនៅតាមទីកន្លែងកំសាន្តសប្បាយ ចំនួន ៤៨កន្លែង។
- រៀបចំកិច្ចប្រជុំប្រចាំត្រីមាស ជាមួយម្ចាស់សេវា
- ប្រជុំចំនួន ០២លើក ក្នុងត្រីមាស ទី១ ជាមួយក្រុមអ្នកអប់រំបន្ត នៃក្រុមនារីរកស៊ីផ្លូវភេទ ដោយផ្ទាល់
- ការប្រជុំប្រចាំខែរបស់ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត ០២ លើក ក្នុងខែកុម្ភៈ និងខែមិនា
- រៀបចំធ្វើផែនទី ដើម្បីកំណត់ទីតាំងសេវាបំរើផ្លូវភេទ( ផ្ទះបន) និងសេវាកកំសាន្តសប្បាយនានា នៅក្នុងស្រុក ចំនួន ០៣ គឺស្រុកដូនកែវ អង្គរកា និងស្រុកគីរីវង្ស។
- រៀបចំវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយស្តីពីជំងឺអេដស៍ និងកាមរោគ ដល់ក្រុមមអប់រំផ្ទាល់ថ្នាក់ ខេត្ត រយៈពេល ០៣ថ្ងៃនៅមន្ទីរ សុខាភិបាល ខេត្ត មានសិក្ខាកាមចូលរួមចំនួន ១៣នាក់។

## ៣. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

- រៀបចំប្រជុំ ប្រចាំសប្តាហ៍ ក្រុមការងារប្រើប្រាស់ស្រោមអនាម័យ១០០% (CUWG) ( ប្រជុំចំនួន ០៤ដង ក្នុងខែកុម្ភៈ និង ០៤ដង ក្នុងខែមិនា ) ។

- រៀបចំការប្រជុំប្រចាំខែ របស់គណៈកម្មាការ តាមដាន និងវាយតំលៃ កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១00% ( ប្រជុំចំនួន 0១ដងក្នុងខែកុម្ភៈ និង 0១ដងក្នុងខែមិនា ) ។
- ការផ្គត់ផ្គង់ស្រោមអនាម័យប្រចាំខែ ដល់មណ្ឌល VCCT, STD Clinic and Outreach programme ។

### ៤. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

- ការចុះអភិបាលលើការងារគ្រប់គ្រង ព្យាបាល និងថែទាំជំងឺកាមរោគ នៅតាមស្រុក ប្រតិបត្តិចំនួន៥ ។
- ទិញសំភារៈមួយចំនួនប្រើប្រាស់ក្នុងការិយាល័យរបស់កម្មវិធីអេដស៍

### ៥. កម្មវិធីថែទាំជំងឺអេដស៍

- ទិញសំភារៈប្រើប្រាស់មួយចំនួនក្នុងមណ្ឌលផ្តល់ប្រឹក្សា ធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និង រក្សាការសំងាត់ ។

### ៦. ផែនការ និងការសំរបសំរួលកម្មវិធី

- ការប្រជុំប្រចាំខែកុម្ភៈ និងខែមិនា របស់កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍/កាមរោគ ខេត្ត
- ការប្រជុំ របស់មន្ត្រីកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍/កាមរោគ ខេត្ត និងស្រុក ក្នុងខែមិនា ឆ្នាំ ២00៤
- ការបញ្ជូនមន្ត្រីកម្មវិធីអេដស៍ ចំនួន 0៤រូប ទៅសិក្សាភាសាអង់គ្លេស
- រៀបចំសិក្ខាសាលាស្តីពីការធ្វើផែនការសកម្មភាព សំរាប់ឆ្នាំ២00៥ រយៈពេល 0៣ថ្ងៃ នៅមន្ទីរសុខាភិបាល ខេត្តតាកែវ ។

## ២១. ខេត្ត ព្រះវិហារ

### ១. ពត៌មានអប់រំ និងទាក់ទំនង មហាជន

- ការចាក់ផ្សាយពតិមានអប់រំពីជំងឺអេដស៍ កាមរោគតាមវិទ្យុ ៩៩ MHz

### ២. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- ចុះអប់រំប្រចាំខែរបស់មន្ត្រីអប់រំផ្ទាល់ថ្នាក់ខេត្តដល់នារីបំរើសេវាផ្លូវភេទដោយផ្ទាល់ និងប្រយោល នៅតាម ផ្ទះបនចំនួន ១៥ ។
- រៀបចំកិច្ចប្រជុំសំរាប់មិត្តអប់រំមិត្ត ដែលមានអ្នកចូលរួមចំនួន ២៣នាក់ ។

- បានរៀបចំការប្រជុំប្រចាំខែ ដល់ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត ។

### ៣. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

- រៀបចំប្រជុំក្រុមការងារ ១00% ប្រចាំសប្តាហ៍ (CUWG) ។
- រៀបចំប្រជុំប្រចាំខែ របស់គណៈកម្មាការ តាមដាន និងវាយតំលៃ កម្មវិធីប្រើប្រាស ់ស្រោមអនាម័យ ១00% ដែលមួយលើកមានអ្នកចូលរួមប្រជុំចំនួន ៦នាក់ មកពីក្រុមការងារប្រើប្រាស់ស្រោមអនាម័យ ១00% ១នាក់ ក្រុមអប់រំផ្ទាល់១នាក់ និងគ្លីនិកកាមរោគ១នាក់ ។

### ៤. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

- ការចុះអភិបាលលើការងារគ្រប់គ្រង និងថែទាំជំងឺកាមរោគ នៅតាមស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព ។

### ៥. កម្មវិធីថែទាំអ្នកជំងឺអេដស៍

### ៦. ផែនការ និងការសំរបសំរួលកម្មវិធី

- ការរៀបចំកិច្ចប្រជុំប្រចាំខែ របស់កម្មវិធីប្រយុទ្ធជំងឺអេដស៍/កាមរោគ ខេត្ត
- បុគ្គលិកកម្មវិធីអេដស៍ចំនួន ៥នាក់ ត្រូវបានបញ្ជូនអោយទៅរៀន ភាសាអង់គ្លេស និងកុំព្យូទ័រ ។
- 

## ២២. ខេត្ត ឧត្តរមានជ័យ

### ១. ពត៌មានអប់រំ និងទំនាក់ទំនង មហាជន

- ការផ្សព្វផ្សាយការអប់រំពីជំងឺអេដស៍/កាមរោគ ជាប្រចាំ មួយថ្ងៃ ២ ដង( ពេលព្រឹកម៉ោង ៧:៣0 នាទី ល្ងាចម៉ោង ៧:៣0នាទី ) តាមរយៈទូរទស្សន៍ ខេត្ត ។

### ២. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- ចុះអប់រំប្រចាំខែរបស់ក្រុមអប់រំផ្ទាល់ចំនួន 0២រូប ដល់នារីបំរើសេវាផ្លូវភេទដោយផ្ទាល់បានចំនួន ២៩ ផ្ទះបន នៅស្រុកសំរោង ស្រុកអូរស្មាច់ ស្រុកអន្លង់វែង នឹងអប់រំស្ត្រី បានចំនួន ១៤៦ នាក់ ។
- រៀបចំធ្វើផែនទីកំណត់ទីតាំងសេវាបំរើផ្លូវភេទនិងសេវាកំសាន្តសប្បាយនានាដើម្បីសំរួលដល់ការងារគ្រប់គ្រង

- រៀបចំការប្រជុំប្រចាំខែ របស់ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត នៅមន្ទីរសុខាភិបាលខេត្ត ដោយមានសមាជិកចូលរួម ចំនួន ០៨រូប ។

### ៣. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

- រៀបចំប្រជុំក្រុមការងារ ១00% ប្រចាំសប្តាហ៍ (CUWG) បានចំនួន ១០លើក ក្នុងត្រីមាសទី១ ឆ្នាំ ២០០៤
- រៀបចំប្រជុំប្រចាំខែ របស់គណៈកម្មាការ តាមដាន និងវាយតំលៃ កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១00% បានចំនួន ០២លើក ក្នុងត្រីមាសទី ១ ឆ្នាំ២០០៤
- ផ្គត់ផ្គង់ស្រោមអនាម័យប្រចាំខែ អោយដល់ផ្ទះបនចំនួន ២៩ផ្ទះ ។
- ផ្គត់ផ្គង់សៀវភៅតាមដានប្រចាំថ្ងៃសំរាប់ស្ត្រីរកស៊ីផ្លូវភេទ និងផ្តល់ស្រោមអនាម័យ

### ៤. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

- ផ្គត់ផ្គង់សំភារៈមួយចំនួនសំរាប់ប្រើប្រាស់ក្នុងគ្លីនិកកាមរោគ
- មន្ត្រីចំនួន ០៥រូប ចូលរួមក្នុងវគ្គបណ្តុះបណ្តាល នៅខេត្តបន្ទាយមានជ័យ
- ការចុះអភិបាល លើការងារថែទាំ និងព្យាបាលជម្ងឺកាមរោគ ចំនួន០១លើក រយៈ០៧ថ្ងៃ ទៅមណ្ឌលសុភាព ចំនួន ៧ ។

### ៥. ផែនការ និងការសំរបសំរួលកម្មវិធី

- រៀបចំការប្រជុំ ចំនួន ០២លើក ដោយមានសមាជិកចូលរួមចំនួន ១៥រូប
- សិក្ខាសាលារយះះពេល ០៣ថ្ងៃស្តីពី Comprehensive Work Plan for HIV/AIDS/STD 2005 មានសិក្ខាកាមចូលរួមចំនួន២0នាក់ និង ០៩ នាក់ មកពីអង្គការនានា

## ២៣. ខេត្ត មណ្ឌលគីរី

### ១. ពត៌មានអប់រំ និងទំនាក់ទំនង មហាជន

- ការបែងចែកសំភារៈអប់រំ មួយចំនួន ដូចជា ខិត្តបណ្ណ័ ១០០០សន្លឹក ផ្ទាំងរូបភាពធំៗ ចំនួន២០០ សៀវភៅ បើកត្រឡប់ចំនួន១០០ ដល់មណ្ឌលផ្តល់ប្រឹក្សា ធ្វើតេស្តឈាមដោយស្មគ្រ័ចិត្ត និងរក្សាការសំងាត់ គ្លីនិកកាម រោគ និងអង្គការមួយចំនួន និងបិទផ្ទាំងរូបភាពធំៗនៅតាមបណ្តាភោជនីយដ្ឋាននានាផងដែរ ។

## ២. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- ការចុះអប់រំប្រចាំខែ របស់ក្រុមអប់រំផ្ទាក់ថ្នាក់ខេត្ត រយៈពេល ៥ថ្ងៃ ចំនួនបីក្រុម (១ក្រុមមានគ្នា ៤ នាក់ ) ទៅលើសេវាបំរើផ្លូវភេទ និងសេវាបំរើការកំសាន្តសប្បាយនានា ចំនួន ៤ផ្ទះ ក្នុងស្រុកសែន មនោរម្យ ចំនួន ៣ផ្ទះ ក្នុងស្រុកកែវសីម៉ា(ឃុំស្រែខ្ទុម និង ឃុំចុងផ្លាស់(មេម៉ង់) មានស្រីបំរើសេវា ផ្លូវភេទដោយផ្ទាល់ ចំនួន ២៧-៤២នាក់ក្នុង១ខែ។ )
- ការប្រជុំប្រចាំខែរបស់ក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត ចំនួន ៥រូប (មន្ទីរកិច្ចការនារី ចំនួន ១រូប ប៉ូលិស ចំនួន ១រូប ផ្នែកសុខាភិបាលចំនួន ៣រូប) ដើម្បីបូកសរុបរបាយការណ៍ និងលើកសកម្មភាពសំរាប់ខែបន្ទាប់
- រៀបចំគូរផែនទីកំណត់ទីតាំងសេវាបំរើការសប្បាយផ្លូវភេទ និងសេវាបំរើការកំសាន្តសប្បាយនានា ចំនួនបី កន្លែង ក្នុងស្រុកសែនមនោរម្យ ស្រុកកែវសីម៉ា ស្រុកចុងផ្លាស់ មានផ្ទះបនចំនួន ៨កន្លែង និងមានស្ត្រីបំរើ សេវាផ្ទាល់ ចំនួន ៤២នាក់។

## ៣. កម្មវិធីគ្រប់គ្រងជម្ងឺកាមរោគ

- ការចុះអភិបាលលើការងារគ្រប់គ្រង និងថែទាំជម្ងឺកាមរោគ របស់មន្ត្រីផ្នែកជម្ងឺកាមរោគ មណ្ឌលសុខភាព សែនមនោរម្យ អូររាំង កែវសីម៉ា ពេជ្រាដា កោះញែក និងមេម៉ង់។

## ៤. ផែនការ និងការសំរបសំរួលកម្មវិធី

- មន្ត្រីកម្មវិធីអេដស៍ ចំនួន ២រូប បានបញ្ជូនទៅសិក្សាផ្នែកកុំព្យូទ័រ រយៈពេល ១ខែ
- រៀបចំវគ្គសិក្ខាសាលាស្តីពីការធ្វើផែនការប្រចាំឆ្នាំ ២០០៥ ដោយមានអ្នកចូលរួមចំនួន ៨រូប មកពីក្រុមអប់រំ ផ្ទាល់ថ្នាក់ខេត្ត និងមន្ត្រីកម្មវិធីអេដស៍

# ២៤. ខេត្ត ក្រចេះ

## ១. ពត៌មានអប់រំ និងទំនាក់ទំនង មហាជន

- ការចាក់ផ្សាយពតិមានអប់រំពីជំងឺអេដស៍/កាមរោគ ជាប្រចាំតាមទូរទស្សន៍ខ្សែកាប ក្នុងទីរួម ខេត្ត ក្រចេះ ។
- និងតាមរយៈវិទ្យុបន្តសំឡេងក្នុងទីរួមខេត្ត ស្រុកសំបូរ ស្រុកព្រែកប្រសប់ និងស្រុកស្នួល ។

- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទូទៅអំពីការបើកឱ្យដំណើរការមណ្ឌលធ្វើតេស្តឈាម រកមេរោគអេដស៍ និងការមកទទួលសេវាផ្តល់ប្រឹក្សាធ្វើតេស្តឈាម ដោយស្មគ្រ័ចិត្ត និងរក្សាការសំងាត់ នៅទីរួមស្រុក សំបូរ ស្រុកព្រែកប្រសព្វ និងស្រុកស្នួល ។
- ចាក់ផ្សាយស្ពតអប់រំពីជំងឺអេដស៍/កាមរោគតាមហាងកាហ្វេវីដេអូ វិដ្ឋលកាំពី ទីរួមខេត្ត ក្រចេះ ចំនួន ១៨លើក
- សំភារៈដែលចំណាយលើការអប់រំផ្ទាល់ និងការអប់រំសាធារណ :
  - ខិត្តបណ្ណ័ចំនួន ២៣០០ សន្លឹក
  - ផ្ទាំងរូបភាពស្តីពីអេដស៍ ចំនួន ៣៣៨ សន្លឹក
  - ស្ទីកឃ័រ ចំនួន ៩៥០ សន្លឹក
  - សៀវភៅទិនានុលេខន៍ឆ្នាំ២០០៤ ចំនួន ៦០ក្បាល
  - ប្រតិទិនឆ្នាំ ២០០៤ ចំនួន ២០៣ផ្ទាំង
  - ស្រោមអនាម័យ ចមនួន៦៥០០ ស្រោម

## ២. កម្មវិធីអប់រំផ្ទាល់ និងមិត្តអប់រំមិត្ត

- មន្ត្រីអប់រំផ្ទាល់ ចុះធ្វើការអប់រំដល់នារីបំរើសេវាផ្លូវភេទដោយផ្ទាល់ និងប្រយោល នៅតាមសេវា បំរើផ្លូវភេទ និងនៅតាមទីកន្លែងកំសាន្តសប្បាយនានា នៅទីរួមខេត្ត និងនៅស្រុកស្នួលបានចំនួន៦៩ កន្លែង ស្ត្រីដែលបាន អប់រំមានចំនួន ៣៥១នាក់ ។




- ប្រជុំប្រចាំខែកាងារក្រុមអប់រំផ្ទាល់ថ្នាក់ខេត្ត ចំនួនបីលើក

## ៣. កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%

- រៀបចំប្រជុំក្រុមការងារតាមដានការប្រើប្រាស់ស្រោមអនាម័យ ១០០% ប្រចាំសប្តាហ៍ ចំនួន ១២លើក
- រៀបចំប្រជុំប្រចាំខែរបស់គណៈកម្មាការតាមដានត្រួតពិនិត្យ និងវាយតំលៃកម្មវិធីប្រើប្រាស់ស្រោម អនាម័យ ១០០% ចំនួនបីលើក ។
- ផ្គត់ផ្គង់ស្រោមអនាម័យប្រចាំខែ ដល់គ្លីនិកកាមរោគ ចំនួន ១០ប្រអប់ និង ក្រុមអប់រំផ្ទាល់ ចំនួន ២០ប្រអប់ ។

## ៤. កម្មវិធីគ្រប់គ្រងជំងឺកាមរោគ

- ការពិនិត្យនិងព្យាបាលជំងឺកាមរោគ




- រៀបចំវគ្គបន្តុះបណ្តាលស្តីពីការគ្រប់គ្រងជម្ងឺកាមរោគលើនារីរកសីផ្លូវភេទ ដល់បុគ្គលិកមណ្ឌលសុខភាពស្នូលចំនួន ០២រូប ។
- ការចុះអភិបាលលើការងារគ្រប់គ្រង និងថែទាំជម្ងឺកាមរោគ ពីស្រុកប្រតិបត្តិក្រចេះ និងស្រុក ឆ្លូងទៅមណ្ឌលសុខភាព
- ការចុះអភិបាលលើការងារគ្រប់គ្រង និងថែទាំជម្ងឺកាមរោគ ពីមន្ទីសុខាភិបាលទៅស្រុកប្រតិបត្តិ ក្រចេះ និង ឆ្លូង និងមណ្ឌលសុខភាព

## ៥. កម្មវិធីថែទាំអ្នកជំងឺអេដស៍

*១. មណ្ឌលផ្តល់ប្រឹក្សា ធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ :*




## ៦. ផែនការ និងការសំរបសំរួលកម្មវិធី

*១.កិច្ចប្រជុំ :*

- ចូលរួមប្រជុំប្រូកូកុំចំនួន ០២លើក
- ចូលរួមប្រជុំគ្រូពេទ្យប្រចាំភូមិភាគ នៅខេត្តស្ទឹងត្រែង
- ចូលរួមកិច្ចប្រជុំសំរបសំរួលការងារ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ ជាមួយ អង្គការ URC.

*២.វគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលា :*

- ចូលរួមក្នុងសិក្ខាសាលាស្ដីពីពតិមានអប់រំនិងទំនាក់ទំនង នៅមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ
- ចូលរួមក្នុងសិក្ខាសាលាស្ដីពីការរៀបចំធ្វើផែនការសកម្មភាពគ្រប់ជ្រុងជ្រោយ សំរាប់ឆ្នាំ២០០៥ នៅមន្ទីរសុខា ភិបាលខេត្តក្រចេះ
- ចូលរួមក្នុងសិក្ខាសាលាស្ដីពីការពង្រឹងការតាមដានត្រួតពិនិត្យ របាយការណ៍ និងវាយតំលៃ នៅមជ្ឈមណ្ឌល ជាតិប្រយុទ្ធ នឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ
- ចូលរួមក្នុងសិក្ខាសាលា ស្ដីពីការបង្ហាញលទ្ធផលអង្កេតការប្រព្រឹត្តផ្លូវភេទ លើកទី៦ នៅសណ្ឋាគារ សាន់វ៉េ
- ចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលស្ដីពីការអប់រំជម្ងឺអេដស៍ដល់សហគមន៍នៅវិទ្យាស្ថានស្រាវជ្រាវសុខភាព សាធារណៈ

*៣.ការងារសំរបសំរួលជាមួយអង្គការជាដៃគូនានា :*

- ប្រជុំពង្រឹងបណ្តាញការងារជាមួយអង្គការក្រៅរដ្ឋាភិបាលនានាដែលពាក់ពន្ធ័នឹងការងារអេដស៍ ចំនួន 0១ លើក ក្នុងនោះមានអង្គការទ្រទ្រង់យុវជន និងកុមារ LYCSO អង្គការOCAA អង្គការ សុខមាលភាពស្រ្តី KWWA អង្គការ PFD អង្គការ WCRD អង្គការ WYA ។
- ចូលរួមក្នុងសិក្ខាសាលាស្តីពីការរៀបចំផែនការសំរាប់ដៃគូអ្នកអនុវត្តន៏កម្មវិធីរបស់អង្គការ FHI នៅមន្ទីរសុខា ភិបាលខេត្តក្រចេះ ។
- ចូលរួមក្នុងសិក្ខាសាលាស្តីពីការបង្ហាញលទ្ធផលនៃការការសិក្សាវាយតំលៃសេវាមូលដ្ឋានសុខាភិបាល និងការ ប្រើប្រាស់លទ្ធផលសំរាប់ធ្វើផែនការ នៅក្រុងព្រះសីហនុ ដែលឧបត្ថមដោយ URC.




ផ្នែកតាមដានត្រួតពិនិត្យ របាយការណ៍ និង វាយតំលៃ

១, វេជ្ជ, លឹម យី

២, វេជ្ជ, ម៉ុត សុគន្ធារី

៣, វេជ្ជ, ផ្លង់ សុខឡ្ណា

Email: mer@online.com.kh